ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- តួនាទីរបស់អាស៊ានទៅក្នុងអង្គជំនុំជម្រះវិសាមញ្ញកម្ពុជា
- ជនជាតិមិល

លេខ ៦៦ ខែមិថុនា ឆ្នាំ២០០៥

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៦៦ ខែមិថុនា ឆ្នាំ២០០៥


## មាតិកា


◆ សំបុត្រៈ តួនាទីរបស់អាស៊ាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ..........១

**ផ្នែកឯកសារ**

◆ គ្រិន លាន........................................................ ៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១..........១០

◆ កម្ពុជាប្រជាធិបតេយ្យ ៈ ក្នុងក្រសែភ្នែកគណៈប្រតិភូ..............១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គ្រួសារចិនមួយក្នុងរបបខ្មែរក្រហម....................................១៥

◆ គ្រួសារ ស៊ុំ សាន........................................................ ១៦

◆ ជនជាតិមិល................................................................១៩

◆ សង្ឃឹមថាមានយុត្តិធម៌................................................ ២២

**ផ្នែកច្បាប់**

◆ តាំង គីមៈ ការឆ្លើយតបទៅនឹងការរំលោភផ្លូវភេទ................ ២៤

**វេទិកាពិភាក្សាសាធារណៈ**

◆ វ៉ាន់ដាៈ តើមានសង្ឃឹមសម្រាប់ប្រទេសនេះទេ? ......................៣៣

◆ ការអប់រំអំពីសន្តិភាព.....................................................៤៤

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ សមរភូមិក្រោយនៃទឹកដីរំដោះ........................................ ៥០

◆ ជីវិតក្នុងភាពនឹងថ្កល់.................................................... ៥២

◆ រកឃើញអ៊ំប្រុសតាមរយៈប្រវត្តិរូប.................................... ៥៩






ស៊ុន សេន


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ:** យិន នាន, ឡុង ដានី, លី សុខឃាង, ដេង ពង្សរ៉ាស៊ី, សារិន វីរៈ, គីម កែវកន្និដ្ឋា, ឃឹម ណារិន, ខេទ្រីណា អាន់ដឺសុន, អាដុង លី **អ្នកនិពន្ធនិងស្រាវជ្រាវ:** លី សុផល, សូហ្វារីណា **អ្នកបកប្រែ:** ជី ទេរិទ្ធិ **និពន្ធនាយករង:** សាន់ កល្យាណ **និពន្ធនាយកខ្ទទេ:** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ:** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ:** មាស ប៊ុនថាន



Email: dccam@online.com.kh, Homepage: www.dccam.org

**សំបុត្រៈ**

# តួនាទីរបស់អាស៊ានរនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញកម្ពុជា

១ភាគ៤នៃចំនួនប្រជាជនសរុបបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាចំនួនប្រជាជនដែលស្លាប់ច្រើនបំផុតប្រសិនបើគិតជាភាគរយប្រៀបធៀបទៅនឹងអំពើប្រល័យពូជសាសន៍ផ្សេងៗទៀតនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប ។ អស់រយៈពេលជាង២៥ឆ្នាំហើយបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានទម្លាក់ពីអំណាច ប៉ុន្តែមិនមានមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យណាម្នាក់ត្រូវបានកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តនៅឡើយទេ ។

ការរំពឹងទុកនិងចម្ងល់របស់ប្រជាជនកម្ពុជាចំពោះអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានរំពឹងទុកថានឹងអាចចាប់ផ្តើមដំណើរការរបស់ខ្លួននៅឆ្នាំ២០០៦ មានភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងចំណោមប្រជាពលរដ្ឋម្នាក់ៗ ។ វាមិនច្បាស់លាស់នោះទេថា ក្តីសង្ឃឹមចង់បានយុត្តិធម៌របស់ប្រជាជនគ្រប់រូបនឹងក្លាយទៅជាការពិត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនឹងផ្តល់ផលប្រយោជន៍ជាក់ស្តែងជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជា ។ ថ្វីត្បិតតែរដ្ឋដែលជាសមាជិករបស់សមាគមអាស៊ានមិនបានរួមវិភាគទានជាថវិការដល់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាក៏ពិតមែន ប៉ុន្តែរដ្ឋទាំងនេះនៅតែមានតួនាទីសំខាន់ដែលនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ ។

ខ្មែរក្រហមបានគ្រប់គ្រងតំបន់ជនបទភាគច្រើនរបស់ប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយមុនពេលសម្រេចបាននូវការកាន់កាប់អំណាចទាំងស្រុងបន្ទាប់ពីដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ កម្ពុជាបានធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិលតាំងពីទសវត្សរ៍ឆ្នាំ១៩៧០មកម្ល៉េះ ដូច្នេះនៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ប្រជាជនបានស្វាគមន៍របបថ្មីយ៉ាងរីករាយដោយសង្ឃឹមថាប្រទេសរបស់ខ្លួននឹងមានសន្តិភាពជាស្ថាពរនិងលែងមានសង្គ្រាមស៊ីវិលរ៉ាំរ៉ៃតទៅទៀតហើយ ។ ដើម្បីអនុវត្តគោលនយោបាយកែប្រែកម្ពុជាឲ្យទៅជាសង្គមកសិកម្មមួយ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ ។ ប្រជាជនប្រមាណជាង៣លាននាក់ត្រូវបានបង្ខំឲ្យទៅរស់នៅនិងបញ្ចេញពលកម្មយ៉ាងធ្ងន់ធ្ងរនៅតាមវាលស្រែចម្ការនៅតាមទីជនបទដាច់ស្រយាល ។

សាលារៀន សាកលវិទ្យាល័យ វត្តអារាម វិហារអ៊ីស្លាម វិហារសាសនាគ្រិស្ត ធនាគារនិងមុខជំនួញជួញដូរទាំងអស់ ត្រូវបានបិទទ្វារលែងឲ្យមានដំណើរការ ។ កម្ពុជាប្រជាធិបតេយ្យដែលជំរុញដោយលទ្ធិម៉ៅនិយមមួយនេះបានលុបបំបាត់ចោលទាំងអស់នូវកម្មសិទ្ធិឯកជន សេរីភាពសាសនា សេរីភាពសារព័ត៌មាន សេរីភាពការបញ្ចេញយោបល់ និងសេរីភាពក្នុងការធ្វើដំណើរទៅកន្លែងផ្សេងៗ ។ នៅពេលដែលប្រជាជនទាំងអស់ត្រូវបានជម្លៀសចេញពីទីក្រុង ការសម្លាប់ផ្តាលដំណាក់កាលដំបូងបានចាប់ផ្តើម ។ ជនទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ (របបលន់ណុល) គឺជាជនទីមួយដែលត្រូវស្លាប់ ។ ជនបន្ទាប់ទៀតដែលជាមុខសញ្ញារបស់ខ្មែរក្រហមរួមមានៈ អ្នកដែលខ្មែរក្រហមសន្មត



ប៉ុល ពត និងគណៈប្រតិភូវៀតណាម

ថាជាភ្នាក់ងារសេ.អ៊ី.អារបស់អាមេរិក កា.ហ្សេ.បេរបស់រុស្ស៊ី និងគិញរបស់វៀតណាម ។ ក្រោយមកទៀត កម្ពុជាប្រជាធិប-តេយ្យបានងាកត្រឡប់មករកខ្លួនឯងវិញដោយមើលឃើញថាខ្មាំងមាននៅគ្រប់ទីកន្លែងទាំងអស់ក្នុងក្រុមនិងក្នុងជួរថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យខ្លួនឯង ហើយរបបនេះបានចាប់ផ្តើមសម្លាប់សមាជិករបស់ខ្លួនអស់ជាច្រើននាក់ ។

បក្សកុម្មុយនិស្តកម្ពុជាត្រូវតែទទួលខុសត្រូវដោយផ្ទាល់ឬដោយប្រយោលចំពោះការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាប្រមាណ២លាននាក់ ដោយសារកង្វះខាតអាហារបរិភោគ ជំងឺដែលមិនបានទទួលការព្យាបាល ការធ្វើការងារហួសកម្លាំង និងការសម្លាប់រង្គាល ។ រដ្ឋាភិបាលរបស់ប្រទេសជាច្រើនក៏បានសម្លាប់ប្រជាពលរដ្ឋខ្លួនឯងដូចរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យដែរ ប៉ុន្តែមិនមានរដ្ឋាភិបាលណាមួយដែលធ្វើឲ្យបាត់បង់ជីវិតប្រជាពលរដ្ឋខ្លួនឯងមានចំនួនច្រើនដូចរបបកម្ពុជាប្រជាធិបតេយ្យនេះឡើយ ។ ជាក់ស្តែង ណាហ្ស៊ីបានសម្លាប់ប្រជាជនប្រមាណ៦ភាគរយនៅក្នុងទឹកដីខ្លះរបស់អឺរ៉ុបដែលខ្លួនកាន់កាប់ ហើយជនជាតិរ៉្វាន់ដាបានកាប់សម្លាប់ជនជាតិគ្នាឯងប្រមាណ១៤ភាគរយនៃប្រជាជនរ៉្វាន់ដាសរុបប៉ុណ្ណោះនៅក្នុងឆ្នាំ១៩៩៤ ។ ផ្ទុយទៅវិញ កម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យប្រជាជនកម្ពុជាបាត់បង់ជីវិតពី២៥ភាគរយទៅ៣៥ភាគរយនៃចំនួនប្រជាជនកម្ពុជាទាំងអស់នៅសម័យនោះ ។

ទិដ្ឋភាពដ៏គួរឲ្យចាប់អារម្មណ៍ផ្សេងទៀតរបស់ប្រវត្តិសាស្ត្រកម្ពុជាគឺមិនមានសាលាជំនុំជម្រះក្តីដែលអាចជឿជាក់បានណាមួយត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះក្តីមេដឹកនាំនៃរបបនោះឡើយ ។ សមាជិកនៃរដ្ឋាភិបាលណាហ្ស៊ីរបស់អ៊ីត្លែរត្រូវបាននាំយកទៅជំនុំជម្រះទោសនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ ហើយនៅពេលថ្មីៗនេះ សាលាជំនុំជម្រះក្តីអន្តរជាតិជាច្រើនត្រូវបានបង្កើតឡើងនៅក្នុងប្រទេសអតីតយូហ្គោស្លាវី រ៉្វាន់ដា ទីម័រខាងកើត និងនៅកន្លែងផ្សេងៗទៀត ។


គណៈប្រតិភូទីម័រខាងកើត

ចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរំលំក្នុងឆ្នាំ១៩៧៩ ក្រៅពី «ការជំនុំជម្រះក្តីកំបាំងមុខ» មួយដែលបានបង្កើតឡើងនៅឆ្នាំ១៩៧៩ និងករណីមួយចំនួនដែលប្រជាជនបានស្វែងរកយុត្តិធម៌ដោយខ្លួនឯង មិនទាន់មានមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យណាម្នាក់ត្រូវបាននាំទៅជំនុំជម្រះសេចក្តីនៅឡើយទេ ។

នៅក្នុងអំឡុង២៥ឆ្នាំបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានទម្លាក់ពីអំណាច មេដឹកនាំខ្លះនៃរបបនោះបានស្លាប់បាត់បង់ជីវិតជាបណ្តើរៗដែលក្នុងនោះមាន ប៉ុល ពត ដែលស្លាប់ដោយសារជំងឺគ្រុនចាញ់នៅក្នុងព្រៃកាលឆ្នាំ១៩៩៨ និងកែ ពក សមាជិកមជ្ឈិមបក្សបានដេកស្លាប់យ៉ាងស្ងៀមស្ងាត់កាលពីឆ្នាំ២០០២ ។ មានតែកម្មាភិបាលខ្មែរក្រហមតែពីររូបប៉ុណ្ណោះដែលកំពុងជាប់ឃុំឃាំងសព្វថ្ងៃនេះ ។ អ្នកទីមួយគឺ ឌុច អតីតអ្នកគ្រប់គ្រងមន្ទីរឃុំឃាំងទួលស្លែង (ស-២១) ដែលតាមការប៉ាន់ស្មានមានអ្នកទោសប្រមាណជាង១ម៉ឺន៤ពាន់នាក់បានស្លាប់ ហើយមានអ្នកទោសតែប្រមាណ១២នាក់ប៉ុណ្ណោះដែលបានរួចជីវិត ។ ចំណែកឯអ្នកទីពីរគឺ តាម៉ុក ដែលជាមេបញ្ជាការភូមិភាគនិរតីនិងជាសមាជិកមជ្ឈិមបក្ស ។ តាម៉ុក ត្រូវបានឃុំឃាំងដោយសារមូលហេតុបដិសេធមិនព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាកាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ។ រហូតមកដល់ពេលនេះ មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់មានអាយុច្រើនណាស់ហើយ ហើយភាគច្រើនមានអាយុលើសពី៧០ឆ្នាំ ។

### លទ្ធផលដែលរំពឹងទុករបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

កាលពីខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីទាំងពីរ គឺសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ «ដើម្បីនាំជនទាំងឡាយដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាន់តុលាការ ។ បន្ទាប់ពីការចរចាអស់រយៈពេល៧ឆ្នាំ កាលពីខែតុលា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានឈានដល់ការផ្តល់សច្ចាប័នដល់ «កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» និងវិសោធនកម្មច្បាប់ស្តីអំពី «ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ។ ជាមួយនឹងចំណាត់ការទាំងនេះ លទ្ធភាពបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាសម្រាប់ជំនុំជម្រះសេចក្តីមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យជិតបានសម្រេចហើយ ។

កម្ពុជានិងអង្គការសហប្រជាជាតិស្ទើរតែបញ្ចប់ជំហានបន្ទាប់របស់ខ្លួនក្នុងការប្រមូលថវិកាសម្រាប់រៀបចំបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ អង្គការសហប្រជាជាតិប្រមូលថវិកាបានជាង៤១លានដុល្លារនៃថវិកាចំនួន៤៣លានដុល្លារដែលជាចំណែកទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាជាអ្នកទទួលខុសត្រូវលើចំណែកថវិកាចំនួនជាង១៣លានដុល្លារជាសាច់ប្រាក់និងការចំណាយផ្សេងៗ ។ ប៉ុន្តែ កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា ខ្លួនអាចរួមវិភាគទានជាទឹកប្រាក់បានត្រឹមតែ១,៥លានដុល្លារប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវសុំឲ្យប្រទេសជប៉ុន (ដែលជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនដែលបានស្នើសុំសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិបង្កើតសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម) ជួយឧបត្ថម្ភចំពោះកង្វះខាតរបស់ខ្លួន ហើយប្រទេសជប៉ុនបានអនុញ្ញាតឲ្យរាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់គណនីធនាគារដែលជប៉ុនបានបង្កើតកាលពីប៉ុន្មានឆ្នាំមុនដើម្បីបំពេញបន្ថែមនូវចំនួនថវិកាដែលរដ្ឋាភិបាលខ្វះខាតសម្រាប់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។


តាម៉ុក និងមិត្តភក្តិចិន

គ្មាននរណាម្នាក់ដឹងច្បាស់ជាមុនទេថាតើអតីតមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យប៉ុន្មាននាក់ដែលនឹងត្រូវទទួលការជំនុំជម្រះពីអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ បើប្រៀបធៀបនឹងសាលាជំនុំជម្រះក្តីអន្តរជាតិផ្សេងទៀត ថវិកាសម្រាប់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាគឺជាចំនួនថវិកាតិចតួចបំផុត ។ ដូច្នេះជាមួយនឹងថវិកាដ៏តិចតួចនេះ អតីតមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមួយចំនួនតូចតែប៉ុណ្ណោះដែលនឹងត្រូវកាត់សេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញ ។

គ្មាននរណាម្នាក់ហ៊ានប៉ាន់ស្មានជាមុនអំពីលទ្ធផលរបស់អង្គជំនុំជម្រះវិសាមញ្ញនេះទេ ។ សាធារណជនមានការរំពឹងទុកខុសៗគ្នាចំពោះលទ្ធផលនេះ ។ ជាគោលការណ៍ អតីតមេដឹកនាំខ្មែរក្រហមអាចនឹងត្រូវជំនុំជម្រះទោសពីបទឧក្រិដ្ឋមួយចំនួននៅក្រោមច្បាប់អន្តរជាតិដូចជាៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ។ អតីតមេដឹកនាំខ្មែរក្រហមទាំងនេះក៏នឹងត្រូវនាំយកទៅជំនុំជម្រះសេចក្តីពីបទឧក្រិដ្ឋមួយចំនួននៅក្រោមច្បាប់កម្ពុជានិងនៅក្រោមច្បាប់របស់រដ្ឋផ្សេងទៀត ។ បទល្មើសពិតប្រាកដដែលត្រូវចោទប្រកាន់ទៅលើមេដឹកនាំខ្មែរក្រហមទាំងនោះគឺស្ថិតនៅលើការសម្រេចរបស់ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ប្រជាជនកម្ពុជាខ្លះចង់ឃើញអតីតមេដឹកនាំទាំងនោះយកជីវិតរបស់ខ្លួនមកទូទាត់ជាមួយនឹងក្រិដ្ឋកម្មដែលអ្នកទាំងនោះបានប្រព្រឹត្ត ប៉ុន្តែកម្ពុជាមិនមានទោសប្រហារជីវិតទេ (អង្គការសហប្រជាជាតិបានធ្វើយុទ្ធនាការប្រឆាំងនឹងទោសប្រហារជីវិតអស់រយៈពេលរាប់ទសវត្សរ៍មកហើយ) ។ ប្រជាជនកម្ពុជាមួយចំនួនតូចបានប្រកាន់យកនូវគោលជំហរតឹងរ៉ឹងបែបព្រះពុទ្ធសាសនា ហើយបានគាំទ្រឲ្យមានការអត់ឱននិងអភ័យទោស ។ ក៏ប៉ុន្តែ មានមនុស្សមួយចំនួនទៀតជាពិសេសអ្នកនយោបាយបានថ្លែងថា មិនគួរបង្កើតឲ្យមានសាលាជំនុំជម្រះក្តីទាល់តែសោះ ដោយសារតែប្រជាជនកម្ពុជាបានផ្សះផ្សាគ្នារួចហើយ ។ អ្នកទាំងនេះព្រួយបារម្ភខ្លាចសាលាជំនុំជម្រះក្តីនេះនឹងរំពុកឡើងវិញនូវអតីតកាលរបស់ខ្លួនដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហម ។ ប្រជាជនកម្ពុជាភាគច្រើនចង់ឃើញ«អ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍» ទាំងនោះរស់នៅក្នុងមន្ទីរឃុំឃាំង ។ ប៉ុន្តែ ជនសង្ស័យទាំងអស់មិនមែនសុទ្ធតែត្រូវបាននាំយកទៅជំនុំជម្រះសេចក្តីនៅចំពោះមុខច្បាប់នោះទេ ដោយសារមូលហេតុច្បាប់ កង្វះខាតថវិកា និងបញ្ហាផ្សេងៗទៀត ។ ផ្ទុយទៅវិញ មានតែបទចោទប្រកាន់និងសំណុំរឿងមួយចំនួនប៉ុណ្ណោះដែលនឹងត្រូវដោះស្រាយជាមួយអតីតមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

បើពិនិត្យមើលទៅលើអាយុរបស់បេក្ខជនសម្រាប់ការកាត់សេចក្តីនិងលទ្ធភាពដែលថាការជំនុំជម្រះក្តីនោះអាចអូសបន្លាយពេលជាច្រើនឆ្នាំដោយសារមានបណ្តឹងសារទុក្ខ និងភាពសាំញ៉ាំនៃប្រព័ន្ធច្បាប់កម្ពុជា វាមិនទំនងនោះទេដែលថា ប្រជាជនកម្ពុជាភាគច្រើននឹងទទួលបានយុត្តិធម៌ដ៏ត្រឹមត្រូវដូចការរំពឹងទុករបស់ខ្លួន ។

ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជានឹងផ្តល់ផលប្រយោជន៍សំខាន់ៗចំនួនបីសម្រាប់ប្រទេសកម្ពុជា ។ ទីមួយៈ អង្គជំនុំជម្រះវិសាមញ្ញនេះអាចផ្តល់ជាវេទិកាសម្រាប់ឆ្លើយសំណួរដែលជាចម្ងល់របស់ប្រជាពលរដ្ឋនិងចំពោះប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។ ទីពីរៈ អង្គជំនុំជម្រះវិសាមញ្ញនេះអាចបង្កើតជាការពិភាក្សានៅក្នុងចំណោមប្រជាជនកម្ពុជាអំពីប្រសិទ្ធភាពរបស់ប្រព័ន្ធច្បាប់និងកម្រិតអភិវឌ្ឍរបស់ប្រព័ន្ធយុត្តិធម៌របស់ប្រទេសខ្លួន ។ ទីបីៈ តែមួយជំនាន់មនុស្សប៉ុណ្ណោះបន្ទាប់ពីអំពើប្រល័យពូជសាសន៍ ប្រជាជនកម្ពុជាដែលមានវ័យក្មេងៗមិនជឿថាឪពុកម្តាយរបស់ខ្លួនជួបប្រទះនូវទុក្ខលំបាកវេទនានៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញនឹងជួយឲ្យការចងចាំអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាមានជីវិតជានិច្ច ព្រមទាំងជំរុញឲ្យប្រជាជនកម្ពុជាការពារមិនឲ្យអំពើនោះកើតឡើងសាជាថ្មីម្តងទៀត ។ ទោះបីជាលទ្ធផលដែលទទួលបានមកយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញនេះមានសារសំខាន់ណាស់សម្រាប់អនាគតរបស់កម្ពុជា ។




មជ្ឈមណ្ឌលឯកសារកម្ពុជា អង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀតដែលធ្វើការផ្សារផ្នែកច្បាប់និងសិទ្ធិមនុស្ស ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជា កំពុងតែប្រឹងប្រែងជួយឲ្យប្រជាជនកម្ពុជាយល់ដឹងនិងដកស្រង់បទពិសោធន៍ពីអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ជាក់ស្តែងរដ្ឋាភិបាលបានបោះពុម្ពសៀវភៅមួយដើម្បីអប់រំដល់សាធារណជនអំពីអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងថ្មីមួយ ហើយគម្រោងនេះនឹងអញ្ជើញមនុស្សដែលមានវ័យចំណាស់និងជាទីគោរពរបស់ប្រជាជននៅក្នុងភូមិនានាទូទាំងប្រទេសឲ្យចូលរួមក្នុងសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងរយៈពេលមួយសប្តាហ៍ ។ នៅពេលវិលត្រឡប់ទៅកាន់ភូមិរៀងៗ



អៀង សារី

ខ្លួនវិញ  អ្នកទាំងនេះនឹងយកបទពិសោធន៍របស់ខ្លួនដែលបានចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញទៅពិភាក្សាជាមួយអ្នកភូមិដទៃទៀត ។ ការជួបប្រជុំពិភាក្សាគ្នារបស់អ្នកភូមិនឹងត្រូវថតជាឯកសារ ហើយឯកសារនេះនឹងត្រូវយកទៅបញ្ចាំងនៅក្នុងភូមិផ្សេងៗទៀតនៅទូទាំងប្រទេសដើម្បីជំរុញឲ្យមានការពិភាក្សាស្រដៀងគ្នានេះបន្ថែមទៀត ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងជួយឲ្យប្រជាជនកម្ពុជាចូលរួមដោយប្រយោលនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ  ព្រមទាំងយល់ដឹងបានច្រើនជាងមុនអំពីការងាររបស់រាជរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តរជាតិ ។

### ការចូលរួមរបស់អាស៊ាន

រដ្ឋាភិបាលប្រទេសអាស៊ីខ្លះនៅតែមើលឃើញថា  បញ្ហាសិទ្ធិមនុស្សជាបញ្ហារបស់ប្រទេសលោកខាងលិច ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍មកនេះប្រជាជននៅក្នុងប្រទេសអាស៊ីជាច្រើនបានបញ្ចេញយោបល់របស់ខ្លួនថា  បញ្ហាសិទ្ធិមនុស្សមានចរិតជាសកល និងថា នីតិរដ្ឋ និងការអនុវត្តច្បាប់ត្រឹមត្រូវគឺជាធាតុសំខាន់បំផុតរបស់លទ្ធិប្រជាធិបតេយ្យ ។  នៅពេលដែលប្រទេសនៅអាស៊ី ជាពិសេសប្រទេសដែលជាសមាជិករបស់សមាគមអាស៊ាន កំពុងតែមានតួនាទីសំខាន់ជាងមុននៅក្នុងឆាកនយោបាយនិងសេដ្ឋកិច្ចអន្តរជាតិ វាមានសារសំខាន់ណាស់ដែលថាកាយវិការរបស់ប្រទេសទាំងនោះឆ្លុះបញ្ចាំងអំពីការរីកចម្រើននៅក្នុងទ្វីបអាស៊ី ។

នៅពេលដែលមិនទាន់មានរដ្ឋសមាជិករបស់សមាគមអាស៊ានជួយឧបត្ថម្ភថវិកាដល់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាក៏នៅមានមធ្យោបាយផ្សេងទៀតដែលមានតម្លៃស្មើគ្នានឹងការឧបត្ថម្ភថវិកានេះដែរដែលរដ្ឋទាំងនោះអាចជួយកម្ពុជាក្នុងកិច្ចការស្វែងរកយុត្តិធម៌ ។  ដោយមានភាពស្រដៀងគ្នាផ្នែកវប្បធម៌និងប្រវត្តិសាស្ត្រ រដ្ឋសមាជិកសមាគមអាស៊ានមានការយល់ដឹងយ៉ាងប្រសើរអំពីរបៀបដោះស្រាយបញ្ហានៅក្នុងប្រទេសអាស៊ានដូចគ្នា ។  ប្រទេសដែលជាសមាជិករបស់សមាគមអាស៊ានទាំងនេះជាប្រទេសដែលស័ក្តិសមបំផុតសម្រាប់ជួយដល់កម្ពុជានៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។

មធ្យោបាយមួយចំនួនទៀតដែលប្រទេសសមាជិកអាស៊ានអាចចូលរួមជាមួយកម្ពុជានៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាគឺៈ

**១) ជំនួយបច្ចេកទេសៈ** ប្រទេសផ្សេងៗដូចជាសិង្ហបុរីជាដើម  មានអ្នកបច្ចេកទេសដែលមានចំណេះដឹងខ្ពស់ដែលអាចជួយកំណត់រកនិងគាស់រណ្តៅសាកសពរួមជាង១ម៉ឺន៩ពាន់រណ្តៅនៅទូទាំងប្រទេស ។  បើប្រៀបធៀបទៅនឹងប្រទេសលោកខាងលិច  សិង្ហបុរីអាចបញ្ជូនអ្នកឯកទេសដ៏មានប្រសិទ្ធភាពក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញដោយអាចផ្តល់នូវភ័ស្តុតាងកោសល្យវិច័យដ៏មានសារសំខាន់ ។

**២) ឯកសារៈ** ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ញើសំបុត្រទៅតំណាងជាច្រើនរបស់សមាគមអាស៊ាននិងប្រទេសផ្សេងៗទៀតចំនួន៤៣ប្រទេស  ដោយសង្ឃឹមថា  រដ្ឋាភិបាល រាជទូតឬរដ្ឋទូត  សាកលវិទ្យាល័យ  និងរូបវន្តបុគ្គលទាំងឡាយនឹងផ្តល់ដល់ប្រទេសកម្ពុជានូវឯកសារ  រូបថត  និងសម្ភារផ្លូវការពាក់ព័ន្ធផ្សេងទៀត  ដែលអាចប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឬអាចជួយប្រជាជនកម្ពុជាឲ្យយល់ច្បាស់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។

**៣) ការផ្តល់ប្រឹក្សាៈ** អ្នកដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យប្រមាណជា២លាននាក់ត្រូវបានវាយតម្លៃថាមានជំងឺបាក់ស្បាត  ហើយបច្ចុប្បន្ននេះប្រទេសកម្ពុជាមានចិត្តវិទូតែ១២នាក់ប៉ុណ្ណោះដែលអាចព្យាបាលជំងឺប្រភេទនេះបាន ។  នៅក្នុងគម្រោងមួយសហការជាមួយអង្គការអន្តរវប្បធម៌

ចិត្តសង្គម មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញថា ការព្យាបាលតាមវិធីសាមញ្ញដូចជាលំហាត់ដកដង្ហើម ឬការតាំងសមាធិ ត្រូវការពេលវេលាយ៉ាងយូរដើម្បីអាចជួយអ្នកដែលឆាប់ខឹង អ្នកដែលមានជំងឺដេកមិនលក់ និងអ្នកដែលមានរោគសញ្ញាផ្សេងៗទៀតនៃជំងឺបាក់ស្បាត ឲ្យជាសះស្បើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានរកឃើញទៀតថា មធ្យោបាយព្យាបាលរបស់លោកខាងលិច ដូចជាការព្យាបាលជាក្រុមជាដើម គឺមិនមែនជាវិធីព្យាបាលដ៏មានប្រសិទ្ធភាពនៅកម្ពុជានោះទេ ។ ដោយសារតែប្រជាជនអាស៊ីយល់ច្បាស់អំពីផ្លូវចិត្តរបស់ជនជាតិអាស៊ីដូចគ្នា អ្នកផ្តល់ប្រឹក្សាពីបណ្តាប្រទេសរបស់សមាជិកសមាគមអាស៊ាន អាចជាជំនួយដ៏មានតម្លៃចំពោះសហគមន៍កម្ពុជាតាមរយៈការផ្តល់ប្រឹក្សាដល់ជនរងគ្រោះក៏ដូចជាដល់ជនដៃដល់នៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ។

***៤) សម្ភារៈ*** ការឧបត្ថម្ភខ្វះរបស់រដ្ឋាភិបាលកម្ពុជាចំពោះអង្គជំនុំជម្រះវិសាមញ្ញគឺជាសម្ភារ ។ ការផ្គត់ផ្គង់កុំព្យូទ័រថ្មីដល់បុគ្គលិករដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬឧបត្ថម្ភដល់ថ្នាក់រៀនប្រវត្តិសាស្ត្រឬថ្នាក់រៀនវិទ្យាសាស្ត្រនយោបាយ នៅតាមសាកលវិទ្យាល័យ ក៏ជាការឧបត្ថម្ភដ៏មានសារសំខាន់ ។

***៥) ការដឹកជញ្ជូនៈ*** ការធ្វើដំណើរអាចជាបញ្ហាចម្បងចំពោះប្រជាពលរដ្ឋនៅតាមទីជនបទ ដោយសារថាត្រូវចំណាយពេលវេលានិងថវិកាអស់ច្រើនដើម្បីចូលរួមក្នុងសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ដូច្នេះការឧបត្ថម្ភជារថយន្តសម្រាប់ដឹកជញ្ជូនប្រជាពលរដ្ឋពីជនបទទៅកាន់ទីក្រុងគឺជាមធ្យោបាយមួយដ៏ល្អ អនុញ្ញាតឲ្យប្រជាជនចូលរួមដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅកម្ពុជា ។

***៦) អ្នកស្ម័គ្រចិត្តៈ*** មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែធ្វើការជាមួយនិស្សិតស្ម័គ្រចិត្តមួយក្រុមដែលមានសមាជិក ២០០នាក់មកពីទូទាំងប្រទេស ។ អ្នកស្ម័គ្រចិត្តទាំងនេះនឹងផ្តល់ព័ត៌មានដល់មូលដ្ឋានរបស់ប្រជាពលរដ្ឋនៅគ្រប់ខេត្តក្រុងទាំងអស់នៅទូទាំងប្រទេសកម្ពុជាមុនពេលអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើង ។ ក្រុមនិស្សិតស្ម័គ្រចិត្តទាំងអស់នឹងជួយពន្យល់ប្រជាពលរដ្ឋឲ្យយល់ដឹងពីអ្វីដែលជាការរំពឹងទុកថាជាលទ្ធផលរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ សកម្មភាពនេះមិនត្រឹមតែផ្តល់ការយល់ដឹងច្បាស់លាស់ជាងមុនអំពីសាលាជំនុំជម្រះក្តីប៉ុណ្ណោះទេ ថែមទាំងជួយកសាងអនាគតរបស់ប្រជាពលរដ្ឋដែលចូលរួមក្នុងសហគមន៍របស់ខ្លួនទៀតផង ។ និស្សិតកម្ពុជានឹងទទួលបាននូវអត្ថប្រយោជន៍តាមរយៈការចូលរួមជាមួយនិស្សិតមកពីទូទាំងរដ្ឋសមាជិករបស់អាស៊ាន ហើយនិស្សិតបរទេសទាំងនេះនឹងជួយពង្រីកចំណេះដឹងនិស្សិតកម្ពុជាអំពីនយោបាយ ប្រវត្តិសាស្ត្រតំបន់ និងមធ្យោបាយដោះស្រាយបញ្ហា ។

***៧) វិទ្យុៈ*** ការឧបត្ថម្ភជាវិទ្យុគឺមានសារសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ។ នៅក្នុងប្រទេសមួយដែលរកប្រាក់ចំណូលបានជាមធ្យមប្រហែល១ដុល្លារអាមេរិកក្នុងមួយថ្ងៃ អ្នកភូមិតិចណាស់ដែលមានលទ្ធភាពទិញកាសែតអានឬទិញទូរទស្សន៍មើល ។ វិទ្យុជាមធ្យោបាយដែលប្រជាជនកម្ពុជាជាទូទៅប្រើប្រាស់ដើម្បីរៀនសូត្រ ។ ប្រជាជនភាគច្រើនប្រមូលផ្តុំគ្នាស្តាប់វិទ្យុនិងពិភាក្សាគ្នាអំពីព័ត៌មានដែលគាត់ទទួលបាន ។ ការឧបត្ថម្ភវិទ្យុថ្មីឬចាស់គឺពិតជាមានតម្លៃក្នុងការជួយប្រជាជនកម្ពុជាឲ្យយល់ដឹងអំពីព្រឹត្តិការណ៍វិវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ប្រជាជនកម្ពុជាសង្ឃឹមថា រដ្ឋសមាជិករបស់សមាគមអាស៊ាននឹងផ្តល់ការគាំទ្រដល់ការគោរពសិទ្ធិមនុស្សនៅអាស៊ីតាមរយៈការផ្តល់ជំនួយដល់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

**ឆាំង យុ**



គណៈប្រតិភូឡាវធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# គ្រិន លាន

គ្រិន លាន គឺជានិស្សិតសាលាបច្ចេកទេសនៅប្រទេសរុស្ស៊ីកាលពីសម័យសង្គមរាស្ត្រនិយម ។ នៅក្នុងឆ្នាំ១៩៧៣ លាន បានត្រឡប់មកប្រទេសកម្ពុជាវិញនិងធ្វើការនៅមន្ទីរស-៩១ របស់អង្គការរហូតដល់ខែឧសភា ឆ្នាំ១៩៧៥ ត្រូវអង្គការបញ្ជូនមកឲ្យធ្វើការនៅក្រសួងការបរទេសភ្នំពេញ ។ ក្រោយមកទៀតគាត់ត្រូវបញ្ជូនឲ្យទៅធ្វើការនៅសាលាបច្ចេកទេសឬស្សីកែវភ្នំពេញ ។ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ លាន ត្រូវអង្គការចាប់ខ្លួននិងសម្លាប់ចោលនៅមន្ទីរស-២១ ។

### មូលហេតុនាំឲ្យ លាន មានចំណូលចិត្តខាងនយោបាយ

គ្រិន លាន ហៅ សំ មានស្រុកកំណើតនៅភូមិកៀនជ្រៃ ឃុំកៀនជ្រៃ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ លាន បានចាប់ផ្តើមទទួលការអប់រំខាងនយោបាយពីគ្រូបង្រៀនមុខវិជ្ជាគាត់តាំងពីរៀននៅថ្នាក់ទី៩ គឺឆ្នាំ១៩៥៣ ។ នៅពេលមកសិក្សានៅវិទ្យាល័យកំពង់ចាម លាន បានទទួលឥទ្ធិពលនយោបាយពីគ្រូៗដទៃអំពីការឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជានិងការគំរាមកំហែងរបស់ថៃនិងអាមេរិកមកលើប្រទេសកម្ពុជា ។ នៅឆ្នាំ១៩៦២ លាន បានចូលរៀននៅសាលាគរុកោសល្យ ។ សាស្ត្រាចារ្យមុខវិជ្ជាអក្សរសាស្ត្រខ្មែរម្នាក់ឈ្មោះ កុយ ធួន តែងតែរិះគន់ពីអំពើស្អាតស្អំនិងអំពើពុករលួយផ្សេងៗនៅក្នុងសង្គមឲ្យសិស្សស្តាប់នៅរាល់ពេលបង្រៀន ។ ក្រៅពីនេះ លាន បានស្តាប់ព័ត៌មានតាមវិទ្យុជាតិភ្នំពេញនិងបានឮសាស្ត្រាចារ្យមួយចំនួននិយាយអំពីឈ្មោះអ្នកនយោបាយម្នាក់ឈ្មោះ ជួន មុម្ម ដែលកំពុងស្នាក់នៅបរទេស ។ លាន ពេញចិត្តអ្នកនយោបាយរូបនេះណាស់ រហូតដល់ពេលគាត់បានទទួលអាហារូបករណ៍ទៅសិក្សានៅទីក្រុងមូស្គូ គាត់បានជួប ជួន មុម្ម នៅទីនោះហើយក៏បានធ្វើការជាមួយគ្នារហូតដល់ថ្ងៃអង្គការចាប់ខ្លួន ។

### ទំនាក់ទំនងនិងការចាប់ខ្លួន

នៅឆ្នាំ១៩៦៧ លាន បានជួប ជួន មុម្ម តាមរយៈ ហាក់ សៀងឡាយនី ។ ក្រោយពេល លាន ទៅដល់និងចូលសិក្សានៅសាកលវិទ្យាល័យមូស្គូ ប៉ែន ថៅងអាន និង ឡាយនី បានមកលេងគាត់ជាញឹកញាប់ ហើយបានណែនាំគាត់ឲ្យស្គាល់ ជួន មុម្ម ។ លាន ពេញចិត្តអ្នកទាំងពីរណាស់ ដោយសារអ្នកទាំងពីរមានទស្សនៈនយោបាយប្រហាក់ប្រហែលនឹងខ្លួននិងជាអ្នកដឹកនាំសហភាពខេមរនិស្សិតផង ។ លាន បានសម្រេចចិត្តចូលរួមក្នុងសហភាពខេមរនិស្សិត ។ នៅពេលនិស្សិតខ្មែរពីរក្រុមនៅមូស្គូមានទំនាស់គ្នា លាន, ឡាយនី និង ថៅងអាន ចាប់ផ្តើមទាក់ទងអង្គការយុវជនរុស្ស៊ីកាន់តែជិតស្និទ្ធតាមរយៈការផ្តល់សម្ភារផ្សេងៗឲ្យអង្គការនេះ ។

ឆ្នាំ១៩៦៩ លាន បានទាក់ទងនិស្សិតវៀតណាមម្នាក់ឈ្មោះ ប៊ិញ ជាប្រធានសមាគមនិស្សិតវៀតណាមនៅសូវៀតដើម្បីបញ្ចុះបញ្ចូលឲ្យនិស្សិតរូបនេះនាំគាត់ទៅជួបខ្មែរនៅហាណូយដូចជា ស៊ឹង ង៉ុកមិញ ជាដើម ។ លាន បានដឹងថា នៅចុងឆ្នាំនេះ សម្តេច សីហនុ និង លន់ ណុល នឹងជួបគ្នានៅប្រទេសបារាំង ។ លន់ ណុល បានស្នើសុំកងទ័ពបន្ថែមពីសម្តេច សីហនុ ដើម្បីបណ្តេញកងទ័ពយៀកកុងចេញពីព្រំដែនកម្ពុជា ប៉ុន្តែសម្តេច សីហនុ ទ្រង់បានបដិសេធ ។ មិនយូរប៉ុន្មានក្រោយពី លន់ ណុល ត្រឡប់ចូលប្រទេសវិញនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧០ មានការវាយប្រហារស្ថានទូតវៀតណាមនៅកម្ពុជា ។

ថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ព្រឹត្តិការណ៍រដ្ឋប្រហារផ្តួលរំលំឡើងទម្លាក់សម្តេច សីហនុ ពីអំណាចនៅក្នុងខណៈពេលដែលព្រះអង្គយាងទៅធ្វើទស្សនកិច្ចនៅទីក្រុងមូស្គូ ។ សម្តេច សីហនុ បានយាងមកទីក្រុងប៉េកាំងជាបន្ទាន់ ហើយទ្រង់បានប្រកាសបង្កើតរណសិរ្សរួបរួមជាតិមួយនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ។ នៅទីក្រុងមូស្គូឯណោះវិញ គ្រិន លាន, ជួន មុម្ម, ហៃ គឹមស៊ាង, ឆៃ ហេង, ថាច់ សួង, រឿង ម៉ាច, ហេង ពេជ្រ និង ជា ខន បានមកជួបជុំគ្នានៅផ្ទះរបស់ ឡាយនី ដើម្បីពិភាក្សាគ្នារកផ្លូវដោះស្រាយ

សភាពការណ៍ផ្លាស់ប្តូរនេះ ។ ដួន មុម្ម បានសម្រេចបែងចែកកម្លាំងជាពីរក្រុម មួយក្រុមធ្វើការនៅទីក្រុងប៉េកាំងនិងមួយចំនួនទៀតធ្វើការនៅសូវៀត ។ យុទ្ធវិធីដែលត្រូវសម្រុះសម្រួលគ្នាមានបួន៖ ទី១) ផ្សព្វផ្សាយឥទ្ធិពលសូវៀតទៅក្នុងចំណោមជនជាតិកម្ពុជាដែលជាសមាជិករណសិរ្សនៅប៉េកាំងនិងនៅប្រទេសដទៃ ទី២) ក្តាប់សភាពការណ៍នយោបាយ នៅក្នុងរណសិរ្សដើម្បីផ្តល់ព័ត៌មានទៅឲ្យសូវៀតនៅប៉េកាំងតាមរយៈឈ្មោះ យូរី និង វ៉ាស៊ីលីលេខាស្ថានទូតរុស្ស៊ី ទី៣) ក្តាប់ប្រវត្តិរូបអ្នកដឹកនាំតាំងពីសមាជិករណសិរ្សរហូតដល់ថ្នាក់រដ្ឋមន្ត្រី និងទី៤) ក្តាប់សភាពការណ៍យោធានៅសមរភូមិមុខ តើខាងណាខ្លាំងខាងណាខ្សោយ ។ នៅយប់ថ្ងៃទី២៥ ខែមីនា ដួន មុម្ម និង ឡាយនី បានធ្វើដំណើរទៅទីក្រុងប៉េកាំង ។ នៅថ្ងៃទី១៧ ខែឧសភា លាន បានទៅដល់ប៉េកាំងដែរ ។

ពេលទៅដល់ប៉េកាំងភ្លាម លាន ត្រូវបានចាត់តាំងឲ្យធ្វើការជាមួយ ប៉ែន នុត ។ ពេលធ្វើការជាមួយ ប៉ែន នុត, លាន តែងតែនិយាយលើកសរសើរអំពីមហាអំណាចរបស់សូវៀតក្នុងការដោះស្រាយបញ្ហាផ្សេងៗនៅក្នុងសកលលោក ។ លាន បានអនុវត្តផែនការនេះផ្សព្វផ្សាយឥទ្ធិពលសូវៀតក្នុងចំណោមខ្មែរទាំងអស់ដែលរស់នៅប៉េកាំងនិងនិស្សិតខ្មែរដែលមកពីប្រទេសផ្សេងៗ ។ លាន អូសទាញបានសាស្ត្រាចារ្យម្នាក់ឈ្មោះ កិន អួន ដែលមកពីប្រទេសបារាំង ។

ចុងឆ្នាំ១៩៧០ រដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានសម្រេចដាក់ទូតនៅតាមបណ្តាប្រទេសមួយចំនួនដែលបានទទួលស្គាល់រដ្ឋាភិបាលនេះមុនគេ មានប្រទេសយូហ្គោស្លាវី គុយបា និងអាល់ហ្សេរី ។

ដើមឆ្នាំ១៩៧១ ឡុង នរិន្ទ ដែលមកពីប្រទេសឆេកូស្លូវ៉ាគីត្រូវបាន ឡាយនី ចាត់តាំងឲ្យធ្វើខាងពិធីការនៅក្រសួងការបរទេស ។ នៅខែកក្កដា អៀង សារី បានមកដល់ប៉េកាំងនិងជួបសំណេះសំណាលជាមួយសមាជិករណសិរ្សទាំងអស់ដែលនឹងត្រូវចូលរួមក្នុងការតស៊ូនៅក្នុងប្រទេសកម្ពុជា ។ ចុងឆ្នាំនោះ លាន និង ដួន ប្រាសិទ្ធ បានទៅចូលរួមសន្និសីទនៅទីក្រុងប៉ារីស ។

ខែ១២ ឆ្នាំ១៩៧២ អៀង សារី បានប្រាប់ថា អង្គការអនុញ្ញាតឲ្យនិស្សិតខ្មែរ៧រូបចូលក្នុងប្រទេសកម្ពុជា ក្នុងនោះមាន គ្រិន លាន, ឃិន ពុំមិកា, ឡុង នរិន្ទ, ឃឹម ណូលីស, សាធ, ប៉ុច មគ្គបូរី និង កុល ដូរិទ្ធី ។ បន្ទាប់ពីទទួលបានដំណឹងនេះ លាន ប្រញាប់ប្រញាល់មកជួប ឡាយនី និង ដួន មុម្ម ដើម្បីរៀបចំផែនការថ្មីសម្រាប់យកទៅអនុវត្តនៅក្នុងប្រទេស ។ ផែនការទីមួយសម្រាប់ពេលមានសង្គ្រាមគឺ ផ្សព្វផ្សាយឥទ្ធិពលរបស់រុស្ស៊ីក្នុងចំណោមប្រជាជន ក្តាប់គោលជំហរអ្នកនយោបាយនៅក្នុងប្រទេសនិងសភាពការណ៍នយោបាយនៅក្នុងចំណោមប្រជាជនយុទ្ធជន និងយោធា ។ ផែនការទីពីរក្រោយពេលសង្គ្រាមចប់គឺកសាងកម្លាំងនៅតាមកន្លែងធ្វើការនិងកសាងអត្តភាពរបស់ខ្លួនឲ្យបានកាន់តែខ្ពស់ដើម្បីកាន់កាប់ក្បាលម៉ាស៊ីន និងបង្វែរមាគ៌ាទៅតាមលទ្ធិសេរីនិយម ។

ថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៣ លាន បានចេញដំណើរពីប៉េកាំងមកប្រទេសកម្ពុជាជាមួយ អៀង សារី ដោយឆ្លងកាត់ទីក្រុងហាណូយ ។

លាន បានមកដល់មន្ទីរស-៩១របស់អង្គការនៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៣ ហើយស្នាក់នៅទីនោះរហូតដល់ខែឧសភាទើបអង្គការបញ្ជូនគាត់ទៅធ្វើការនៅមូលដ្ឋាន ។ ក្នុងរយៈពេលស្នាក់អាស្រ័យនៅមន្ទីស-៩១ លាន បានចាប់ផ្តើមសាបព្រោះឥទ្ធិពលសូវៀតដល់យុទ្ធជននៅទីនោះអំពីការរីកចម្រើនខាងបច្ចេកទេសនិងគ្រឿងសព្វាវុធ និងជីវភាពបែបទំនើបរបស់ប្រទេសនោះ ។ ក្រៅពីនេះ លាន បានតាមដានគ្រប់សកម្មភាពកម្មាភិបាលដែលចេញចូលក្នុងមន្ទីរ ។ លាន បានជួប នួន ជា និង ហ៊ូ យន់ នៅទីនោះ ។ លាន បានប្រគល់សំបុត្រខ្ទេសនាមរបស់ ដួន មុម្ម ទៅឲ្យ ហ៊ូ យន់ ដើម្បីសុំឲ្យគាត់ជួយសម្រួលដល់កិច្ចការរបស់ខ្លួន ។ នៅខែកញ្ញា លាន ចេញទៅធ្វើការនៅចម្ការ ប-១៥ ជាមួយបញ្ញាជនមួយចំនួនដែលមកពីភ្នំពេញ ។ មុនពេលចាកចេញ លាន បានទៅជួប ហ៊ូ យន់ នៅប-១៧ ដើម្បីសួរនាំពីការអនុវត្តផែនការនេះ ។ ហ៊ូយន់ បានឲ្យយោបល់ថា បញ្ហាដែលសំខាន់គឺប្រមូលកម្លាំងឲ្យបានច្រើនតាមទីកន្លែងនិងក្រសួងនានាដែលខ្លួនរស់នៅនិងធ្វើសកម្មភាពទប់ទល់ចលនាសហករណ៍ដែលអង្គការនឹងបង្កើតទូទាំងប្រទេសជាមុនសិន ។ នៅមន្ទីរប-១៥ លានបានធ្វើ

សកម្មភាពដូចនៅមន្ទីរ ស-៩១ ដែរ ។

ខែ៣ ឆ្នាំ១៩៧៤ លាន បានជួប ហ៊ូ យន់ ជាលើកទីបី ។ លើកនេះគាត់បានសុំឲ្យ ហ៊ូ យន់ ជួយបញ្ជូនឯកសារមួយចំនួនទៅឲ្យ ស៊ាន អាន នៅហាណូយ និង ជួន មុម្ម នៅប៉េកាំងផង ។ ឯកសារទាំងនោះគឺជារបាយការណ៍អំពីសកម្មភាពក្នុងការផ្សព្វផ្សាយឥទ្ធិពលសូវៀតសភាពការណ៍នយោបាយនិងនិន្នាការនយោបាយរបស់អ្នកដឹកនាំកម្ពុជា ។

ចុងខែមិថុនា ឆ្នាំ១៩៧៤ នៅមន្ទីរ១៣០ក្បែរប-១៥ លាន បានជួប កុយ ធួន សំណេះសំណាលអំពីសភាការណ៍នៅក្នុងប្រទេសនិងកិច្ចការរបស់ខ្លួនដែលនឹងត្រូវធ្វើបន្ត ។ នៅខែកញ្ញា លាន បានជួប ហ៊ូយន់ នៅ ប-១៥ ដើម្បីរាយការណ៍អំពីសកម្មភាពដែលគាត់បានធ្វើកន្លងមក ។ ចុងឆ្នាំ១៩៧៤ លាន, ឡាយនី និង ប៉ុច មគ្គបុរី បានជួបជុំគ្នានៅមន្ទីរ ប-១៥ ដើម្បីប្រាប់ពីការងាររបស់ខ្លួនម្នាក់ម្តងៗ ។ ពីរថ្ងៃក្រោយ លាន បាននាំ ឡាយនី ទៅជួប អ៊ីង គឹមសេង ដើម្បីឲ្យគាត់ជួយណែនាំ ឡាយនី និង ហ៊ូ យន់ ស្គាល់គ្នា ។ នៅពាក់កណ្តាលខែ៣ ឆ្នាំ១៩៧៥ លាន បានផ្លាស់ទៅធ្វើការនៅតំបន់១០៣ ប៉ុន្តែមិនបានធ្វើសកម្មភាពអ្វីទេ ព្រោះគាត់មានជំងឺគ្រុនចាញ់ ។

នៅចុងខែឧសភា ឆ្នាំ១៩៧៥ លាន បានមកដល់ភ្នំពេញ និងធ្វើការនៅអគ្គភាពរៀបចំផ្ទះឲ្យភ្ញៀវបរទេសជាមួយ លន់ និង សៅ ។ ឈ្មោះទាំងពីរនេះបានអូសទាញ ហេង ពេជ្រ, ឡុង នរិន្ទ ឲ្យមានទំនោរទៅខាងខ្លួន ។ ចំណែក លាន មិនសូវយកចិត្តទុកដាក់នឹងសម្តីរបស់អ្នកទាំងពីរនេះដែរ ព្រោះគិតថាមិនមែនជាបក្ខពួករបស់ខ្លួន ក្រោយមកទើបដឹងថាអ្នកទាំងពីរនេះជាខ្សែរបស់ កុយ ធួន ។ ខែកក្កដា លាន បានចេញពីអគ្គភាពរៀបចំផ្ទះភ្ញៀវមកធ្វើការក្នុងក្រសួងការបរទេស ។ នៅទីនោះ លាន បានជួប ប៉ុច មគ្គបុរី និង សួង ស៊ីគឿន ។ លាន ក៏បានរាយការណ៍ប្រាប់អ្នកទាំងពីរអំពីទំនាក់ទំនងរបស់ខ្លួនកន្លងមកជាមួយ ហ៊ូ យន់, កុយ ធួន និងខ្សែរយៈរបស់គាត់ពីរនាក់ឈ្មោះ លន់ និង សៅ នៅអគ្គភាពរៀបចំផ្ទះ ។ ពេល លាន មកធ្វើការនៅភ្នំពេញគាត់មិនដែលបានជួប ហ៊ូ យន់ ឡើយ ក្រោយមកទើបដឹងថា ហ៊ូ យន់ បាត់ខ្លួនដោយសារមានទំនាស់ជាមួយអង្គការក្នុងរឿងជម្លៀសប្រជាជន ។

នៅក្រសួងការបរទេស លាន បានផ្សព្វផ្សាយឥទ្ធិពលសូវៀតនៅក្នុងចំណោមយុទ្ធជន យុទ្ធនារី កម្មាភិបាល និងតាមដានបានលទ្ធផលមួយចំនួនពីទំនាក់រវាងកម្ពុជា-ចិននិងកម្ពុជា-កូរ៉េ ។

ខែមីនា ឆ្នាំ១៩៧៦ លាន បានផ្លាស់ទៅធ្វើការខាងអាកាសចរណ៍ ។ លាន បានតាមដានឃើញមានអ្នកបច្ចេកទេសចិន កូរ៉េ និងខ្មែរ ធ្វើដំណើរចេញចូលប្រទេសកម្ពុជាមិនចេះដាច់ ។ នៅក្នុងខែនេះអង្គការបានប្រមូលអ្នកតស៊ូខ្មែរមួយចំនួនឲ្យមកធ្វើការនៅក្រសួងការបរទេស ។ ចំណែកអ្នកដែលមានឈ្មោះទៅធ្វើទូតក៏ត្រូវចេញទៅតាមស្ថានទូតផ្សេងៗដែរ ។ ក្រោយពេលអ្នកទាំងអស់នោះចេញផុតអស់ទៅ ឡាយនី, ជួន ប្រាសិទ្ធ, សួង ស៊ីគឿន និង លាន បានជួបជុំគ្នាពិភាក្សាម្តងទៀតអំពីការបាត់ខ្លួនរបស់ ហ៊ូ យន់ ។ ទាំងអស់គ្នាចាត់ទុកការបាត់ខ្លួននេះជាការគំរាមកំហែងដល់ក្រុមរបស់ខ្លួន ដូច្នេះត្រូវផ្អាកសកម្មភាពទាក់ទងជាមួយគ្នាមួយរយៈ ។

ខែមេសា ឆ្នាំ១៩៧៦ លាន បានទទួលដំណឹងថា កុយ ធួន មានទំនាស់ជាមួយអង្គការ ។ ដូច្នេះរាល់ទំនាក់ទំនងជាមួយខ្សែរយៈរបស់ កុយ ធួន ក៏ត្រូវផ្អាកដើម្បីចៀសវាងកុំឲ្យមានការសង្ស័យ ប៉ុន្តែទំនាក់ទំនងនិងការបញ្ជូនឯកសារទៅក្រៅប្រទេសគឺនៅបន្ត ។ ចុងខែឧសភា លាន ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅសាលាបច្ចេកទេសឫស្សីកែវ ។ នៅទីនោះ លាន បានធ្វើសកម្មភាពផ្សព្វផ្សាយដូចនៅកន្លែងមុនៗដែរ ។ លាន បានស្គាល់ឈ្មោះ មី ប៉ុន្តែពុំមានទំនាក់ទំនងអ្វីធំដុំទេ ព្រោះដឹងថា មី ជាខ្សែរបស់ កុយ ធួន ។ ក្រោយមកនៅពេល លាន កំពុងជាប់រវល់រៀបចំឯកសារសម្រាប់បើកវគ្គសិក្សាថ្មីនៅសាលាបច្ចេកទេស គាត់ក៏ត្រូវអង្គការឃាត់ខ្លួននៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ និងត្រូវសួរចម្លើយដោយសមមិត្ត ម៉ាន ពួកទី១០ ។ លាន បានសរសេរចម្លើយសារភាពជាច្រើនលើកច្រើនសា ។ នៅក្នុងចម្លើយរបស់គាត់មានបញ្ជីឈ្មោះអ្នកដែលជាប់ពាក់ព័ន្ធធ្វើសកម្មភាពជាមួយចំនួន២៩រូប ហើយឈ្មោះទាំងអស់នោះក៏ត្រូវអង្គការចាប់ខ្លួនជាបន្តបន្ទាប់ ។

**លី សុផល**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២០៧២ | ចាប ឈុន | មេក្រុម | ជាមពល | ១៥-៣-៧៧ | ៣០-៣-៧៧ |
| ២០៧៣ | ទេព ផល្លា ហៅ ឈុន | យុទ្ធជន | ជាមពល | ៥-២-៧៧ | ៣០-៣-៧៧ |
| ២០៧៤ | ផៀង ប៊ុនខេង ហៅ ខេង | យុទ្ធជន | ជាមពល | ៥-២-៧៧ | ៣០-៣-៧៧ |
| ២០៧៥ | ក្រូច រើង ហៅ រុន | អនុក្រុម | ជាមពល | ១០-៣-៧៧ | ៣០-៣-៧៧ |
| ២០៧៦ | សៅ សារឿន ហៅ វុធ | យុទ្ធជន | ជាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៧៧ | អោក នឹម ហៅ ងឹម | មេក្រុម | ជាមពល | ៨-២-៧៧ | ៣០-៣-៧៧ |
| ២០៧៨ | ប្រាក់ ប៊ុនលី ហៅ ហេង | កម្មករជួសជុល | ជាមពល | ៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៧៩ | អោក ស៊ីមហ៊ីង ហៅ ហេង | អនុក្រុម | ជាមពល | ១០-៣-៧៧ | ៣០-៣-៧៧ |
| ២០៨០ | ស៊ឹម គុន ហៅ នៅ | មេពួក | ជាមពល | ១០-៣-៧៧ | ៣០-៣-៧៧ |
| ២០៨១ | ពេជ សុន ហៅ យ៉េន | មេពួក | ជាមពល | ១០-៣-៧៧ | ៣០-៣-៧៧ |
| ២០៨២ | ស្វាយ ជឿង ហៅ ចេន (ស្រី) | យុទ្ធនារី | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៨៣ | ហង់ ឡូន ហៅ គុន (ស្រី) | មេក្រុម | ជាមពល | ១៥-៣-៧៧ | ៣០-៣-៧៧ |
| ២០៨៤ | ប៉ែន វ៉ាយ (ស្រី) | អនុក្រុម | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៨៥ | ម៉ៅ ទូច ហៅ ខាន់ (ស្រី) | អនុក្រុម | ជាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៨៦ | លាង ខេន ហៅ វ៉ាត (ស្រី) | មេក្រុម | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៨៧ | ភោគ យ៉ាន់ ហៅ ចាន់ (ស្រី) | យុទ្ធនារី | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៨៨ | មិត សួ ហៅ ធី (ស្រី) | មេក្រុម | ជាមពល | ២៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៨៩ | ហង់ យីន ហៅ សាន (ស្រី) | មេក្រុម | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៩០ | សិត ធួក ហៅ សី (ស្រី) | កងហា | ជាមពល | ២២-២-៧៧ | ៣០-៣-៧៧ |
| ២០៩១ | គីម សុក ហៅ ស៊ីន (ស្រី) | កងហា | ជាមពល | ២២-២-៧៧ | ៣០-៣-៧៧ |
| ២០៩២ | វ៉ាន់ លី ហៅ ឡុង (ស្រី) | យុទ្ធនារី | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៩៣ | ថោង ហ៊ី ហៅ សេន (ស្រី) | មេក្រុម | ជាមពល | ២៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៩៤ | ហែម យីម (ស្រី) | មេពួក | ជាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៩៥ | ឈឹម យឿន ហៅ ភឿន (ស្រី) | យុទ្ធនារី | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៩៦ | ឃួន មឿយ (ស្រី) | មេពួក | ជាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៩៧ | ហេង អុន ហៅ អឿន (ស្រី) | យុទ្ធនារី | ជាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៩៨ | ហៀង វ៉ាន (ស្រី) | ពេទ្យ | ជាមពល | ២៣-៣-៧៧ | ៣០-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២០៩៩ | ជុំ វុធ ហៅ លាង (ស្រី) | មេក្រុម | ថាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២១០០ | ឆន សេង ហៅ ភឿន (ស្រី) | មេក្រុម | ថាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២១០១ | ហៀត យ៉ុន ហៅ កេង (ស្រី) | មេក្រុម | ថាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២១០២ | សូ ផៃ ហៅ សែន (ស្រី) | យុទ្ធនារី | ថាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២១០៣ | ឡុង លុន ហៅ ម៉ៃ (ស្រី) | អនុក្រុម | ថាមពល | ១-៣-៧៧ | ៣០-៣-៧៧ |
| ២១០៤ | អ៊ុន ស្រាង ហៅ នាត (ស្រី) | សមាជិកក្រុម | ថាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២១០៥ | ហង់ ម៉ៅ ហៅ វ៉ាន (ស្រី) | មេក្រុម | ថាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២១០៦ | ម៉ែន ធី ហៅ វុធ | កុមារ | ថាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២១០៧ | សូ ដូ ហៅ ផល (ស្រី) | ប្រធានមន្ទីរ | ថាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២១០៨ | អ៊ិន គឹមលី | យុវជន | ស-២១យ | ? | ៣០-៣-៧៧ |
| ២១០៩ | គឹម កយ | យុវជន | ស-២១យ | ? | ៣០-៣-៧៧ |
| ២១១០ | ជុំ រំភើយ ហៅ ដេង | កម្មករថ្មី | សាលាអគ្គិសនី | ១៥-៣-៧៧ | ៦-៤-៧៧ |
| ២១១១ | សុខ សំអ៊ុល | ប្រធានក្រុម | អគ្គិសនីទី១ | ១៥-៣-៧៧ | ៦-៤-៧៧ |
| ២១១២ | យ៉ែម ណាយ៉ា ហៅ យ៉ាន់ | ប្រធានក្រុម | អគ្គិសនីទី១ | ១៥-៣-៧៧ | ៦-៤-៧៧ |
| ២១១៣ | អ៊ុំ ឆន | ប្រធានក្រុម | អគ្គិសនីទី១ | ១៥-៣-៧៧ | ៦-៤-៧៧ |
| ២១១៤ | អែម យ៉ាន់ ហៅ ដេត្ត | កម្មករថ្មី | អគ្គិសនីទី១ | ១៥-៣-៧៧ | ៦-៤-៧៧ |
| ២១១៥ | ហ៊ី ង៉ូវ | សមាជិកផ្នែក | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១១៦ | ភេ ម៉ៅ | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១១៧ | សួស ណូរិន ហៅ រិន | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១១៨ | កែវ សុធី | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១១៩ | ទេព ថៃ | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២០ | សោម ធីតា | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២១ | បេ សួន | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២២ | មាស ពិរោ | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២៣ | ញូង ប៊ុនសៀង | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២៤ | សែត ប៊ុនសឿន | បង្កើនផល | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២៥ | អ៊ុក អាន | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២៦ | ឡុង គង់ | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២៧ | អ៊ូ ស៊ីលេ | បង្កើនផល | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២៨ | កែវ ឈិត | បើកបរ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១២៩ | ហន ថេន | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |

**(នៅមានត)**

# កម្ពុជាប្រជាធិបតេយ្យក្នុងក្រសែភ្នែកគណៈប្រតិភូបរទេស

ថ្វីដ្បិតតែមេដឹកនាំកម្ពុជាប្រជាធិបតេយ្យប្រកាន់នយោបាយតឹងរ៉ឹងចំពោះទំនាក់ទំនងការបរទេសក៏ដោយ ក៏នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅតែមានគណៈប្រតិភូបរទេសមួយចំនួនត្រូវបានអនុញ្ញាតឲ្យមកធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា ។ នៅពេលត្រឡប់ទៅវិញ គណៈប្រតិភូទាំងនោះបានផ្តល់បទសម្ភាសន៍ដល់អ្នកកាសែតបរទេស អំពីការមើលឃើញរបស់ខ្លួនចំពោះកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់ពីដំណើរទស្សនកិច្ចរយៈពេលពីរសប្តាហ៍នៅទីក្រុងភ្នំពេញ អគ្គរាជទូតស៊ុយអែដ ហ្សាំងឡង់ និងដាណឺម៉ាក ប្រចាំនៅទីក្រុងប៉េកាំង បានប្រាប់កាសែត «វ៉ាស៊ីនតោនប៉ុស្តិ៍» ដែលចេញផ្សាយកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៨ថា «ទីក្រុងភ្នំពេញប្រៀបដូចជាទីក្រុងខ្មោចនិងគ្មានការប្រើប្រាស់រូបិយវត្ថុទេ ។ ក្រដាសប្រាក់ស្ថិតនៅរាយប៉ាយតាមដងវិថី បន្ទាប់ពីមេដឹកនាំរបបកុម្មុយនិស្តបានដាក់រំសេវឲ្យផ្ទុះធនាគាររដ្ឋ» ។ ទីក្រុងភ្នំពេញនៅពេលនោះគ្មានលក្ខណៈជារដ្ឋធានីទាល់តែសោះ ដោយសារតែគ្មានសេវាដឹកជញ្ជូននិងសេវាកម្មទូរគមនាគមន៍ ហើយទីក្រុងឬទីរួមខេត្តផ្សេងៗទៀតក៏គ្មានអ្វីខុសប្លែកពីទីក្រុងភ្នំពេញដែរ ។

អ្នកកាសែតជនជាតិយូហ្គោស្លាវីមួយក្រុមត្រូវបានអនុញ្ញាតឲ្យមកធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជារយៈពេលពីរសប្តាហ៍ ។ ដំណើរទស្សនកិច្ចរបស់អ្នកសារពត៌មានទាំងនោះត្រូវបានទទួលស្វាគមន៍ដោយសមមិត្ត ប៉ុល ពត នាយករដ្ឋមន្ត្រីនិងជាប្រមុខបក្សកុម្មុយនិស្តកម្ពុជា ។ បន្ទាប់ពីដំណើរទស្សនកិច្ចនេះ អ្នកកាសែតទាំងនោះបានប្រាប់កាសែត«ញូវយ៉កថែមស៍»ចេញផ្សាយនៅពីថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨ថា កម្ពុជាជាទឹកដីមួយដ៏អន់ថយបំផុត ។ មធ្យោបាយទំនាក់ទំនងគ្នាធ្វើឡើងតាមរយៈការពាំនាំដំណឹងពីភូមិមួយទៅភូមិមួយទៀត ។ អ្នកសារពត៌មានទាំងនោះបាននិយាយទៀតថា ទឹកដីដ៏អន់ថយនេះគ្រប់គ្រងដោយមេដឹកនាំអាថ៌កំបាំងមួយក្រុមដែលប្រជាជនកម្ពុជាខ្លួនឯងភាគច្រើនមិនស្គាល់មេដឹកនាំរបស់ខ្លួនជានរណាផង ។ នាយករដ្ឋមន្ត្រី ប៉ុល ពត បានប្រាប់អ្នកកាសែតជនជាតិយូហ្គោស្លាវីទាំងនោះថា *គោលបំណងចម្បងបំផុតរបស់កម្ពុជាគឺកសាងសង្គមមួយដែលគ្មាននរណាម្នាក់ឥតការងារធ្វើ ។ ប្រជាជនគ្រប់រូបនឹងចូលរួមនៅក្នុងការបង្កបង្កើនផលនិងការពារជាតិ»* ។ ក្រុមអ្នកយកពត៌មានទាំងនោះឆ្ងល់ចំពោះអ្វីដែលមន្ត្រីជាន់ខ្ពស់កម្ពុជាក្នុងនោះមាន ប៉ុល ពត ដែរបាននិយាយថា យុវជនម្នាក់ៗទទួលបានអង្ករប្រមាណ២៧០គីឡូក្រាមជារៀងរាល់ឆ្នាំ ។ កាសែតនោះបានសរសេរថា «ប្រសិនបើពិតមែននោះបរិមាណអង្ករនេះគឺច្រើនប្រហាក់ប្រហែលនឹងបរិមាណអង្ករដែលប្រជាជនកម្ពុជាបរិភោគនៅមុនពេលសង្គ្រាមដែរ» ។



សារិន ឆាក

គណៈប្រតិភូបរទេសត្រូវបាននាំទៅទស្សនកិច្ចតែសហករណ៍គំរូៗប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបាននាំទៅទស្សនាកន្លែងដែលពោរពេញទៅដោយការបង្ខំមនុស្សឲ្យធ្វើការហួសកម្លាំងការប្រហារជីវិតនិងការខ្វះខាតអាហារបរិភោគដែលនាំទៅដល់ការបាត់បង់ជីវិតរបស់ប្រជាជន

ឡើយ ។ គណៈប្រតិភូយូហ្គោស្លាវីទាំងនោះបាននិយាយថា នៅក្នុងតំបន់ដែលខ្លួនបានទៅទស្សនាជាពិសេស នៅក្នុងតំបន់បង្កបង្កើនផលស្រូវនៅភាគខាងត្បូងនៃខេត្តតាកែវហាក់បីដូចជាមិនមានការខ្វះខាតស្បៀងអាហារនោះទេ ។

រេនសុិក ជាអ្នកកាសែតម្នាក់ក្នុងគណៈប្រតិភូនោះបាននិយាយថា បក្សកុម្មុយនិស្តកម្ពុជាផ្តល់ឲ្យប្រជាជនកម្ពុជាម្នាក់ៗនូវសម្លៀកបំពាក់ខ្មៅមួយកំប្លេក្នុងមួយឆ្នាំ ។ ថ្នាក់ដឹកនាំនៃរបបនោះចាប់អារម្មណ៍ខ្លាំងតែក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម ហើយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យផ្សេងទៀតតែបន្តិចបន្តួចប៉ុណ្ណោះ ។ អ្នកកាសែតរូបនោះបានរៀបរាប់ទៀតថា មធ្យោបាយទំនាក់ទំនងនៅក្នុងប្រទេសកម្ពុជាអន់ថយមែនទែន ដោយសារតែគ្មានប្រព័ន្ធទូរគមនាគមន៍សម្រាប់ប្រើប្រាស់នៅក្នុងប្រទេសនិងសម្រាប់ទំនាក់ទំនងជាមួយបរទេសទេ ហើយក៏គ្មានភ្លើងចរាចរណ៍ដែរ ។

វិស័យអប់រំមិនត្រូវបានយកចិត្តទុកដាក់ទាល់តែសោះ ។ ប្រជាជនទាំងក្មេងទាំងចាស់មិនបានចូលសាលារៀនទេ ។ កម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយនាយករដ្ឋមន្ត្រី ប៉ុល ពត ហាក់បីដូចជាដាក់ទិសដៅដើម្បីអភិវឌ្ឍវិស័យកសិកម្មខ្លួនតែទៅលើការកសាងប្រព័ន្ធភ្លឺស្រែនិងកសាងប្រព័ន្ធធារាសាស្ត្រតែប៉ុណ្ណោះ ។ ប្រជាជនគ្រប់រូបត្រូវបញ្ជូនទៅធ្វើការនៅតាមវាលស្រែចម្ការ ជីកប្រឡាយ លើកទំនប់ទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាកជាមួយនឹងរបបអាហារមិនគ្រប់គ្រាន់និងត្រូវរស់នៅក្នុងការព្រួយបារម្ភខ្លាចបាត់បង់ជីវិតជារៀងរាល់ថ្ងៃទៀតផង ។ កាសែតដដែលនោះបានឲ្យដឹងទៀតថាមិនមានការបោះពុម្ពសៀវភៅសិក្សាទេ ហើយមធ្យោបាយសំខាន់បំផុតក្នុងការផ្សព្វផ្សាយពត៌មានឲ្យប្រជាជនបានជ្រួតជ្រាបគឺវិទ្យុជាតិដែលផ្សាយតែពត៌មានវិចារណកថានិងចម្រៀងបដិវត្តន៍តែប៉ុណ្ណោះ ។

**ឌី ខេមរិទ្ធិ**

# វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

- រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរករូបថតជនរងគ្រោះ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ *FM102MHz* ទីក្រុងភ្នំពេញ វិទ្យុ *FM93.25MHz* ខេត្តកំពត វិទ្យុ *FM99MHz* ខេត្តព្រះវិហារ និងវិទ្យុ*FM* ១០៣.២៥*MHz* ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះ យើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួន ។ រូបថតទាំងនោះ ចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។


បាន សារឿន និងក្មួយ១

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រ លេខ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthwynne@dccam.org ឬ truthpivoine@dccam.org ។

សូមអរគុណ ។

# គ្រួសារចិនមួយនៅក្នុងរបបខ្មែរក្រហម


ភី ឡាន់គៀម

ភី ឡាន់គៀម អាយុ៨៣ឆ្នាំ ជាកូនកាត់ខ្មែរ-ចិន សព្វថ្ងៃរស់នៅក្នុងភូមិរនៀស ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ។ គាត់មានកូនប្រាំនាក់ ។

នៅអាយុ១៨ឆ្នាំ ឡាន់គៀម បានរៀបការជាមួយនឹង ង៉ាន់ ស៊ីង ជាជនជាតិចិនដែលទើបនឹងមកដល់ប្រទេសកម្ពុជាថ្មីៗ ហើយប្រកបមុខរបរជួសជុលនាឡិកានៅខេត្តកំពត ។ ឡាន់គៀម រំឭកឡើងវិញថា ប្តីគាត់បានចាកចេញពីខេត្តហៃណានដើម្បីគេចពីកំណែនទាហាននៅក្នុងអំឡុងពេលមានការចូលឈ្លានពានរបស់ជប៉ុននៅប្រទេសចិន ។ ពីរបីឆ្នាំក្រោយពេលរៀបការ ឡាន់គៀម និងប្តីបានផ្លាស់ទៅរស់នៅខេត្តតាកែវ ដើម្បីទុកឲ្យបងប្រុសរបស់ ង៉ាន់ ស៊ីង ដែលទើបនឹងមកដល់ស្រុកខ្មែរនោះបានធ្វើជាជាងជួសជុលនាឡិកានៅក្នុងខេត្តកំពត ។

ប្រមាណ៣០ឆ្នាំក្រោយមក ឡាន់គៀម និងក្រុមគ្រួសារទាំងមូល បានចាកចេញពីខេត្តកំពតទៅរស់នៅក្រុងកំពង់សោម ដើម្បីគេចចេញពីការប្រយុទ្ធគ្នារវាងទាហានលន់ណុលនិងកងទ័ពខ្មែរក្រហម ។ ការប្រយុទ្ធគ្នានេះចេះតែបន្តគ្មានពេលស្រាកស្រាន្តរហូតដល់កងទ័ពខ្មែរក្រហមយកឈ្នះទាំងស្រុងទៅលើរបបលន់ណុល ។ ក្រុមគ្រួសាររបស់ ឡាន់គៀម ត្រូវកងទ័ពខ្មែរក្រហមបង្ខំឲ្យចេញពីក្រុងកំពង់សោមទៅរស់ក្នុងសភាពភ័យខ្លាចនៅក្បែរតំបន់ព្រៃស្អក ។ ក្រោយមកទៀត ខ្មែរក្រហមបានបញ្ជូនក្រុមគ្រួសាររបស់ ឡាន់គៀម តាមរថភ្លើងឆ្ពោះទៅខេត្តកំពង់ឆ្នាំង ។ ឡាន់គៀម បាននិយាយថា ជនជាតិចិនជាងមួយរយគ្រួសារត្រូវខ្មែរក្រហមដាក់ឲ្យរស់នៅលាយឡំជាមួយជនជាតិខ្មែរនិងចាម ។ ឡាន់គៀម នៅចាំបានថាតំបន់ដែលគាត់រស់នៅគឺជាទឹកដីសម្បូរជំងឺគ្រុនចាញ់ដែលបណ្តាលឲ្យមនុស្សស្លាប់ជាច្រើន ។

ឡាន់គៀម និងជនជាតិចិនដទៃទៀត ត្រូវមេកងធ្វើបាបជារឿយៗដោយសារមិនប្រយត្ន័ធ្លោយមាត់និយាយភាសាចិន ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យជនជាតិចិនរក្សាទំនៀមទម្លាប់របស់ខ្លួនឡើយ ។

កូនប្រុសរបស់ ឡាន់គៀម ឈ្មោះ ហេង ដែលមានអាយុប្រហែល៣០ឆ្នាំ ត្រូវប្រធានក្រុមឈ្មោះ ប៉ាន វាយដំយ៉ាងដំណំ ដោយសារ ហេង បណ្តោយឲ្យជ្រូកស៊ីដំណាំ និងធ្វើឲ្យជ្រុះបាត់នាឡិកាដៃរបស់ប្រធានក្រុមនោះ ។ ក្រោយមក នាឡិកាដៃដែលជ្រុះចូលក្រោមគំនរខសដោយចៃដន្យនោះត្រូវបានរកឃើញវិញ ។ ឡាន់គៀម និយាយថា គេឲ្យកូនប្រុសរបស់គាត់ជួលជុលនាឡិការបស់ ប៉ាន បានយ៉ាងម៉េចកើត បើគ្មានប្រេងនិងឧបករណ៍ជួសជុលផងនោះ ។ ចំណែកប្តីរបស់ ឡាន់គៀម ក៏មិនព្រមជួសជុលនាឡិកានោះដែរ ។

ប្តីរបស់ ឡាន់គៀម ជាមនុស្សចចេសរឹងរូសណាស់ ។ គាត់នឹងមិនព្រមជួសជុលនាឡិកាឲ្យកម្មាភិបាលខ្មែរក្រហមម្នាក់ណាឡើយ ប្រសិនបើកម្មាភិបាលនោះមិនឲ្យដំឡូងមួយគីឡូក្រាមជាការតបស្នង ។ ឡាន់គៀម តែងតែអង្វរករកម្មាភិបាលខ្មែរក្រហមកុំឲ្យប្រកាន់ទឹងនឹងភាពចចេសរឹងរូសរបស់ប្តីគាត់ ។ ឡាន់គៀម ចាំបានថា ថ្ងៃមួយឈ្លបខ្មែរក្រហមមកហៅប្តីរបស់គាត់ចេញពីផ្ទះដោយប្រាប់ថា អង្គការចង់ឲ្យប្តីរបស់គាត់ទៅធ្វើនាឡិកានៅឯចម្ការដូងក្នុងក្រុងកំពង់សោម ។ ពេលនោះ ឡាន់គៀម គិតថា ពិតជាមានរឿងមិនស្រួលកើតឡើងចំពោះប្តីគាត់ជាមិនខាន ហើយប្តីគាត់ពិតជាមិនបានត្រឡប់មកវិញទេ ។ នៅពាក់កណ្តាលផ្លូវ នរណាម្នាក់ដែលទំនងជាកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម បានបញ្ជាឲ្យដោះលែងប្តីរបស់គាត់ ។

ប្រជាជននៅក្នុងសហករណ៍ដែល ឡាន់គៀម រស់នៅសុទ្ធតែខ្វះខាតចំណីអាហារនិងមានជំងឺដែលបណ្តាលឲ្យបាត់បង់ជីវិតជាច្រើននាក់ ។ ថ្នាំសង្កូវដែលផលិតចេញពីឫសនិងសំបកឈើគ្មានប្រសិទ្ធភាពទេ ។ ចំនួនបុរសស្លាប់ច្រើនជាងស្ត្រី ។ ឡាន់គៀម

និយាយថា វាជារឿងអាក្រក់ខ្លាំងណាស់ដែលចុងក្រោយស្ត្រី ទទួលបន្ទុកសែងខ្មោចបុរសយកទៅកប់ ។

បន្ទាប់ពីថ្ងៃ៧មករា ឆ្នាំ១៩៧៩ ឡាន់គៀម និងក្រុមគ្រួសាររបស់គាត់ភៀស ខ្លួនទៅជំរំមួយថាន ជំរំឡុងទៀន និងជំរំសុងប៊ែរ របស់ប្រទេសវៀតណាម ។ ឡាន់គៀម ប្រាប់ថា កាលនោះគាត់មិនចង់រស់នៅលើទឹកដីកម្ពុជាតទៅទៀតទេ ។ គាត់ខឹងខ្មែរក្រហមខ្លាំងណាស់ ។ គាត់នឹកស្មានមិនដល់ពីទំហំនៃទុក្ខទោសដែលខ្មែរក្រហមធ្វើមកលើខ្លួនគាត់ផ្ទាល់និងក្រុមគ្រួសាររបស់គាត់ឡើយ ។ ទោះយ៉ាងណាក៏ដោយ ឡាន់គៀម និងសមាជិកគ្រួសារ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៩៨ ។

នៅពេលវិលត្រឡប់មកវិញ ប្តីរបស់ ឡាន់គៀម បានបន្តអាជីពជាជាងជួសជុលនាឡិកានៅក្នុងផ្សារកំពតដដែល ។ ក្រោយពេលដែលប្តីនិងកូនប្រុសរបស់គាត់ម្នាក់ស្លាប់កាលពីពីរឆ្នាំកន្លងទៅនេះ ឡាន់គៀម មានអារម្មណ៍ថាគាត់គ្មានអ្នកណាពឹងពាក់ទាល់តែសោះ ។ ដូច្នេះហើយ គាត់បានសម្រេចចិត្តទៅរស់នៅក្នុងស្រុកកំពង់ត្រាច ។ សព្វថ្ងៃ ឡាន់គៀម គ្រាន់តែចង់រស់នៅដោយស្ងប់ស្ងាត់ក្នុងជីវភាពសាមញ្ញជាមួយកូនស្រីតែម្នាក់គត់របស់គាត់ប៉ុណ្ណោះ ។

**លី សុខឃាង**

# គ្រួសារ ស៊ុំ សាន

ស៊ុំ សាន ត្រូវអង្គការសម្លាប់ដោយសារតែគាត់ជាជនជាតិវៀតណាម ។ ឪពុករបស់ សាន ជាជនជាតិចិន និងម្តាយជាជនជាតិវៀតណាម ។ មុនរបបខ្មែរក្រហមក្រុមគ្រួសារឪពុកម្តាយរបស់ សាន រស់នៅម្តុំជ្រោយចង្វារាជធានីភ្នំពេញ ។ ស៊ុំ សាន ដែលកំពុងតែមានផ្ទៃពោះ៤ខែ និងកូនៗទាំង៧នាក់របស់គាត់ ត្រូវអង្គការយកទៅសម្លាប់នៅខែកក្កដា ឆ្នាំ១៩៧៧ ។ ឡាច នី អាយុ៦៤ឆ្នាំ ជាប្តីរបស់ សាន បានរៀបរាប់ឲ្យដឹងថា នៅខណៈពេលដែលខ្មែរក្រហមចាប់ប្រពន្ធនិងកូនគាត់យកទៅសម្លាប់ រូបគាត់ត្រូវខ្មែរក្រហមចាប់ឃុំឃាំង ហើយបន្ទាប់ពីពេលនោះគាត់ក៏ក្លាយទៅជាមនុស្សវិកលចរិតដើរចាប់ឱបកូនអ្នកភូមិដោយយល់ច្រឡំថាជាកូនរបស់ខ្លួន ។

***ឡាច នី និង ស៊ុំ សាន***

ឡាច នី គឺជាកូនប្រុសច្បងនៅក្នុងគ្រួសារអ្នកលក់ដូរមួយនៅក្បែរផ្សារស្វាយអន្ទរ ។ ក្រោយពេលបញ្ចប់ការសិក្សានៅសាលាឯកជនមួយក្នុងទីក្រុងភ្នំពេញនៅឆ្នាំ១៩៦០ ឡាច នី បានចូលបម្រើការងារនៅក្រសួងសុរិយោដីទទួលបានបៀវត្សរ៍ ២២០០រៀលក្នុងមួយខែ ។ នៅក្នុងរយៈពេលនោះ ឡាច នី ត្រូវបានមិត្តភក្តិម្នាក់ដែលធ្លាប់រៀនជាមួយគ្នានៅព្រៃវែងណែនាំគាត់ឲ្យស្គាល់ ស៊ុំ សាន ។ ដោយមានការជួយជ្រោងជ្រែងពីមិត្តភក្តិ ឡាច នី និង ស៊ុំ សាន បានរៀបការនៅឆ្នាំ១៩៦២ ។

បន្ទាប់ពីរៀបការរួច ស៊ុំ សាន ធ្វើជាចុងភៅនៅហាងក្រណាត់របស់ជនជាតិឥណ្ឌា ។ មួយឆ្នាំក្រោយមក ឡាច នី បានលាឈប់ពីការងារនៅក្រសួងសុរិយោដីដោយសារប្រាក់បៀវត្សរ៍តិចតួចពេក ហើយមកធ្វើជាអ្នកបកប្រែភាសាបារាំងខ្មែរនៅក្នុងហាងក្រណាត់ជាមួយប្រពន្ធ ។

នៅឆ្នាំ១៩៦៨ អ្នកទាំងពីរបានលាឈប់ពីការងារនៅហាងក្រណាត់ ហើយត្រឡប់មករស់នៅក្នុងស្រុកកំណើតនៅខេត្តព្រៃវែងវិញ ។ មុនពេលមកដល់ស្រុកកំណើត ឡាច នី បានធ្វើជាគ្រូបង្រៀនមួយរយៈពេលខ្លីនៅសាលាឯកជនដីឥដ្ឋ (ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១០ចន្លោះស្រុកកៀនស្វាយនិងអ្នកលឿង) ។ នៅខណៈពេលនោះ ទំនិញចេះតែឡើងថ្លៃពីមួយថ្ងៃទៅមួយថ្ងៃ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះ ។

ឡាច នី និង ស៊ុំ សាន ព្រមទាំងកូនស្រី២នាក់ បានមកដល់ភូមិពោធិ៍ចិនដាំនៅចុងឆ្នាំ១៩៦៨ ។ អ្នកទាំងពីរប្រកបមុខរបរជាអ្នកលក់បន្លែនៅផ្សារស្វាយអន្ទរនិងឆ្លៀតពេលទៅទិញបន្លែពី

អ្នកលឿងនិងស្រុកអូររាំងឪយកទៅឲ្យប្រពន្ធលក់ ។ អ្នកភូមិគ្រប់គ្នាស្រឡាញ់រាប់អានគ្រួសារនេះណាស់ ។ ឡាច នី បានសរសើរថា ប្រពន្ធគាត់ជាមេផ្ទះដ៏ល្អ ។

សុភមង្គលនិងសេចក្តីរីករាយទាំងអម្បាលម៉ាននបានរលាយអស់បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ។ តាមពិត ភូមិពោធិ៍ចិនដាំធ្លាក់ក្រោមអំណាចរបស់ពួកខ្មែរក្រហមតាំងពីប៉ុន្មានខែក្រោយពេលដែល លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ម៉្លេះ ។ ឡាច នី គិតថាគ្រួសាររបស់គាត់មានសំណាងជាងអ្នកជម្លៀសមកពីភ្នំពេញ ។ ប្រជាជនជម្លៀសភាគច្រើនត្រូវអង្គការសម្លាប់ដោយចោទប្រកាន់ថាជាមន្ត្រីរាជការ សក្តិភូមិ និងមូលធន ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចទូទាំងប្រទេសនៅឆ្នាំ១៩៧៥ គ្រួសាររបស់ ស៊ុំ សាន មិនត្រូវបានជម្លៀសទៅទីណាទេ ។ ឡាច នី ត្រូវបានចាត់តាំងឲ្យបង្រៀនកុមារនៅពេលថ្ងៃត្រង់ ហើយពេលព្រឹកនិងពេលរសៀលដឹកនាំកុមារៗទៅធ្វើការនៅតាមវាលស្រែនិងធ្វើការងារផ្សេងៗទៀតដែលអង្គការចាត់តាំង ។ ស៊ុំ សាន ដែលមានកូនតូច ធ្វើការក្បែរភូមិក្នុងកងមីងៗ ដូចជាស្ទូងស្រូវ ច្រូតស្រូវ និងដាំបន្លែ ។ កូនស្រីច្បងរបស់ សាន ដែលមានអាយុ១១ឆ្នាំ ត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅក្នុងកងចល័តយុវនារីដែលស្ថិតនៅឆ្ងាយពីភូមិ ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ឡាច នី ត្រូវគណៈឃុំស្វាយអន្ទរ ឈ្មោះ ឡឹម ឆែម ហៅទៅមន្ទីរឃុំដើម្បីសាកសួរអំពីប្រវត្តិរូបប្រពន្ធរបស់គាត់ ។ ឡាច នី បានប្រាប់ថាប្រពន្ធរបស់គាត់ជាជនជាតិខ្មែរដែលមានឪពុកជាកូនចៅចិន ។ ប៉ុន្តែ ឆែម មិនជឿសម្តីរបស់ ឡាច នី ទេព្រោះ ឆែម ដឹងច្បាស់ថា សាន ជាជនជាតិវៀតណាម ដូច្នេះត្រូវតែបញ្ជូនទៅប្រទេសវៀតណាមវិញ ។ ឡាច នី ក៏បានសុំអង្វរឲ្យ ឆែម ទុកកូនស្រីច្បងតែម្នាក់ក៏បានដែរ ប៉ុន្តែ ឆែម បដិសេធ ហើយថែមទាំងនិយាយថា ត្រូវយកទាំងម្តាយទាំងកូនទៅទាំងអស់តែម្តង ។ ត្រឡប់មកផ្ទះវិញ ឡាច នី បានប្រាប់ប្រពន្ធថា «ឯងនិងកូននឹងត្រូវអង្គការបញ្ជូនទៅប្រទេសវៀតណាមហើយ» ។ សាន មានទឹកមុខក្រៀមក្រំរហូតចាប់តាំងពីបានឮដំណឹងនេះ ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ឆែម បានបញ្ជាឲ្យឈ្លបមកយកនាំខ្លួន សាន និងកូនៗ ក្នុងអំឡុងពេលដែល ឡាច នី កំពុងតែជាប់ឃុំឃាំង ។ មូលហេតុដែលខ្មែរក្រហមចាប់ ឡាច នី ឃុំឃាំងនេះព្រោះខ្លាចគាត់ទាមទារទៅជាមួយប្រពន្ធដែរ ។ ឡាច នី ក៏បាននិយាយថា ប្រសិនបើជាខ្មែរក្រហមមិនចាប់គាត់ដាក់ឃុំឃាំងទេ គាត់សុខចិត្តស្លាប់ជាមួយប្រពន្ធកូនប្រសើរជាងរស់នៅតែម្នាក់ឯង ។

ស៊ុំ សាន និងកូន៦នាក់ ត្រូវកងឈ្លបដឹកយកទៅតាមរទេះសេះ ។ ចំណែកកូនស្រីច្បងមកដល់ភូមិបន្ទាប់ពីម្តាយនិងប្អូនៗចេញផុតរយៈពេលមួយម៉ោង ។ កូនស្រីច្បងរបស់ ឡាច នី បានរត់និងស្រែកហៅឲ្យជីដូនជីតាជួយ ប៉ុន្តែកងឈ្លបដេញចាប់នាងពេញភូមិ ។

ស៊ុំ សាន និងកូន ត្រូវខ្មែរក្រហមយកទៅសម្លាប់ពេលយប់នៅវត្តចាជី ក្នុងភូមិក្រាំងគរស្ថិតក្នុងស្រុកព្រៃវែងខេត្តព្រៃវែង ។



ប្រពន្ធក្រោយនិងកូនៗរបស់ ឡាច នី

ក្រាំងគរជាអតីតមន្ទីរសន្តិសុខនិងមានទីតាំងសម្លាប់មួយកន្លែង ដែលមានជនរងគ្រោះប្រមាណមួយម៉ឺននាក់ត្រូវសម្លាប់និងកប់ នៅទីនោះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ រណ្តៅសាកសពនៅក្រាំងគរក្រៅពីមានជនរងគ្រោះជាជនជាតិវៀតណាមក៏មានជនជាតិខ្មែរនិងព្រះសង្ឃដែរ ។

ឪពុកម្តាយនិងសាច់ញាតិរបស់ ឡាច នី យំសោកនៅពេលឃើញខ្មែរក្រហមយក សាន និងកូនទៅសម្លាប់ ចំណែក ឡាច នី បានក្លាយជាមនុស្សវិកលចរិត ចាប់ឱបកូនអ្នកដទៃថាជាកូនរបស់ខ្លួន ។ ដោយមានការអាណិតអាសូរពីអ្នកជិតខាង ឡាច នី ត្រូវអ្នកភូមិបញ្ជូនឲ្យធ្វើការឆ្ងាយៗពីផ្ទះ ដើម្បីឲ្យគាត់សាយចិត្តបានខ្លះ ។ មួយឆ្នាំក្រោយមក អង្គការបានចាត់តាំងឲ្យ ឡាច នី រៀបការប្រពន្ធថ្មីឈ្មោះ អ៊ិត ដាត នៅវត្តស្វាយអន្ទរ ។ ពិធីរៀបការនោះមានគូស្រករថ្មីប្រមាណ២០គូ ។

គ្រួសារថ្មីរបស់ ឡាច នី ត្រូវអង្គការខ្មែរក្រហមជម្លៀសទៅភាគពាយ័ព្យ(ជីខ្វាញ់) នៅខេត្តពោធិ៍សាត់ ។ ឡាច នី និងប្រពន្ធគាត់ត្រូវខ្មែរក្រហមបញ្ជូនទៅរស់នៅសហករណ៍អាងទំលែង ក្នុងភូមិថ្លុកត្រពាំង ស្រុកស្វាយដូនកែវ ដែលខ្មែរក្រហមប្រាប់ថាមានដីសម្បូរជីជាតិសម្រាប់ធ្វើស្រែចម្ការនិងដំណាំហូបផ្លែ ប៉ុន្តែការពិតជាកន្លែងលត់ដំសោះ ។ ប្រជាជនត្រូវធ្វើការងារធ្ងន់ធ្ងរលើសកម្លាំងនិងហូបចុកមិនគ្រប់គ្រាន់ ។ ជារៀងរាល់ថ្ងៃឃើញតែប្រជាជនស្លាប់ដោយអត់បាយ ធ្វើការហួសកម្លាំង និងត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងរស់ៗ ។

ឡាច នី បានរស់រានមានជីវិតនិងត្រឡប់មកភូមិកំណើតវិញនៅក្នុងឆ្នាំ១៩៧៩ ។ ទោះបីជា ឡាច នី បានត្រឡប់មកដល់ភូមិវិញក៏ដោយ ក៏គាត់នៅតែនឹកគិតពីប្រពន្ធនិងកូនៗរបស់គាត់ដែលត្រូវខ្មែរក្រហមយកទៅសម្លាប់ដែរ ។

ភ្លាមៗបន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅនៅឆ្នាំ១៩៧៩ ឡាច នី មានបំណងចូលបម្រើជាកងទ័ព ប៉ុន្តែដោយមានការបញ្ចុះបញ្ចូលពីសំណាក់មិត្តភក្តិនិងក្រុមគ្រួសារ ឡាច នី សម្រេចចិត្តចូលបម្រើការងារនៅសាលាស្រុកព្រៃវែងរហូតដល់ឆ្នាំ១៩៩៧ ។ សព្វថ្ងៃ ឡាច នី ចូលនិវត្តន៍ហើយ ។ ឡាច នី បាននិយាយថា “ខ្ញុំមិនអាចបំភ្លេចបានឡើយ ។ ដរាបណាខ្ញុំនៅអាចដើរបាន ហើយខ្ញុំនៅឃើញស្រមោលខ្លួនឯង ខ្ញុំនៅតែឃើញមុខប្រពន្ធនិងកូនខ្ញុំជានិច្ច ។ ខ្ញុំបាត់បង់កូន៧នាក់មិនមែនជារឿងធម្មតាទេ ។ កូនៗរបស់ខ្ញុំគ្មានកំហុសអីសោះ ។ ខ្មែរក្រហមព្រៃផ្សៃជាងហ៊ិត្លែទៅទៀត” ។

**ឡុង ដានី**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។

◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**សូ ហ្វារីណា និង លី សុផល**

# ជនជាតិមិល

មិល (នៅក្នុងវចនុក្រមខ្មែរបោះពុម្ពឆ្នាំ១៩៦៧សរសេរមិលក្ខៈ) ជាជនជាតិភាគតិចមួយក្រុមដែលប្រជាជនខ្មែរភាគច្រើនស្ទើរតែមិនដឹងថាអ្នកទាំងអស់នោះកំពុងតែមានវត្តមាននៅក្នុងប្រទេសកម្ពុជាផង ។ ជនជាតិនោះហៅខ្លួនឯងថា មិល ។ ជនជាតិមិលគ្មានសាសនាដូចជនជាតិដទៃទេ ។ បច្ចុប្បន្នជនជាតិនេះមានចំនួន៦១គ្រួសារកំពុងរស់លាយឡំជាមួយប្រជាជនខ្មែរនៅក្នុងភូមិមួយចម្ងាយ៤០គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ។ ភូមិកំណើតរបស់ជនជាតិនេះពីដើមឡើយស្ថិតនៅភូមិឆក់ត្រាចហៅភូមិក្ពិក្ពក់ ចម្ងាយប្រហែល៣០គីឡូម៉ែត្រខាងកើតភូមិអូរពោធិ៍ ខេត្តក្រចេះ ។ ដោយសារមានជំងឺអុតធំរាតត្បាតពេញភូមិនិងដោយមានពួកមួយក្រុមចូលមកកាប់សម្លាប់ប្រជាជនក្នុងភូមិ ជនជាតិមិលបានរត់ភៀសខ្លួនមករស់នៅវាលមួយហៅថា«ស្រែចង្ហប» ។ នៅក្នុងរបបសង្គមរាស្ត្រនិយម ភូមិនេះត្រូវបានប្តូរទីតាំងមកនៅជាប់ផ្លូវជាតិវិញដើម្បីងាយស្រួលទំនាក់ទំនងជាមួយសង្គមនិងដើម្បីឲ្យកុមារបានចូលរៀននៅសាលាផង ។ អំឡុងពេលសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧០ដល់១៩៧៥ និងនៅក្នុងរបបខ្មែរក្រហម បុរសមិលជាច្រើននាក់បានបម្រើបដិវត្តន៍ខ្មែរក្រហម ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះ ជនជាតិមិលមួយចំនួនបានទទួលតួនាទីខ្ពស់ មួយចំនួនត្រូវខ្មែរក្រហមសម្លាប់ចោល ហើយមួយចំនួនទៀតបាត់ខ្លួន ។

គេង ជនជាតិមិល ជាប្រធានឈ្លបនៅក្នុងរបបខ្មែរក្រហម ។ អ្នកភូមិចង្ហបបានដឹងគ្រប់ៗគ្នាថា គេង ជាមនុស្សកាចសាហាវបំផុតនៅជំនាន់នោះ ។ ប្រសិនបើប្រជាជនណាធ្វើខុស ជាពិសេសប្រជាជន១៧មេសា គេង បញ្ជាឲ្យឈ្លបមកហៅទៅ ហើយអ្នកនោះបាត់ខ្លួនរហូត ។ គេង បានសម្លាប់ប្រជាជន១៧មេសាអស់ជាច្រើននាក់ ។ នៅឆ្នាំ១៩៧៩ គេង ត្រូវកងទ័ពវៀតណាមចាប់ខ្លួននិងបញ្ជូនទៅដាក់គុកនៅប្រទេសវៀតណាមអស់រយៈពេលជាងមួយឆ្នាំ ។ ក្រោយពីត្រឡប់ចូលភូមិវិញ គេង ត្រូវប្រជាជន១៧មេសានៅស្រុកតាមួងព្រួតគ្នាវាយសម្លាប់នៅតាមផ្លូវ ។

កក វ៉ិន ជនជាតិមិល អាយុ៥៩ឆ្នាំ ប្រាប់ថា គាត់បាន



ស្ត្រីមិលនៅភូមិចង្ហប

បាត់កូនប្រុសម្នាក់បន្ទាប់ពីទៅបម្រើខ្មែរក្រហម ។ ក្រោយមក បានឮអ្នកស្រុកនិយាយថាកូនរបស់គាត់ត្រូវតាម៉ុកសម្លាប់ ។

សឿ ឃឹម អាយុ៤៥ឆ្នាំ បានចូលធ្វើកងទ័ពខ្មែរក្រហមតាំងពីអាយុ១៥ឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧៦ ។ កាលណោះអង្គការបញ្ជូនគាត់ទៅបម្រើការនៅខេត្តក្រចេះរយៈពេលមួយឆ្នាំ ក្រោមការដឹកនាំរបស់ឈ្មោះ យី និង កួន ។ ចុងឆ្នាំ១៩៧៧ គាត់ត្រូវអង្គការទៅខេត្តរតនគិរី ជាយុទ្ធជននៅកងពល៩២០ ។ នៅក្នុងឆ្នាំ១៩៧៨ អង្គការលើបានចាប់ខ្លួន យី និង កួន ដោយចោទអ្នកទាំងពីរថាក្បត់អង្គការ ។ ក្រោយពីចាប់ យី និង កួន រួចអង្គការក៏តាមចាប់ខ្លួន ឃឹម និងយុទ្ធជនផ្សេងទៀត ។ ឃឹម បានរត់ទៅលាក់ខ្លួនក្នុងព្រៃរហូតដល់ឆ្នាំ ១៩៨២ទើបហ៊ានត្រឡប់ចូលភូមិវិញ ។


សឿ ឃឹម

ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អ្នកភូមិចន្លួបទាំងអស់ត្រូវបានជម្លៀសចេញពីភូមិទៅរស់នៅសហករណ៍ស្រែចន្លួប ចំណែកផ្ទះសម្បែងត្រូវអង្គការយកធ្វើឃ្លាំងសម្រាប់ដាក់អំបិល អង្ករ និងសម្ភារផ្សេងៗ ។ យុវជនត្រូវបង្ខំឲ្យចូលធ្វើកងទ័ព ។ បុរសវ័យកណ្តាលត្រូវអង្គការឲ្យធ្វើជាជាងសាងសង់ផ្ទះ លើកទំនប់ និងធ្វើស្រែ ។ ស្ត្រីវ័យចំណាស់នៅថែរក្សាកុមារតូចនៅមណ្ឌលកុមារ ។ ខេន និង ជូតាំង បានប្រាប់ឲ្យដឹងថា គាត់ត្រូវអង្គការចាត់តាំងឲ្យសាងសង់ផ្ទះគ្រប់ទីកន្លែង ក្នុងរយៈពេលពីរបីខែទើបអង្គការអនុញ្ញាតឲ្យមកជួបក្រុមគ្រួសារម្តង ។ ក្រៅពីការងារសាងសង់ អង្គការបានបញ្ជូនគាត់ទៅលើកទំនប់នៅអូរគ្រៀងនិងនៅកន្លែងផ្សេងទៀតដែលគាត់មិនចាំឈ្មោះ ។ ខេន បានប្រាប់ថា កាលជំនាន់នោះ គាត់ធ្វើស្រែនិងប្រមូលផលស្រូវបានច្រើនណាស់ ប៉ុន្តែគាត់នៅតែហូបបបររាវៗជារៀងរាល់ថ្ងៃ ។ នៅរដូវប្រមូលផលស្រូវគាត់ឃើញមានរថយន្តមកដឹកអង្ករទៅបាត់ៗមិនដឹងថាដឹកយកទៅទុកនៅកន្លែងណាទេ ។ កម្មាភិបាលខ្មែរក្រហមនិយាយប្រាប់ប្រជាជនថាសហករណ៍ផ្សេងខ្វះអង្ករ ហើយក៏ដឹកស្រូវយកទៅ ជួនកាលដឹកចូលទៅក្នុងព្រៃបាត់ ។

ចាប់ពីឆ្នាំ១៩៧៧ សហករណ៍ចន្លួបមានសមាជិកកាន់តែច្រើនដោយសារអង្គការដឹកប្រជាជនជម្លៀសគ្រប់ជនជាតិមាន ខ្មែរ ចិន ចាម មករស់នៅលាយឡំជាមួយប្រជាជនមិល ។ ប្រជាជនទាំងអស់គ្រប់ជាតិសាសន៍មិនត្រូវបានអនុញ្ញាតឲ្យនិយាយភាសាអ្វីក្រៅពីភាសាខ្មែរឡើយ ។

ជូ តាំង ជនជាតិមិល អាយុ៦០ឆ្នាំ បច្ចុប្បន្នជាប្រធានភូមិចន្លួប និយាយថា «ចិនគេអត់ឲ្យនិយាយភាសាចិន ចាមក៏គេអត់ឲ្យនិយាយភាសាចាម មិលក៏គេអត់ឲ្យនិយាយ ឲ្យនិយាយតែភាសាខ្មែរ ហើយជនជាតិចាមសាច់ជ្រូកក៏អត់ឲ្យស៊ី គេបំបិទទាំងអស់ ។ ផ្ទះខ្ញុំនៅពីរគ្រួសារ កូនផ្ទះតូចមួយហ្នឹងចាមមួយគ្រួសារ ចិនមួយគ្រួសារ» ។


ជូ តាំង

កូវ ខេន ជនជាតិមិល អាយុ៧៤ឆ្នាំ និយាយថា ប្រជាជនជម្លៀសស្លាប់ច្រើនកាលជំនាន់នោះ ដោយសារមិនចេះអត់ធ្មត់នឹងការងារនិងរអ៊ូរទាំច្រើន ។ ចំណែកអ្នកភូមិចន្លួបមិនសូវមានស្លាប់ដោយការសម្លាប់ទេ ភាគច្រើនស្លាប់ដោយសារជំងឺគ្មានថ្នាំព្យាបាល ។


កូវ ខេន

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានរៀបគម្រោងធ្វើទំពុក ដោយដាក់ថ្នាំបំពុលនៅក្នុងសម្លឲ្យប្រជាជនហូបនៅថ្ងៃទី៣០ ខែធ្នូ ក្នុងគោលបំណងសម្លាប់ប្រជាជនទាំងអស់នៅសហករណ៍ចន្លួប ។ ផែនការនេះត្រូវបរាជ័យទៅវិញដោយសារកងទ័ពវៀតណាមបានបណ្តេញខ្មែរក្រហមឲ្យរត់ខ្ចាត់ខ្ចាយ ។ ខេន បានដឹងអំពីផែនការនេះដោយចៃដន្យនៅពេលគាត់ធ្វើដំណើរទៅកាន់វាលស្រែ៖ «ថ្ងៃមួយខ្ញុំបានឮមេធំៗប្រជុំគ្នានៅក្រៅភូមិថា ថ្ងៃទី៣០ ទុកក្រមុំខ្មែរស្អាតៗតែមួយពាន់នាក់ទេបង្កាត់ពូជជាមួយចិន ក្រៅពីហ្នឹងបំពុលទាំងអស់ ។ ដល់ឆ្នាំ៧៩កុំតែវៀតណាមមកទាន់ កុំអីខ្មែរយើងអត់សល់ពូជទេ» ។

កែវ ណាន អាយុ៥៣ឆ្នាំ ជនជាតិខ្មែរដែលបានមករស់នៅ




ភូមិចន្លួបតាំងពីឆ្នាំ១៩៦៩ ក៏បានឮអំពីគម្រោងសម្លាប់ប្រជាជនដោយដាក់ថ្នាំបំពុលក្នុងនំបញ្ចុកដែរ ។

នៅពេលបាក់ទ័ពរត់ចូលព្រៃកងទ័ពខ្មែរក្រហមបានកៀរប្រជាជនទៅជាមួយខ្លួន ហើយថែមទាំងឃោសនាថាអ្នកណាមិនរត់នឹងត្រូវវៀតណាមអារ-ក ។ ប្រជាជនភូមិចន្លួបខ្លះភ័យខ្លាចបាននាំគ្នារត់ទៅជាមួយខ្មែរក្រហម ខ្លះទៀតត្រឡប់មកភូមិវិញ ។ ជូ តាំង បាននិយាយថា កាលណោះគាត់បានរត់ទៅរហូតដល់ស្រុកសំបូរ ហើយបានជួបក្រុមគ្រួសាររបស់គាត់នៅកំពង់ព្នៅ ។ តាំង បានប្រគល់អាវុធឲ្យកងទ័ពវៀតណាម រួចនាំប្រពន្ធនិងកូនត្រឡប់មកភូមិវិញ ។ ចំណែក ខេន ក៏ដូចជាអ្នកភូមិរបស់គាត់ដែរ បានរត់កៀសខ្លួនរហូតដល់អូរកាច់ព្រួល ហើយបានជួបកងទ័ពវៀតណាមនៅតាមផ្លូវ ។ កងទ័ពវៀតណាមបានប្រាប់គាត់ឲ្យត្រឡប់មកស្រុកភូមិកំណើតវិញ ។

បន្ទាប់ពីឆ្នាំ១៩៧៩ ជនជាតិមិលវិលត្រឡប់មកភូមិចន្លួបវិញ ។ វៀតណាមបានចាត់តាំងមេភូមិចន្លួបដើម្បីចែកស្រូវអង្ករ អំបិល គោក្របី និងជយភណ្ឌ ឲ្យប្រជាជនស្មើៗគ្នា ។ ក្នុងរយៈពេលនោះ កងទ័ពខ្មែរក្រហមតែងតែលួចវាយឆ្មក់ចូលភូមិចន្លួបជាញឹកញាប់ធ្វើឲ្យអ្នកភូមិមួយចំនួនត្រូវស្លាប់ ។ ម្តាយមីងរបស់ តាំង បានស្លាប់ក្នុងពេលខ្មែរក្រហមវាយឆ្មក់ចូលភូមិចន្លួប ។ តាំង និយាយថា «ខ្ញុំអត់ភ្លេចទេ ទាល់តែខ្ញុំស្លាប់បានខ្ញុំភ្លេចជំនាន់ ៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ ។ ខ្ញុំមានបានពីមុនមកក៏រលាយសូន្យនេះខ្ញុំកសាងសាជាថ្មីទេក្រោយ៧៩នេះ អត់ភ្លេចទេ» ។

នៅពេលរំឭកដល់របបខ្មែរក្រហមប្រជាជនមិលនៅក្នុងភូមិចន្លួបបាននិយាយថាគាត់មិនចង់ឮពីរបបនេះទៀតឡើយ ។ គាត់គ្រាន់តែចង់រស់នៅដោយសុខសាន្តដូចសង្គមសព្វថ្ងៃតែប៉ុណ្ណោះ ទោះបីមានអ្នកមកឃោសនាថាខាងនេះល្អខាងនោះមិនល្អក៏គាត់មិនជឿទៀតដែរ ។

**លី សុផល**

## សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ស្រ៊ុន ម៉ាប់

នាងខ្ញុំឈ្មោះ មុំ ណន អាយុ៧៣ឆ្នាំ រស់នៅភូមិកណ្តាប់ ឃុំចុងអំពិល ស្រុកកញ្ជៀច ខេត្តព្រៃវែង ប្តីឈ្មោះ នុយ ស្រ៊ុន (ស្លាប់ឆ្នាំ១៩៨២) សូមសួររកកូនប្រុសឈ្មោះ ស្រ៊ុន ម៉ាប់ ដែលបានចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧៣ ។ ប្រហែលក្នុងខែ ៦ឬ៧ ឆ្នាំ១៩៧៦ ម៉ាប់ បានមកលេងផ្ទះម្តងបន្ទាប់ពីគាត់ត្រូវរបួសសម្រាកពេទ្យព-២ អស់រយៈពេលជាច្រើនខែ ។ បន្ទាប់ពីពេលនោះមក ខ្ញុំមិនបានទទួលដំណឹងអំពី ម៉ាប់ រហូតដល់ឆ្នាំ ១៩៧៩ សាច់ញាតិម្នាក់ឈ្មោះ ឃុត ឃួន ដែលបានទៅបម្រើបដិវត្តន៍ជាមួយ ម៉ាប់ ដែរ បានប្រាប់ខ្ញុំថា ម៉ាប់ ត្រូវអង្គការដាក់គុកនៅភ្នំជីនៅឆ្នាំ១៩៧៨ បន្ទាប់មកបញ្ជូនទៅភ្នំដងរែក ។ រហូតមកដល់បច្ចុប្បន្ននេះ ខ្ញុំមិនបានទទួលដំណឹងអ្វីអំពី ម៉ាប់ ទៀតទេ ។

បើបងប្អូនណាស្គាល់ឈ្មោះ ស្រ៊ុន ម៉ាប់ ឬសាមីខ្លួនបានឃើញសេចក្តីប្រកាសនេះសូមមេត្តាផ្តល់ដំណឹងមកខ្ញុំតាមរយៈឈ្មោះ នុយ ដានី តាមលេខទូរស័ព្ទ ០១២ ១៨០២៦៥២ ។

សូមអរគុណ ។

## សេចក្តីប្រកាសរកកូនស្រី អ៊ួច សារឿន

នាងខ្ញុំឈ្មោះ ចាន់ សៀម អាយុ៥៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិដីប្រាប ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ សូមសួររកកូនស្រីឈ្មោះ អ៊ួច សារឿន ហៅ យឿន បម្រើការក្នុងកងនារីសែងរបួសនៅវត្តអង្គកែវ ឃុំអង្គកែវ ស្រុកទ្រាំង ខេត្តតាកែវ ។

នៅឆ្នាំ១៩៧៦ យឿន បានផ្ញើសំបុត្រមកផ្ទះម្តងទៀតប្រាប់ថារស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ។ នាងខ្ញុំបានឲ្យកូនប្រុសទៅរក ប៉ុន្តែរកមិនឃើញ ។ តាំងពីពេលនោះមកក៏បាត់ដំណឹង យឿន រហូត ។ មកដល់បច្ចុប្បន្ន យឿន មានអាយុប្រហែល៤០ឆ្នាំ ។

ប្រសិនបើសាមីខ្លួនបានឮ ឬបងប្អូនបានស្គាល់ឈ្មោះខាងលើសូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាៈ ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារលេខ ០២៣ ២១០ ៣៥៨ ។

សូមអរគុណ ។

# សង្ឃឹមថាមានយុត្តិធម៌

ជាជនរងគ្រោះម្នាក់ដែលរួចរស់ជីវិតពីរបបខ្មែរក្រហម សោម ថាច បានចាប់អាជីពជាគ្រូបង្រៀនដើម្បីចិញ្ចឹមកូនទាំងពីររបស់គាត់ ។ ប្ដីរបស់ សោម ថាច ព្រមទាំងឪពុកនិងបងប្អូនរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សោម ថាច អាយុ៥៧ឆ្នាំ ជាស្ត្រីមេម៉ាយមានកូនពីរនាក់ សព្វថ្ងៃរស់នៅភូមិប្រឡាយធំ ឃុំព្រៃញី ស្រុកសំពៅមាស ខេត្តពោធិសាត់ ។ ថាច បានរៀបការជាមួយ គាំ ថេត នៅឆ្នាំ១៩៦៩ ។ ថាច មានស្រុកកំណើតនៅខេត្តបាត់ដំបង ចំណែក គាំ ថេត ជាសិស្សវិទ្យាល័យ មានស្រុកកំណើតនៅខេត្តពោធិ៍សាត់ ។ អ្នកទាំងពីរជាសាច់ញាតិនឹងគ្នា ។



គាំ ថេត នៅមន្ទីរស-២១ ឆ្នាំ១៩៧៧

ឆ្នាំ១៩៧០ ថេត បានបញ្ចប់ថ្នាក់វិទ្យាល័យនិងរៀនបន្តនៅទីក្រុងភ្នំពេញផ្នែកស្ថាបត្យកម្ម ។ ថេត និងប្រពន្ធ បានមកស្នាក់នៅផ្ទះម្ដាយមីងនៅម្ដុំវត្តបទុម ។ ការចំណាយសម្រាប់ការសិក្សារបស់ ថេត និងជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកទាំងពីរគឺពឹងផ្អែកទៅលើឪពុកម្ដាយទាំងស្រុង ។ បើតាមសម្ដីរបស់ សោម ថាច គាំ ថេត គឺជានិស្សិតម្នាក់ដែលមានចិត្តអំណត់ព្យាយាម ឆ្លាតវាងវៃ និងរៀនពូកែរហូតទទួលបានចំណាត់ថ្នាក់លេខមួយប្រចាំសាលា ។

ឆ្នាំ១៩៧៤ គាំ ថេត បញ្ចប់បរិញ្ញាបត្រផ្នែកស្ថាបត្យកម្ម ហើយត្រៀមខ្លួនទៅបន្តការសិក្សានៅប្រទេសបារាំងរយៈពេល ៣ឆ្នាំ ។ ខែ១០ ឆ្នាំ១៩៧៤ គាំ ថេត ចេញធ្វើដំណើរទៅសិក្សានៅប្រទេសបារាំង ។

បន្ទាប់ពី គាំ ថេត ចាកចេញពីប្រទេសកម្ពុជាមិនបានមួយឆ្នាំផង ប្រទេសជាតិក៏ធ្លាក់ក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្រុមគ្រួសាររបស់ ថាច ត្រូវខ្មែរក្រហមជម្លៀសទៅស្រុកកំណើតនៅស្រុកថ្មគោល ខេត្តបាត់ដំបង ។ ទៅដល់ទីនោះ ថាច ត្រូវអង្គការចាត់ឲ្យធ្វើការក្នុងកងភ្ជួរស្រែនិងដកសំណាបនៅក្នុងសហករណ៍អន្លង់រុន ។ ថាច មិនបានជួបជុំកូននិងឪពុកម្ដាយបងប្អូនឡើយ ។ ថាច បំពេញការងារនៅក្នុងកងស្រួចដែលតម្រូវឲ្យគាត់ទៅមុខជានិច្ច ។ កូនតូចៗរបស់គាត់ត្រូវផ្ញើទុកជាមួយម្ដាយនៅសមរភូមិក្រោយ យូរៗទើបបានជួបមុខកូនម្ដង ។ ថាច និយាយថា គាត់វេទនាខ្លាំងណាស់ ទាំងការហូបចុក ទាំងការបែកបាក់



ក្រុមគ្រួសារ និងធ្វើការងារហួសកម្លាំង ព្រោះគាត់មិនធ្លាប់ជួបប្រទះការលំបាកបែបនេះពីមុនមកទាល់សោះ ។ ជារៀងរាល់ថ្ងៃ ថាច ទន្ទឹងរង់ចាំមើលផ្លូវប្ដីរបស់គាត់ជានិច្ច ។ មានពេលខ្លះគាត់ដេកដឹបណ្ដើរគិតបណ្ដើរថា តើប្ដីរបស់គាត់បានដឹងពីទុក្ខវេទនារបស់គាត់ដែរឬទេបានជាមិនមករកគាត់យ៉ាងដូច្នេះ ។ ថាច តែងតែសួរនាំអំពីដំណឹងប្ដីរបស់គាត់តាមរយៈអ្នកស្រុកភូមិជាច្រើនលើក

ច្រើនសា ប៉ុន្តែនៅតែមិនបានទទួលដំណឹងសោះ ។

ក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ថាច ត្រឡប់មកស្រុកកំណើតរបស់ប្តីគាត់នៅឯខេត្តពោធិ៍សាត់វិញដោយសង្ឃឹមថានឹងបានជួបប្តីគាត់ ប៉ុន្តែគាត់មិនបានជួបប្តីឡើយ ។ ថាច បានត្រឹមតែទទួលដំណឹងពីប្អូនថ្លៃរបស់គាត់ឈ្មោះ គាំ សផាន ថា មុនឆ្នាំ១៩៧៦ គាត់បានឆ្លើយឆ្លងសំបុត្រជាមួយ គាំ ថេត ជាច្រើនលើក ប៉ុន្តែនៅក្នុងសំបុត្រចុងក្រោយ ថេត បានសរសេរថា «អង្គការនឹងមកយកគាត់ពីស្រុកបារាំងដើម្បីទៅជួយកសាងប្រទេសជាតិនៅពេលឆាប់ៗនេះ» ។ តាំងពីពេលនោះមក ថេត ក៏បាត់ដំណឹងរហូត ។



ថតឆ្នាំ១៩៧៨ មុនពេលចេញដំណើរទៅប្រទេសបារាំង

គាំ សផាន និយាយថា មុនពេល គាំ ថេត ត្រឡប់មកប្រទេសកម្ពុជាវិញ អៀង សារី បានអំពាវនាវឲ្យនិស្សិតទាំងអស់ដែលបានទៅបន្តការសិក្សានៅបរទេសវិលត្រឡប់មកស្រុកកំណើតវិញដើម្បីរួមគ្នាកសាងប្រទេសជាតិ ។ សផាន បានដាស់តឿន ថេត កុំឲ្យវិលត្រឡប់មកក្នុងប្រទេសដែរ ប៉ុន្តែ គាំ ថេត មិនត្រឹមតែមិនស្តាប់យោបល់របស់ ស ផាន ប៉ុណ្ណោះទេ ថែមទាំងស្តីឲ្យប្អូនប្រុសថា «ពួកឯងសុទ្ធតែពួកក្មេងស្រុកកំណើត បានទៅនៅស្រុកគេបែរជាមិនចង់មកស្រុកខ្លួនវិញ» ។ ថាច ក៏បាននិយាយដែរថា ការដែលប្តីរបស់គាត់សម្រេចចិត្តត្រឡប់មកស្រុកវិញ ប្រហែលជាដោយសារគាត់នឹកប្រពន្ធកូន ម្យ៉ាងទៀតគាត់ចង់យកចំណេះដឹងរបស់ខ្លួនមកបម្រើប្រទេសជាតិផង ។

ឆ្នាំ១៩៨២ ប៊ិន សារឿន ដែលជាមិត្តភក្តិរបស់ ថេត បានប្រាប់ ថាច ថា គាត់បានឃើញរូបថតរបស់ ថេត ព្យួរនៅគុកទួលស្លែងក្នុងសម្លៀកបំពាក់ជាអ្នកទោស ។ ដំណឹងនេះធ្វើឲ្យ ថាច ជឿជាក់ថាប្តីរបស់គាត់ពិតជាបានវិលត្រឡប់មកប្រទេសកម្ពុជា និងស្លាប់នៅក្នុងរបបខ្មែរក្រហម ។

រហូតមកដល់ថ្ងៃនេះ សោម ថាច បានត្រឹមតែធ្វើបុណ្យបញ្ជូនកុសលឲ្យប្តីរបស់គាត់និងសម្លឹងមើលរូបថតប្តីមួយសន្លឹកដែលគាត់ខំលាក់ទុកតាំងពីយូរមកហើយ ។

សោម ថាច សង្ឃឹមថាថ្ងៃណាមួយប្រាកដជាមានយុត្តិធម៌សម្រាប់គាត់តាមរយៈការនាំខ្លួនមេដឹកនាំខ្មែរក្រហមយកទៅកាត់ទោសនៅមុខតុលាការអន្តរជាតិ ។ ទោះបីជាការកាត់ទោសនេះមិនអាចទូទាត់នឹងការបាត់បង់ប្តីជាទីស្រលាញ់របស់គាត់ក៏ដោយ ក៏ប៉ុន្តែយ៉ាងហោចណាស់អាចធ្វើឲ្យគាត់ស្ងប់ចិត្តនិងរំសាយកំហឹងដែលធ្លាប់មានពីមុនមកខ្លះដែរ ។ **សារិន ឌីរ:**

# ពន្យល់ពាក្យខ្មែរក្រហម

◆ **ធាតុពិតជាប់ជិតស្និទ្ធនឹងមហាជនៈ** មានមហាជននៅជាមួយបក្ស ។ គណៈកម្មាធិការបក្សមួយនៅក្នុងអង្គភាពមួយ បើគ្មានមហាជននៅជាមួយមិនខ្លាំងទេ ។ នៅជាមួយក្នុងន័យសតិអារម្មណ៍នៅជាមួយ នយោបាយនៅជាមួយ ចាត់តាំងនៅជាមួយ ។ *(ទង់បដិវត្តលេខ៧ ខែកក្កដា ឆ្នាំ១៩៧៦)*

◆ **យោធាបដិវត្តល្អៈ** យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អដោយគ្មានលក្ខខណ្ឌ ពេលមាន ពេលអត់ ពេលស្រួល ពេលលំបាក ពេលឈ្នះ ពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុង ក៏គ្មានលក្ខខណ្ឌ ។

*(កំណត់ហេតុលេខ១០៨)*

# តាំង គីម :

## ការឆ្លើយតបទៅនឹងការរំលោភផ្លូវភេទនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

**(តចប់)**

### ៣) អនុសាសន៍សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ

ផ្នែកដែលទើបតែពិភាក្សានេះផ្តោតទៅលើឧបសគ្គក្នុងការជំនុំជម្រះអំពើរំលោភផ្លូវភេទនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែឧបសគ្គទាំងនេះនឹងមិនអាចពុះពារបានទេប្រសិនបើមិនបានផ្តោតការយកចិត្តទុកដាក់និងធនធានទៅលើបញ្ហានេះតាំងពីដំបូង ។ ផលប្រយោជន៍រយៈពេលខ្លីនិងយូរអង្វែងនៃការជំនុំជម្រះបទល្មើសរំលោភផ្លូវភេទមិនអាចមើលស្រាលបានឡើយ ។ ជាដំបូងនិងសំខាន់បំផុត ការជំនុំជម្រះសេចក្តីបទល្មើសរំលោភផ្លូវភេទនឹងអាចបង្ហាញការពិតនៃបទពិសោធន៍របស់ស្ត្រី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបញ្ឈប់ការស្ងៀមស្ងាត់ចំពោះអំពើរំលោភផ្លូវភេទតាមរយៈការសរសេរជាប្រវត្តិសាស្ត្រ ។ ទីពីរ ការចោទប្រកាន់អ្នកចេញបញ្ជាចំពោះទង្វើរំលោភផ្លូវភេទបានថ្កោលទោសជាទម្ងន់ដល់សកម្មភាពបែបនោះនិងបានធ្វើឲ្យតុល្យភាពអំណាចងាកទៅរកជនរងគ្រោះវិញម្តង ។ ទីបី ការនាំយកជនដៃដល់ទៅកាន់សាលាជំនុំជម្រះក្តីគឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពបំផុតរារាំងការប្រើប្រាស់អំពើរំលោភជាអាវុធនៃសង្គ្រាម ។ ទីបួន ការកាត់សេចក្តីចំពោះបទល្មើសរំលោភផ្លូវភេទនឹងបង្កើតជាយុត្តិសាស្ត្រនៃអំពើរំលោភជាឧក្រិដ្ឋកម្មអន្តរជាតិ ព្រមទាំងជួយអប់រំចៅក្រមអំពីបទល្មើសទាក់ទងនឹងផ្លូវភេទ និងកែប្រែរបៀបដែលចៅក្រមអនុវត្តច្បាប់នៅក្នុងករណីនៃបទល្មើសរំលោភផ្លូវភេទទៀតផង ។ ចុងក្រោយបង្អស់ការជំនុំជម្រះក្តីនេះនឹងជួយអប់រំចៅក្រមកម្ពុជាពីអំពើហិង្សាផ្លូវភេទ និងអាចនាំទៅដល់ការអនុវត្តបានប្រសើរជាងមុននូវច្បាប់ទាក់ទងនឹងអំពើរំលោភផ្លូវភេទ ។ ជាងនេះទៅទៀត ការបង្កើនការពិភាក្សាជុំវិញបញ្ហាហិង្សាផ្លូវភេទនឹងជំរុញឲ្យមានកំណែទម្រង់ផ្នែកច្បាប់ដើម្បីការពារជនរងគ្រោះ ។


តាំង គីម ឆ្នាំ១៩៧៣

បើទោះបីជាមានកង្វះខាតក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញត្រូវតែទទួលបាននូវការគាំទ្រជាជំហានដំបូងឆ្ពោះទៅរកការទទួលខុសត្រូវនៅក្នុងដំណើរនៃការផ្សះផ្សាជាតិ ។ បើទោះជាអង្គជំនុំជម្រះមិនបានផ្តល់ឲ្យ តាំង គីម និងស្ត្រីទៃទៀតដែលរងគ្រោះដូចគាត់ នូវវេទិកាដ៏សមរម្យមួយដើម្បីប្រឈមមុខជាមួយនឹងជនដៃដល់ដែលប្រព្រឹត្តមកលើរូបគាត់ក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញនេះនឹងចាប់ផ្តើមបង្កើតឯកសារជាក់ស្តែងមួយអំពីហេតុការណ៍ដែលកើតឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ កង្វះខាតរបស់អង្គជំនុំជម្រះវិសាមញ្ញអាចរកមិនបានចម្លើយតបទៅនឹងសំណួរជាច្រើនក៏ពិតមែន ក៏ប៉ុន្តែអង្គជំនុំជម្រះនេះនឹងបើកការពិភាក្សាជាតិមួយដ៏មានសារសំខាន់អំពីហេតុការណ៍នៃអតីតកាលដែលនឹងបង្កើនសន្ទុះសម្រាប់ទម្រង់បន្ថែមផ្សេងៗទៀតនៃការផ្សះផ្សាជាតិ ។

មានមធ្យោបាយបួនសំខាន់ៗដែលសហគមន៍ជាតិនិងអន្តរជាតិអាចធានាថាតម្រូវការចាំបាច់របស់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទអាចត្រូវបានដោះស្រាយ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ទីមួយ បង្កើតការការពារតាមនីតិវិធីពិសេសសម្រាប់សាក្សីនិងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ទីពីរ បង្កើតក្រុមសម្រាប់ជនរងគ្រោះនិងសាក្សី នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញដើម្បីផ្តល់ការការពាររយៈពេលខ្លីនិងយូរអង្វែង ទីបី ផ្តល់ការអប់រំអំពីផ្លូវភេទដោយផ្តោតលើបញ្ហាហិង្សាផ្លូវភេទដល់មន្ត្រី

អង្គជំនុំជម្រះវិសាមញ្ញដែលក្នុងនោះរួមមានចៅក្រម ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត ទីបួន តែងតាំងស្ត្រីឲ្យបម្រើការនៅក្នុងតំណែងចៅក្រមនិងព្រះរាជអាជ្ញា ។

### ក) ការគាំពារតាមនីតិវិធី

នៅពេលខ្ញុំកំពុងតែសរសេរអត្ថបទនេះ រដ្ឋសភាជាតិនៃកម្ពុជាមិនទាន់អនុម័តច្បាប់នីតិវិធីនិងភ័ស្តុតាងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅឡើយទេ ។ ខុសប្លែកពីលក្ខន្តិកៈបង្កើតសាលាជំនុំជម្រះក្តីអន្តរជាតិនិងសាលាជំនុំជម្រះក្តីបណ្តោះអាសន្នផ្សេងៗទៀត លក្ខន្តិកៈឬច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញមិនបានអនុញ្ញាតឲ្យចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញបង្កើតនូវច្បាប់នីតិវិធីនិងភ័ស្តុតាងទេ ។ ដូច្នេះ យើងមិនអាចទស្សន៍ទាយជាមុនទេថាតើច្បាប់ណាដែលនឹងត្រូវយកមកអនុវត្ត ឬអ្នកណាដែលជាអ្នកធ្វើសេចក្តីព្រាងច្បាប់នេះ ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញគួរតែយកគំរូតាមសាលាជំនុំជម្រះក្តីអន្តរជាតិផ្សេងៗ និងគួរតែមានច្បាប់នីតិវិធីនិងភ័ស្តុតាងជាពិសេសតាក់តែងឡើងដើម្បីដោះស្រាយតម្រូវការរបស់ជនរងគ្រោះដោយអំពើបំពារបំពានផ្លូវភេទ ។

ដោយសារតែយុត្តិសាស្ត្រកម្ពុជាស្តីពីអំពើហិង្សាផ្លូវភេទមិនទាន់មានការអភិវឌ្ឍន៍ គ្រប់គ្នាសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញនឹងអនុម័តនូវច្បាប់ដែលឆ្លុះបញ្ចាំងពីបទពិសោធន៍មានតម្លៃដែលទទួលបានពីសាលាជំនុំជម្រះក្តីអន្តរជាតិនៅយូហ្គោស្លាវីនិងរ៉្វាន់ដាចំពោះសំណុំរឿងដែលទាក់ទងនឹងករណីរំលោភផ្លូវភេទ ។ ឧទាហរណ៍ ច្បាប់នីតិវិធីសម្រាប់សាលាជំនុំជម្រះក្តីទាំងនោះមិនតម្រូវឲ្យមានការអះអាងបញ្ជាក់សក្ខីភាពពីជនរងគ្រោះដោយអំពើរំលោភផ្លូវភេទទេ ។ សាលាជំនុំជម្រះក្តីទាំងនោះមិនទទួលស្គាល់ភ័ស្តុតាងរបស់ជនរងគ្រោះមុនពេលត្រូវរំលោភ និងមិនទទួលស្គាល់ការអះអាងរបស់ជនដៃដល់ដែលថាជនរងគ្រោះ “បានយល់ព្រម” ដែរនៅក្នុងស្ថានភាពដែលត្រូវគំរាមកំហែង ។ សេចក្តីសម្រេច “ហ្វូរុនដ៍ហ្ស៊ីចា” បានកត់សម្គាល់ការរីកចម្រើនជាសារវន្តចេញពីការសន្មតដ៏គ្រោះថ្នាក់ដូចជា បន្ថយការជឿជាក់លើជនរងគ្រោះនៃអំពើរំលោភផ្លូវភេទដែលមានការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរនិងដែលកំពុងទទួលការព្យាបាល ។ សេចក្តីសម្រេចនោះសរសេរថា “នេះមិនមែនមានមានន័យថា ជនរងគ្រោះដែលប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរផ្តល់ភ័ស្តុតាងមិនត្រឹមត្រូវនោះទេ ។ មិនមានហេតុផលណាមួយដែលអាចអះអាងថា អ្នកដែលមានការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរមិនអាចធ្វើជាសាក្សីដែលផ្តល់ពត៌មានឥតខ្ចោះនោះទេ” ។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានអំពាវនាវឲ្យមានការគាំពារជនរងគ្រោះនិងសាក្សី ប៉ុន្តែច្បាប់នេះបានបញ្ជាក់នីតិវិធីតែមួយគត់ទាក់ទងនឹងការគាំពារនេះ គឺកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ដើម្បីឲ្យចៅក្រមពិនិត្យមើលភ័ស្តុតាង ។ មិនត្រឹមតែមិនបានបញ្ជាក់អំពីនីតិវិធីការពារផ្សេងទៀតប៉ុណ្ណោះទេ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញថែមទាំងមិនបានកំណត់កិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ទៀតផង ។ ច្បាប់នីតិវិធីដែលមិនទាន់បានអនុម័តនេះគួរតែបញ្ជាក់ឲ្យបានច្បាស់នូវវិធានការដែលនឹងផ្តល់នូវការថែរក្សាសន្តិសុខដល់ជនរងគ្រោះ ការពារមិនឲ្យមានការប៉ះពាល់ផ្លូវចិត្ត និងការពារសមាសភាពរបស់ជនរងគ្រោះ ។

### ខ) អង្គភាពជនរងគ្រោះនិងសាក្សី

ដើម្បីផ្តល់នូវការគាំពារមួយដែលមានលក្ខណៈល្អិតល្អន់ អង្គជំនុំជម្រះវិសាមញ្ញគួរតែបង្កើតអង្គភាពជនរងគ្រោះនិងសាក្សីដែលអាចសម្របសម្រួលតម្រូវការចាំបាច់របស់ជនរងគ្រោះ ។ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញថ្មីៗនេះបានបង្កើតការិយាល័យចំនួនបីដើម្បីចែករំលែកការទទួលខុសត្រូវចំពោះការគាំពារជនរងគ្រោះ ។ ការិយាល័យទាំងបីនោះមានៈ ការិយាល័យចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា និងការិយាល័យចៅក្រម ។ កង្វះខាតនៃការចាត់តាំងតួនាទីឲ្យបានច្បាស់លាស់បានបង្ហាញថា កិច្ចគាំពារជនរងគ្រោះមិនមែនជាការយកចិត្តទុកដាក់ជាចម្បងរបស់អ្នកធ្វើច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះទេ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញអាចកែតម្រូវបញ្ហានេះតាមរយៈការបង្កើតអង្គភាពជនរងគ្រោះដែលនឹងផ្តល់កិច្ចគាំពារជិតដល់ និងធានាថាតម្រូវការរបស់ជនរងគ្រោះនឹងត្រូវបានដោះស្រាយ ។

### គ) វគ្គហ្វឹកហ្វឺនអំពីភាពងាយប៉ះពាល់នៃភេទ

ការអប់រំមន្ត្រីដែលពាក់ព័ន្ធជាមួយអង្គជំនុំជម្រះវិសាមញ្ញអំពីនីតិវិធីទាក់ទងនឹងភាពងាយប៉ះពាល់នៃភេទ គឺជាចំណុចគន្លឹះឆ្ពោះទៅរកដំណោះស្រាយដោយជោគជ័យនូវបទល្មើសប្រឆាំងនឹងស្ត្រី ។ មានមេរៀនដ៏សំខាន់ពីរដែលគួរតែទាញយកពីសាលាជំនុំជម្រះក្តីផ្សេងៗទៀត ។ ទីមួយ សារសំខាន់ក្នុងការធ្វើឲ្យស្ត្រីមានអារម្មណ៍ថាខ្លួនមានសុវត្ថិភាពទាំងផ្លូវកាយនិងស្មារតី ហើយសុវត្ថិភាពក្នុងន័យនេះរួមបញ្ចូលទាំងធាតុផ្សំសត្យានុម័តនិងអត្តនោម័ត ។ ដើម្បីបង្កើតបរិយាកាសមួយដែលមានសុវត្ថិភាពនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ អ្នកស៊ើបអង្កេតនិងព្រះរាជអាជ្ញាត្រូវតែទទួលបាននូវការហ្វឹកហ្វឺនក្នុងការសួរសំណួរតាមរបៀបមួយដែលផ្តល់អំណាចដល់ស្ត្រីក្នុងការរៀបរាប់រឿងរ៉ាវរបស់ខ្លួន ។ ជាពិសេស អ្នកស៊ើបអង្កេតអាចត្រូវបានហ្វឹកហ្វឺនឲ្យសួរសំណួរដែលសមរម្យ និងស្តាប់រកចំណុចគន្លឹះនៅក្នុងរឿងរ៉ាវរបស់ស្ត្រីជាជនរងគ្រោះដែលបង្ហាញពីភ័ស្តុតាងនៃអំពើហិង្សាផ្លូវភេទ ។ មេរៀនទីពីរដែលគួរតែរៀនសូត្រទាក់ទងនឹងសារជាតិជួយព្យាបាលជនរងគ្រោះនៃសាលាជំនុំជម្រះក្តី ដែលក្នុងន័យនេះគ្មានសាលាជំនុំជម្រះក្តីណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ស្ត្រីម្នាក់ដែលទទួលរងនូវអំពើហិង្សាផ្លូវភេទទេ ។ បើយោងទៅតាម ដូឌីត ហ្កាដាម និង មីសែល ចារីស ចំណុចសំខាន់គឺថាស្ត្រីដែលជាជនរងគ្រោះ ឬស្ត្រីដែលជាសាក្សី ត្រូវតែទទួលបាននូវសិទ្ធិក្នុងការ«ជ្រើសរើសរវាងការរក្សាភាពស្ងៀមស្ងាត់ឬផ្តល់សក្ខីកម្ម» ។ ម្យ៉ាងទៀត មន្ត្រីរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវប្រាប់ស្ត្រីទាំងនោះឲ្យបានដឹងថា ខ្លួនគាត់មានសិទ្ធិសម្រេចក្នុងការផ្តល់ឬមិនផ្តល់សក្ខីកម្ម ។ វិធានការគាំពារទាំងអស់សម្រាប់ជនរងគ្រោះនិងសាក្សីមានប្រភពចេញពីគោលការណ៍នេះ ។

ជាការពិត កម្មវិធីកសាងសមត្ថភាពសម្រាប់វិស័យយុត្តិធម៌កម្ពុជាមិនទទួលបានជោគជ័យប៉ុន្មានទេក្នុងរយៈពេលជាច្រើនឆ្នាំមកនេះដោយសារតែអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ ។ អ្នកមានប្រាក់និងអំណាចមានឥទ្ធិពលជាខ្លាំងនៅក្នុងការចេញសេចក្តីសម្រេចចិត្តរបស់តុលាការស្ទើរតែគ្រប់ករណីទាំងអស់ បើទោះបីជាមានការហ្វឹកហ្វឺនចៅក្រមអំពីរបៀបអនុវត្តបទដ្ឋានអន្តរជាតិដើម្បីឲ្យសវនាការមានយុត្តិធម៌ក៏ដោយ ។ ការហ្វឹកហ្វឺនផ្នែកយុត្តិធម៌នៅកម្ពុជាឥឡូវនេះមិនមានន័យទាល់តែសោះ ហើយជាលទ្ធផល ប្រទេសផ្តល់ជំនួយបានបដិសេធឧបត្ថម្ភវគ្គហ្វឹកហ្វឺនបែបនេះ ។ ស៊ីវ ហេង័រ បានលើកឡើងថា «បញ្ហាគឺមិនមែនស្ថិតនៅលើសមត្ថភាពក្នុងការវិភាគច្បាប់ឬក៏ការអនុវត្តសាលក្រមឯករាជ្យនោះទេ កត្តាសំខាន់គឺស្ថិតនៅលើការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំនយោបាយសំខាន់ៗក្នុងការធានាថាអ្នកបម្រើការងារនៅក្នុងតុលាការនឹងយកចំណេះដឹងរបស់ខ្លួនទៅប្រើប្រាស់ឲ្យបានត្រឹមត្រូវ» ។ ដូច្នេះ សហគមន៍អន្តរជាតិមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យឥទ្ធិពលនយោបាយដែលគាបសង្កត់លើចៅក្រមនិងអ្នកដែលមានតួនាទីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ បញ្ហាដែលចាក់ឫសជាយូរមកហើយ ដូចជាអំពើពុករលួយជាដើមនឹងមិនអាចដោះស្រាយបានក្នុងរយៈពេលភ្លាមៗនោះទេ ប៉ុន្តែតាមរយៈការត្រួតពិនិត្យមើលរបស់អន្តរជាតិទៅលើប្រព័ន្ធយុត្តិធម៌នៅកម្ពុជានឹងបង្កជាឱកាសក្នុងការអប់រំដល់អ្នកធ្វើការងារផ្នែកប្រព័ន្ធយុត្តិធម៌អំពីបទដ្ឋានអន្តរជាតិសម្រាប់ការជំនុំជម្រះក្តីដែលមានយុត្តិធម៌ ។

## ឃ) បុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញជាស្ត្រី

បទពិសោធន៍កន្លងមករបស់សាលាជំនុំជម្រះក្តីផ្សេងៗទៀតបានបង្ហាញថា នៅពេលដែលមានស្ត្រីកាន់តំណែងខ្ពស់នៅក្នុងសាលាជំនុំជម្រះក្តី ឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រីត្រូវបានដោះស្រាយ ។ មនុស្សជាច្រើនបានជឿជាក់ថា សេចក្តីសម្រេចរបស់សាលាជំនុំជម្រះក្តីអន្តរជាតិនៅរ៉ាន់ដាដើម្បីកាត់សេចក្តី អាកៃយីស៊ុ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍យុត្តិសាស្ត្រទាក់ទងនឹងអំពើរំលោភផ្លូវភេទនៅក្រោមច្បាប់អន្តរជាតិ ត្រូវបានធ្វើឲ្យរីកចម្រើនដោយសារវត្តមានរបស់ចៅក្រមជាស្ត្រីនៅក្នុងក្រុមគណៈវិនិច្ឆ័យដែលបានជំរុញឲ្យដាក់បញ្ចូលឧក្រិដ្ឋកម្មទាំងនោះវិញនៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានលុបចេញពីដីកាចោទប្រកាន់ ។ ការតែងតាំងស្ត្រីជាចៅក្រម ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត នឹងជំរុញឲ្យមានភាពស្រដៀងគ្នានេះនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ពោលគឺអំពើហិង្សាផ្លូវភេទនឹងត្រូវកាត់

សេចក្តីតាមផ្លូវច្បាប់ ។

តាមរយៈការបម្រើការងារនៅក្នុងតំណែងខ្ពស់ៗទាំងនេះ ស្ត្រីបានជួយបញ្ឈប់ការរក្សាភាពស្ងៀមស្ងាត់ជុំវិញបទល្មើសប្រឆាំងនឹងស្ត្រី ។ ដូចដែល ឃែលលី អាសឃីន បានកត់សម្គាល់ថា "វត្តមានរបស់ស្ត្រីនៅក្នុងតំណែងដែលអាចសម្រេចចិត្តតំណាងឲ្យការរីកចម្រើនយ៉ាងខ្លាំងដល់តួនាទីរបស់ស្ត្រីដែលត្រូវបានបង្រួមតូចដោយសារប្រពៃណីនិងឋានៈនៅក្នុងអង្គការច្បាប់និងអង្គការផ្សេងៗ រួមទាំងសាលាជំនុំជម្រក្តីឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិ ។ ជាលទ្ធផល យុត្តិសាស្ត្ររបស់សាលាជំនុំជម្រះក្តីអង្គការសហប្រជាជាតិបានឆ្លុះបញ្ចាំងអំពីការចូលរួមរបស់ស្ត្រី" ។

## ៤) ការស្តារយុត្តិធម៌នៅកម្ពុជា

ដូចបានលើកឡើងរួចហើយនៅក្នុងផ្នែកមុនៗ ឧក្រិដ្ឋកម្មប្រឆាំងស្ត្រីប្រហែលជាមិនសូវមានតួនាទីសំខាន់ប៉ុន្មានទេនៅក្នុងឯកសារប្រវត្តិសាស្ត្រដែលនឹងត្រូវបង្កើតឡើងដោយអង្គជំនុំជម្រះវិសាមញ្ញ ហើយក៏មិនផ្តល់ឲ្យជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទនូវឱកាសក្នុងការប្រឈមមុខចំពោះជនដៃដល់និងទាមទារយុត្តិធម៌ដែរ ។ ដូចគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងស្ត្រីដែរ ស្ត្រីបានរក្សាភាពស្ងៀមស្ងាត់ចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យមកម៉្លេះ ហើយស្ត្រីទាំងនេះក៏មានចេតនាពិសេសចង់បានការផ្សះផ្សាជាតិដែរ ។ មិនមានការស្រាវជ្រាវជាផ្លូវការណាមួយដើម្បីលាតត្រដាងគោលបំណងរបស់ស្ត្រីនៅក្នុងដំណើរការផ្សះផ្សាជាតិនៅឡើយ ហើយក៏មិនមានការស្រាវជ្រាវណាមួយអំពីទស្សនៈរបស់ស្ត្រីទាក់ទងនឹងយុទ្ធសាស្ត្រដែលបម្រើគោលបំណងរបស់ស្ត្រីបានសមរម្យបំផុតដែរ ។

នៅក្នុងការស្ទាបស្ទង់នាពេលថ្មីៗនេះទៅលើអ្នកអានទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សំណួរជាច្រើនមានគោលបំណងចង់ដឹងអំពីអារម្មណ៍របស់អ្នកឆ្លើយសំណួរចំពោះរបបខ្មែរក្រហមឬបក្សកុម្មុយនិស្តកម្ពុជា និងចំពោះការផ្សះផ្សាជាតិ ។ ៦៧ភាគរយនៃអ្នកឆ្លើយតបសំណួរអះអាងថា ខ្លួនមិនអាចលើកលែងទោសឲ្យកម្មាភិបាលខ្មែរក្រហមបានទេ ចំណែក៥៨ភាគរយបាននិយាយថាខ្លួនមិនអាចអត់ឱនឲ្យកម្មាភិបាលថ្នាក់ក្រោមទេ ។ ភាគច្រើនបានភ្ជាប់លទ្ធភាពនៃការអត់ឱនទៅការទទួលខុសត្រូវ ដែលក្នុងនោះ៥៨ភាគរយបានសម្តែងថាសាលាជំនុំជម្រះក្តីផ្តល់នូវយន្តការល្អបំផុតសម្រាប់ការអត់ឱន ។ ប៉ុន្តែ ការស្ទាបស្ទង់មតិបានរួមចំណែកតិចតួចដល់ការយល់ដឹងមួយដែលថាតើស្ត្រីពិតជាពេញចិត្តសាលាជំនុំជម្រះក្តីជាជាងទម្រង់ផ្សេងៗទៀតនៃការផ្សះផ្សាជាតិ ។ ទោះបីជាអ្នកឆ្លើយសំណួរបានឆ្លើយតបមកពីតំបន់ផ្សេងៗនិងមានវិជ្ជាជីវៈផ្សេងៗគ្នាក៏ដោយ ក៏អ្នកឆ្លើយភាគច្រើនជាបុរស ហើយភេទស្រីឬប្រុសមិនមែនជាកត្តាក្នុងការវិភាគចម្លើយទាំងនោះឡើយ ។ បុរេលក្ខខណ្ឌច្បាស់លាស់ក្នុងការណែនាំយុទ្ធ-សាស្ត្រផ្សះផ្សាដែលអាចដោះស្រាយឧក្រិដ្ឋកម្មប្រឆាំងស្ត្រីគឺអនុវត្តការស្រាវជ្រាវមួយដែលល្អិតល្អន់អំពីបទពិសោធន៍របស់ស្ត្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទស្សនៈរបស់ស្ត្រីចំពោះមធ្យោបាយដែលសមរម្យបំផុតដើម្បីប្រឈមមុខនឹងអតីតកាល ។

ទោះជាយ៉ាងណាក៏ដោយ អ្វីដែលជាការស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញគឺថា ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញសម្រេចបានជោគជ័យក្នុងការផ្តន្ទាទោសមេដឹកនាំជាន់ខ្ពស់មួយចំនួនក៏ដោយ ក៏សាលាជំនុំជម្រះក្តីនេះនឹងមិនអាចធ្វើឲ្យសះស្បើយនូវការបាក់បែកសង្គមដ៏ធ្ងន់ធ្ងរនៅក្នុងសង្គមកម្ពុជាបានដែរ ។ ជាមួយនឹងចំនួនប្រជាជនកម្ពុជាច្រើនជាងពាក់កណ្តាលដែលបានអះអាងថាខ្លួនមិនអាចអត់ឱនឲ្យកម្មាភិបាលថ្នាក់ក្រោម បានការផ្សះផ្សាជាតិនឹងនៅតែមិនច្បាស់លាស់ដដែលប្រសិនបើគ្មានសាលាជំនុំជម្រះក្តីដើម្បីយុត្តិធម៌ជាគំរូមួយដែលជំរុញឲ្យមានការផ្សះផ្សាជាតិនៅថ្នាក់សហគមន៍ ។ ផ្ទុយទៅនឹងសាលាជំនុំជម្រះក្តីដើម្បីសងសឹកចំពោះជនដៃដល់ សាលាជំនុំជម្រះក្តីដើម្បីស្តារយុត្តិធម៌មានទិសដៅរៀបចំដំណើរការតាមរបៀបដែលផ្តោតការយកចិត្តទុកដាក់ទៅលើជនរងគ្រោះ ដែលអនុញ្ញាតឲ្យជនរងគ្រោះរៀបរាប់រឿងរ៉ាវរបស់ខ្លួននៅចំពោះមុខចៅក្រមដែលមិនលម្អៀង ។ វិធីដោះស្រាយយុត្តិធម៌តាមរបៀបកម្ពុជាបានសន្មតថា យុទ្ធសាស្ត្រផ្សះផ្សាជាតិដែលត្រូវបានរៀបចំ

ពីថ្នាក់ក្រោមទៅលើអាចលែលកបង្កើតនូវដំណើរការជួសជុលសង្គមដែលល្អប្រសើរជាងមុន ដោយសារតែប្រជាជនក្នុងស្រុកបានផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើដំណើរការនេះ ។ យន្តការយុត្តិធម៌ក្នុងស្រុកដ៏សមរម្យមួយអាចជួយលាតត្រដាងការពិតពីអំពើហិង្សាដ្ឋវភេទនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនិងអាចជួយដោះស្រាយកេរដំណែលយូរអង្វែងរបស់របបកម្ពុជាប្រជាធិបតេយ្យ ពោលគឺកម្រិតខ្ពស់នៃអំពើរំលោភផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារដែលកំពុងតែញាំញីសង្គមកម្ពុជាបច្ចុប្បន្ន ។

### ក) រ៉្វាន់ដា៖ តុលាការហ្កាឆាឆា

ឧទាហរណ៍ដែលស្គាល់ច្រើនបំផុតនៃយុត្តិធម៌ក្នុងស្រុកបន្ទាប់ពីអំពើឃោរឃៅមួយរយៈមកគឺប្រហែលជាដំណើរការផ្សះផ្សាសហគមន៍របស់រ៉្វាន់ដាដែលត្រូវបានឲ្យឈ្មោះថា អ៊ីនគីកុហ្កាឆាឆា (ដែលមានន័យថា យុត្តាធិការហ្កាឆាឆា) ។ តុលាការក្នុងស្រុកនេះមានមូលដ្ឋាននៅលើយន្តការដោះស្រាយជម្លោះតាមទំនៀមទម្លាប់ដែលមានឈ្មោះថា ហ្កាឆាឆា និងត្រូវបានដាក់ឈ្មោះតាមស្មៅដែលមេដឹកនាំសហគមន៍អង្គុយពីលើនៅពេលដោះស្រាយពាក្យបណ្តឹងរបស់អ្នកភូមិ ។ ដំណើរការទំនើបរបស់ហ្កាឆាឆាត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលរ៉្វាន់ដានៅឆ្នាំ២០០១ ក្រោមការដឹកនាំរបស់ប្រធានាធិបតី ដល ខាហ្កាមិ និងដោយមានការឧបត្ថម្ភពីយោធាបណ្ឌិតសភាជាន់ខ្ពស់និងអង្គការក្រៅរដ្ឋាភិបាល ក្នុងគោលបំណងដោះស្រាយបញ្ហាពីរដែលក្នុងនោះមានការខកខានរបស់សាលាជំនុំជម្រះក្តីអន្តរជាតិរ៉្វាន់ដាក្នុងការសម្រេចឲ្យបាននូវការផ្សះផ្សាជាតិសម្រាប់ប្រជាជនរ៉្វាន់ដានិងបន្ទុកដែលមិនអាចទ្រាំទ្របាននៃអ្នកទោសចំនួន១២ម៉ឺននាក់ដែលកំពុងជាប់ឃុំឃាំងនៅក្នុងប្រព័ន្ធពន្ធនាគារដែលខ្វះខាតរបស់រ៉្វាន់ដា ។ នៅពេលសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិឬយុត្តិធម៌ព្រហ្មទណ្ឌរបស់រ៉្វាន់ដាកាត់សេចក្តីជនសង្ស័យសំខាន់ៗពីបទប្រល័យពូជសាសន៍ ដំណើរការហ្កាឆាឆានឹងចាប់ជនល្មើសហ៊ូទូដែលកាន់តំណែងតូចតាចឲ្យទទួលខុសត្រូវចំពោះតួនាទីរបស់ខ្លួននៅក្នុងអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា ។

ហ្កាឆាឆាដែលជាគំរូតែមួយគត់នៃតុលាការប្រភេទនេះនៅក្នុងពិភពលោក គឺជាដំណើរការដកពិសោធន៍ដែលសម្រេចបានទាំងយុត្តិធម៌និងការផ្សះផ្សាជាតិនៅពេលតែមួយ ។ ហ្កាឆាឆាបានសង្កត់ធ្ងន់ទៅលើការផ្សះផ្សាជាតិដោយបានផ្តល់ឱកាសឲ្យជនដៃដល់សារភាពអំពីឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ដើម្បីដោះដូរនឹងការធ្វើសមាហរណកម្មអ្នកទាំងនោះត្រឡប់ចូលមកក្នុងសង្គមវិញ បើទោះបីជាបុគ្គលនោះបានប្រព្រឹត្តឧក្រិដ្ឋកម្មនេះរួចទៅហើយក្តី ។ នៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម តុលាការហ្កាឆាឆាបានកោះហៅជនរងគ្រោះនិងជនដៃដល់ឲ្យប្រឈមមុខចំពោះគ្នានៅក្នុងកិច្ចប្រជុំជាសាធារណៈមួយ ។ ការចូលរួមគឺមានភាពចាំបាច់ខ្លាំងណាស់ ។ ជនជាប់ចោទត្រូវបានផ្តល់ឱកាសឲ្យសារភាពជាសាធារណៈនៅចំពោះមុខជនរងគ្រោះដែលរួចរស់ជីវិតពីអំពើប្រល័យពូជសាសន៍ ហើយជនរងគ្រោះនិងសមាជិកសហគមន៍អាចផ្តល់ភស្តុតាងបន្ថែមទៀត ។ ចៅក្រមដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអាចបន្ធូរបន្ថយទោសជនដៃដល់ណាមួយដែលចៅក្រមទាំងនោះគិតថាចម្លើយសារភាពដែលបានមកពីជនដៃដល់នោះពិតប្រាកដនិងមានភាពពេញលេញ ។

យ៉ាងហោចណាស់នៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម ស្ត្រីហាក់បីដូចជាបានចូលរួមក្នុងតុលាការហ្កាឆាឆានៅក្នុងអត្រាមួយច្រើនជាងបុរស ។ ស្ត្រីទាំងនេះបម្រើការងារជាចៅក្រម ហើយបានចូលរួមក្នុងសវនាការនិងសួរសំណួរបានច្រើនជាងបុរស ។ ផលប្រយោជន៍មួយក្នុងចំណោមផលប្រយោជន៍ជាច្រើនរបស់តុលាការហ្កាឆាឆាគឺថា តុលាការនេះបានបង្កភាពងាយស្រួលដល់ស្ត្រីក្នុងការបរិយាយរឿងរ៉ាវរបស់ខ្លួនតាមរបៀបដែលស្ត្រីទាំងនោះចង់បរិយាយ ។ ស្ត្រីរ៉្វាន់ដាជាច្រើនបានទទួលរងនូវការប្រមាថតាមរយៈការផ្តល់សក្ខីភាពរបស់ខ្លួនដោយសារតែមេធាវីជនជាប់ចោទទាមទារឲ្យស្ត្រីទាំងនោះពន្យល់អំពីបទពិសោធន៍នៃអំពើរំលោភផ្លូវភេទក្នុងទម្រង់គ្រោះក្បាយ ។ ការធ្វើដូច្នេះនឹងបង្ខំស្ត្រីឲ្យប្រព្រឹត្តផ្ទុយទៅនឹងការហាមឃាត់នៃវប្បធម៌ព្រមទាំងប្រថុយប្រថានចំពោះការព្រងើយកន្តើយពីសហគមន៍របស់ខ្លួននៅពេលត្រឡប់ទៅវិញ ។ ផ្ទុយទៅវិញ តុលាការហ្កាឆាឆាបានផ្តល់ឲ្យជនរងគ្រោះនូវឱកាសដើម្បីរៀបរាប់រឿងរ៉ាវ

ផ្ទាល់ខ្លួនដោយប្រើប្រាស់ពាក្យសម្តីខ្លួនឯង ប្រឈមមុខជាមួយជនដៃដល់ និងទាមទារការសូមអភ័យទោស ។

វាហាក់បីដូចជាឆាប់រហ័សពេកក្នុងការបរិយាយថាតើដំណើរការសារភាពជាសាធារណៈនេះនឹងទទួលបានជោគជ័យដែរឬទេ ហើយជាពិសេសថាតើតុលាការនេះនឹងផ្តល់ការចាប់ផ្តើមដ៏មានប្រសិទ្ធភាពក្នុងការពិភាក្សាអំពីឧក្រិដ្ឋកម្មរំលោភផ្លូវភេទដែលកើតឡើងនៅក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍នៅរវ៉ាន់ដាដែរឬទេ ។ ជនរងគ្រោះនិងសាក្សីបានសម្តែងការព្រួយបារម្ភថា ការផ្តល់សក្ខីភាពរបស់ខ្លួននឹងបង្កគ្រោះថ្នាក់ដោយការសងសឹកពីសំណាក់ជនដៃដល់ឬក្រុមគ្រួសាររបស់ជនដៃដល់ ។ តុលាការហ្គាឆាឆាមិនបានអនុម័តនីតិវិធីពិសេសទាក់ទងនឹងឧក្រិដ្ឋកម្មនៃអំពើហិង្សាផ្លូវភេទ ដូចជាសវនាការមិនចំហ ឬក៏ការតែងតាំងចៅក្រមនារីសម្រាប់សក្ខីភាពអំពីបទល្មើសរំលោភដែលអាចជំរុញឲ្យអ្នកនៅរស់ជីវិតពីអំពើរំលោភហ៊ានរៀបរាប់អំពីបទពិសោធន៍ជូរចត់របស់ខ្លួន ។ វាជាសញ្ញាវិជ្ជមានមួយដែលមានអត្រាចៅក្រមជានារីច្រើននៅក្នុងតុលាការហ្គាឆាឆា ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះជាចាស់ៗនៅក្នុងភូមិ ហើយប្រព័ន្ធប្រពៃណីរបស់អ្នកទាំងនោះមិនបានផ្តល់អាទិភាពដល់សុវត្ថិភាពរបស់ស្ត្រីទេ ។ ក្រុមអង្គការសិទ្ធិមនុស្សបានរិះគន់តុលាការហ្គាឆាឆាចំពោះការខកខានរបស់រដ្ឋាភិបាលក្នុងការហ្វឹកហ្វឺននិងរៀបចំក្រុមចៅក្រមឲ្យបានគ្រប់គ្រាន់ និងបានអំពាវនាវឲ្យមានការពិនិត្យមើលលទ្ធភាពរបស់រដ្ឋាភិបាលរវ៉ាន់ដាដើម្បីធានាថាសវនាការមានដំណើរការប្រកបដោយយុត្តិធម៌ ។

បទពិសោធន៍របស់តុលាការហ្គាឆាឆាក៏ដូចជាបទពិសោធន៍យុត្តិធម៌ក្នុងស្រុកនៅទីម័រខាងកើត សៀរ៉ាឡេអូន និងកន្លែងផ្សេងៗទៀត អាចផ្តល់នូវមេរៀនល្អៗដល់យុត្តិធម៌នៅកម្ពុជា ។ មេរៀនមួយនៃមេរៀនទាំងនោះគឺជាភាពចាំបាច់ដើម្បីធានាឯករាជ្យភាពនិងអព្យាក្រឹតភាពនៅក្នុងចំណោមចៅក្រមដើម្បីការពារដំណើរត្រឹមត្រូវតាមផ្លូវច្បាប់ ។ រវ៉ាន់ដាបានព្យាយាមកែប្រែឥទ្ធិពលនៃមេដឹកនាំនៅតាមមូលដ្ឋានទៅលើដំណើការរបស់ហ្គាឆាឆាដោយការរៀបចំការបោះឆ្នោតជ្រើសរើសចៅក្រម ។ ចំណុចស្រដៀងគ្នានេះដែរបានកើតឡើងនៅក្នុងគណៈកម្មការស្វែងរកការពិត បដិសណ្ឋារកិច្ច និងការផ្សះផ្សារបស់ទីម័រខាងកើត ។ គណៈកម្មការនេះគឺជាដំណើរការមួយដែលមានគោលដៅធ្វើសមាហរណកម្មសមាជិកកងជីវពលត្រឡប់ទៅក្នុងសហគមន៍វិញតាមរយៈការជួបជុំគ្នាដើម្បីផ្សះផ្សាជាតិ ។ ទាញចេញពីយន្តការយុត្តិធម៌តាមប្រពៃណី ដំណើរការនេះបានផ្តល់ឱកាសដល់សមាជិកកងជីវពលសារភាពអំពីឧក្រិដ្ឋកម្មរបស់ខ្លួននៅចំពោះមុខមនុស្សចាស់ៗនៅក្នុងភូមិ និងសន្យាថានឹងមិនប្រព្រឹត្តអំពើបែបនេះទៀតទេ ។ គុណវិបត្តិមួយគឺថា សហគមន៍បានពឹងផ្អែកទៅលើមេដឹកនាំមូលដ្ឋានដើម្បីផ្តល់ឲ្យប្រជាជននូវពត៌មានអំពីជនដៃដល់ ហើយការធ្វើដូច្នេះបាននាំឲ្យមានការរិះគន់ថាមេដឹកនាំទាំងនោះភាគច្រើនការពារផលប្រយោជន៍ផ្ទាល់ខ្លួន ។

មិនអាចមើលស្រាលពីសារសំខាន់នៃការយល់ឃើញនេះឡើយ ។ គណៈកម្មការនៅទីម័រខាងកើតបានជួបប្រទះបញ្ហាជាច្រើននៅពេលដែលការកាត់ទោសរបស់គណៈកម្មការនេះផ្ទុយទៅនឹងការកាត់ទោសជាផ្លូវការនូវមេដឹកនាំក្រុមឧទ្ទាម ។ ស្រដៀងគ្នានេះដែរ ការខកខានក្នុងការបញ្ជាក់ពីទំនាក់ទំនងរវាងការផ្សះផ្សានិងការពិតនៅសៀរ៉ាឡេអូននិងតុលាការ ពិសេសសៀរ៉ាឡេអូនបានបង្កទាំងភាពមិនច្បាស់លាស់និងការព្រួយបារម្ភអំពីដំណើរសមរម្យតាមផ្លូវច្បាប់ ។ នៅក្នុងបរិបទនៃប្រទេសកម្ពុជាគួរតែមានសារសំខាន់ក្នុងការបែងចែកយុត្តាធិការនៃយន្តការមូលដ្ឋានពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ បញ្ហាទីពីរគឺការផ្គត់ផ្គង់ថវិកា ។ ការពឹងផ្អែកលើការបរិច្ចាគថវិកាពីសហគមន៍មូលដ្ឋានអាចបង្កឱកាសសម្រាប់អំពើពុករលួយការផ្គត់ផ្គង់ថវិកាពីខាងក្រៅនឹងអាចធានាថាជនរងគ្រោះនិងជនដៃដល់នឹងមិនត្រូវបានប្រព្រឹត្តខុសគ្នាដោយសារស្ថានភាពសេដ្ឋកិច្ចនិងសង្គមនៅក្នុងសហគមន៍មូលដ្ឋាន ។ ការឧបត្ថម្ភរបស់អន្តរជាតិគឺមិនទំនងជាទទួលបានទេ ដោយសារតែការនឿយណាយរបស់ម្ចាស់ជំនួយជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញនិងការមិនទុកចិត្តទៅលើយន្តការយុត្តិធម៌មូលដ្ឋាន ។ ក៏ប៉ុន្តែ ការប្តេជ្ញាចិត្តក្នុងការចូលរួមចំណែកឧបត្ថម្ភខ្លះរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងដំណើរការនេះអាច

ផ្តល់ភាពឯករាជ្យនិងអព្យាក្រឹតភាពដើម្បីឲ្យដំណើរការកាត់ក្តីនេះប្រកបដោយយុត្តិធម៌ ។

គ្មានយន្តការផ្សះផ្សានៅថ្នាក់សហគមន៍មួយណាដែលអាចបង្កើតជាដំណើរការឯករាជ្យនិងអព្យាក្រឹតពេញលេញនោះទេ ប៉ុន្តែតាមរយៈបទពិសោធន៍ទាំងនេះ ប្រជាជនកម្ពុជាអាចដោះស្រាយគុណវិបត្តិទាំងនេះ ។ ដូចប្រជាជនរ៉្វាន់ដាដែរ ប្រជាជនកម្ពុជាបានសម្តែងការព្រួយបារម្ភអំពីភាពចាំបាច់ដើម្បីប្រឈមមុខនឹងជនដៃដល់ជាសាធារណៈ និងបង្ខំជនដៃដល់ទាំងនោះឲ្យសារភាពអំពីសកម្មភាពរបស់ខ្លួន ។ តាមការពិត ទោះបីសន្ទុះប្រឈមមុខនិងទាមទារចម្លើយមានច្រើនជាងតម្រូវការក្នុងការចង់ដឹងការពិតឬបំណងចង់សងសឹកក៏ដោយ នេះគឺជាអ្វីដែលប្រជាជនកម្ពុជាចង់បាននៅពេលនិយាយថាខ្លួនចង់ដឹងមូលហេតុដែលអំពើដ៏រន្ធត់នេះកើតឡើង ។ ពិសោធន៍ជាមួយយន្តការយុត្តិធម៌នៅតាមមូលដ្ឋានអាចជំរុញប្រជាជនកម្ពុជាបង្កើតវិធីសាស្ត្រដោះស្រាយដើម្បីការផ្សះផ្សា ។

## ១) ការស្តារយុត្តិធម៌នៅកម្ពុជា

យន្តការស្តារយុត្តិធម៌ត្រូវបានសង្កេតយ៉ាងយកចិត្តទុកដាក់នៅកម្ពុជា ប៉ុន្តែកន្លងមករាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានអនុម័តយន្តការណាមួយដែលមានបែបនេះនៅឡើយទេ ។ សំណើសុំជាទូទៅមួយបានយកបច្ចេកទេសដោះស្រាយជម្លោះតាមព្រះពុទ្ធសាសនាជាសំខាន់ ។ ដូចដែលបានបង្ហាញនៅក្នុងខ្សែភាពយន្តអំពីខ្សែជីវិតរបស់គាត់ តាំង គីម បានងាកទៅធម៌ព្រះពុទ្ធដើម្បីដោះស្រាយកំហឹងរបស់គាត់ ។ ព្រះសង្ឃមួយអង្គដែលជួយណែនាំគាត់ឲ្យបួសជាដូនជីបានដកស្រង់ព្រះធម៌ថា *“ពៀររំងាប់ដោយការមិនចងពៀរ ។ ប្រសិនបើនរណាម្នាក់ប្រព្រឹត្តអំពើអាក្រក់មកលើយើងហើយយើងសងសឹកវិញនោះ ការចងគំនុំនឹងគ្មានទីបញ្ចប់ទេ”* ។ ក៏ប៉ុន្តែ ប្រជាជនកម្ពុជាមានយោបល់ផ្ទុយគ្នាជុំវិញការប្រើប្រាស់យុទ្ធសាស្ត្រផ្សះផ្សាតាមបែបព្រះពុទ្ធសាសនាតែមួយគត់ដើម្បីប្រឈមមុខជាមួយអំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅខណៈពេលដែល៧៨ភាគរយនៃប្រជាជនកម្ពុជាចង់បានសាលាជំនុំជម្រះក្តី មានប្រជាជនកម្ពុជាតែ១៥ភាគរយប៉ុណ្ណោះដែលចង់បានវិធីតាមព្រះពុទ្ធសាសនាដែលអនុញ្ញាតឲ្យជនដៃដល់អាចមកសារភាពចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តនិងសុំការអត់ឱន ។

នៅថ្នាក់សហគមន៍ ព្រះពុទ្ធសាសនាជាផ្នែកដែលមានសារសំខាន់នៅក្នុងដំណើរការដោះស្រាយជម្លោះដ៏សាំញ៉ាំដែលពាក់ព័ន្ធនឹងទំនាក់ទំនងសង្គមនិងការរៀបចំសង្គម ។ តំបន់ជនបទនៅកម្ពុជាមានដំណើរការដោះស្រាយជម្លោះតាមប្រពៃណីមិនផ្លូវការដែលហៅថា“សម្រុះសម្រួល” ។ ដំណើរការនេះមានទម្រង់ជាការសម្រុះសម្រួលដោយភាគីទី៣ ដោយផ្អែកលើគោលការណ៍ព្រះពុទ្ធសាសនា ។ សមាជិកសហគមន៍បានចូលរួមនៅក្នុងអ្វីដែលហៅថាជាកិច្ចខិតខំប្រឹងប្រែងយូរអង្វែងដើម្បីប៉ះប៉ូវដល់ជនរងគ្រោះ ជួសជុលទំនាក់ទំនងដែលខូចខាត និងអនុញ្ញាតឲ្យភាគីទាំងសងខាងត្រឡប់ទៅកាន់ជីវភាពធម្មតាវិញ ។ ជម្លោះប្រហែលជាអាចត្រូវបានដោះស្រាយដោយយោងទៅលើព្រះធម៌ឬក្រមច្បាប់និងវិន័យ ។

តើរបៀបដោះស្រាយជម្លោះទាំងនេះជាយន្តការសមរម្យសម្រាប់ដោះស្រាយឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាពិសេសឧក្រិដ្ឋកម្មហិង្សាផ្លូវភេទប្រឆាំងនឹងស្ត្រីដែរឬទេ? សហគមន៍ដែលស្វះស្វែងដើម្បីដោះស្រាយអំពើហិង្សាផ្លូវភេទតាមរយៈវិធីសាស្ត្រផ្សះផ្សាតាមប្រពៃណីនឹងមិនអាចគេចផុតពីការប្រឈមមុខចំពោះភាពតានតឹងជាគន្ទឹះមួយឡើយ ពោលគឺភាពចាំបាច់ដើម្បីជួសជុលសង្គមមួយដែលខ្ទេចខ្ទាំដោយប្រើប្រាស់នូវយន្តការដោះស្រាយជម្លោះដែលទទួលការគាំទ្រពីប្រជាជនមូលដ្ឋានទល់នឹងបំណងប្រាថ្នាបដិសេធចោលនូវប្រពៃណីដែលលើកកម្ពស់លក្ខខណ្ឌវប្បធម៌សង្គមដែលគាបសង្កត់ស្ត្រី ។ ភាពតានតឹងនេះបាននាំទៅដល់សំណួរដ៏ចម្រូងចម្រាស់ដែលធ្វើឲ្យខូចស្នូលនៃប្រពៃណីសង្គមនិងទំនៀមទម្លាប់សហគមន៍ ។ តើត្រូវថែរក្សាទុកអ្វី ហើយត្រូវផ្លាស់ប្តូរអ្វី?

*ភាពតានតឹងនេះបានធ្វើឲ្យមានការថ្លឹងថ្លែងដ៏ប្រុងប្រយ័ត្ននូវគុណសម្បត្តិនិងគុណវិបត្តិនៃយុត្តិធម៌ ។* យន្តការដែលធ្លាប់

ស្គាល់ច្បាស់នេះអាចបង្កឲ្យមានការចូលរួមទាំងជនរងគ្រោះនិងជនដៃដល់ផង និងសហគមន៍ទាំងមូលផង ។ ស្រដៀងគ្នានេះដែរ យន្តការទាំងនេះមានភាពស្របច្បាប់កម្រិតខ្ពស់នៅក្នុងចំណោមប្រជាជនមូលដ្ឋាន ប៉ុន្តែមិនមានការធានាថាទុក្ខព្រួយរបស់ស្ត្រីត្រូវបានដោះស្រាយយ៉ាងសមរម្យនៅក្នុងយន្តការដោះស្រាយជម្លោះនៅតាមមូលដ្ឋានទាំងនេះទេ ។ ដោយសារតែដំណើរការនេះត្រូវបានប្រើប្រាស់នៅក្នុងស្ថានភាពដែលមានអំពើហិង្សា វាមិនទាន់ច្បាស់លាស់នៅឡើយថាតើស្ត្រីចូលរួមដល់កម្រិតណានៅក្នុងដំណើរការសម្រុះសម្រួលពិតប្រាកដនេះ ។ ទោះជាយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងផ្តល់សេវាកម្មដល់មូលដ្ឋានមុនពេលមានតុលាការ ដើម្បីធ្វើការជាមួយដូនជីនៅទូទាំងប្រទេស ពីព្រោះដូនជីទាំងនោះទទួលបាននូវការគោរពកម្រិតខ្ពស់ពីក្នុងចំណោមអ្នកភូមិ និងមិនសូវពាក់ព័ន្ធនឹងនយោបាយដូចព្រះសង្ឃ ។ ដោយសារតែដូនជីស្ទើរតែទាំងអស់ជាស្ត្រីដែលមានវ័យចំណាស់ ភាគច្រើននៃដូនជីទាំងនេះជាអ្នករស់រានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលស្គាល់ថា ដូនជីអាចផ្តល់នូវធនធានដ៏មានសារសំខាន់នៅក្នុងកិច្ចការកសាងឯកសារប្រវត្តិសាស្ត្រ ។ ទាំងនេះជាមូលហេតុដ៏មានឥទ្ធិពលដើម្បីជំរុញឲ្យដូនជីទាំងនេះបំពេញតួនាទីជាអ្នកសម្រុះសម្រួលនៅក្នុងដំណើរការនៅតាមមូលដ្ឋានដែលផ្តោតលើឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រី ។

ប្រជាជនកម្ពុជា ជាពិសេសស្ត្រីដែលរង់ចាំឱកាសដើម្បីរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួន ជាអ្នកដែលសម្រេចចិត្តចុងក្រោយថាតើយន្តការយុត្តិធម៌នៅតាមមូលដ្ឋានផ្តល់នូវលទ្ធភាពដល់បុគ្គលនិង(ឬ)ការផ្សះផ្សាសង្គមដែរឬទេ ។ ការពិភាក្សានៅថ្នាក់សហគមន៍ផ្តល់នូវគម្រោងមួយដើម្បីទាញយកស្ត្រីចូលទៅក្នុងដំណើរការផ្សះផ្សាជាតិទាំងស្រុង និងដើម្បីដោះស្រាយឧក្រិដ្ឋកម្មដែលជាបទពិសោធន៍របស់ស្ត្រីទាំងនោះ ។ ដោយសារតែដំណើរការតាមប្រពៃណីរបស់តុលាការហ្កាឆាឆាត្រូវបានធ្វើឲ្យទំនើបឡើងដើម្បីផ្តល់ដល់ស្ត្រីនូវការគ្រប់គ្រងធំជាងមុននៅក្នុងដំណើរការនោះ ប្រជាជនកម្ពុជាអាចជួយដូនជី ស្ត្រីចាស់ៗ នៅក្នុងភូមិ និង(ឬ)សមាជិករបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីដើរតួនាទីដែលសំខាន់ជាងមុននៅក្នុងយន្តការយុត្តិធម៌នៅថ្នាក់មូលដ្ឋានរបស់កម្ពុជា ។ ដូចគ្នានៅរ៉្វាន់ដា ដំណើរការផ្លូវការ ដែលមានមូលដ្ឋាននៅតាមសហគមន៍អាចដាក់បញ្ចូលនូវការគាំពារតាមនីតិវិធីទំនើបដើម្បីជំរុញឲ្យស្ត្រីចូលរួមបានច្រើន ។ ជាក់ស្តែង ស្ត្រីអាចជ្រើសរើសការរៀបចំសវនាការជាលក្ខណៈឯកជនដើម្បីបន្ថយការបំភិតបំភ័យដោយសារការរៀបរាប់រឿងរ៉ាវរបស់ខ្លួនជាសាធារណៈ ។

ជាងនេះទៅទៀត វិធីសាស្ត្រដោះស្រាយបែបថ្មីដើម្បីស្តារយុត្តិធម៌នឹងទទួលបាននូវការគាំទ្រជាបន្ត ។ ភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពី តាំង គីម គឺជាយន្តការស្តារយុត្តិធម៌ដែលអ្នកទស្សនាអាចមើលឃើញដំណើរការផ្សះផ្សាដ៏សង្ខេបរបស់បុគ្គលម្នាក់ ។ ជនរងគ្រោះបានពុះពារភាពតានតឹងនៃការជ្រើសរើសរវាងការប្រឈមមុខចំពោះអតីតកាលរបស់ខ្លួន និងការកប់អតីតកាលទាំងនោះដោយឆ្លងកាត់នូវអារម្មណ៍ទុក្ខសោកពីដើមរហូតដល់ចុងបញ្ចប់នៃភាពយន្ត ។ នៅពេលចាប់ផ្តើមដំបូងនៃខ្សែភាពយន្ត តាំង គីម បានបញ្ចេញនូវកំហឹងចំពោះខ្មែរក្រហមដោយបានថ្លែងថា «ទាល់តែយកពួកនោះទៅសម្លាប់ទាំងអស់ទើបខ្ញុំអាចស្ងប់ចិត្តខ្លះ» ។ តាំង គីម ចង់ឲ្យជនដៃដល់ទាំងនោះឈឺចាប់ដូចពេលដែលគាត់ជួបប្រទះពេលនៅក្នុងកណ្តាប់ដៃរបស់អ្នកទាំងនោះដែរ ។ មួយរយៈក្រោយមក តាំង គីម ចាប់ផ្តើមជឿជាក់ថា គាត់អាចរស់នៅដោយស្ងប់ស្ងាត់ប្រសិនបើជនដៃដល់សារភាពអំពីទោសកំហុសរបស់ខ្លួនជាសាធារណៈ ។ ដំណើរការក្នុងការរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួនរបស់ តាំង គីម នៅក្នុងខ្សែភាពយន្តបានប្រែក្លាយបំណងចង់សងសឹករបស់គាត់ទៅជាបំណងប្រាថ្នាចង់បានភាពស្ងប់ស្ងាត់ ។ គាត់បានសម្រេចចិត្តបួសជាដូនជីដើម្បីឲ្យគាត់អាចចេញផុតពីការវាយតម្លៃនិងការតិះដៀលពីសំណាក់អ្នកភូមិដែលបានដឹងអំពីអតីតកាលរបស់គាត់ ។ នៅក្នុងខ្សែភាពយន្តតាំងគីមនិយាយថា «ខ្ញុំសប្បាយចិត្តក្នុងការស្នាក់នៅទីនេះ(វត្ត) ។ នៅក្នុងភូមិឮតែសំឡេងមនុស្សឈ្លោះគ្នា ចំណែកនៅទីនេះយើងឮសូរតែសម្លេងសូត្រធម៌

ប៉ុណ្ណោះ... គ្រប់ៗគ្នាគិតតែស្វែងរកព្រះធម៌» ។

ការរៀបរាប់តាមរយៈភាពយន្តឯកសារជាជាងតាមរយៈការប្រឈមមុខផ្ទាល់ជាមួយជនដៃដល់ បានផ្តល់ឲ្យ តាំង គីម នូវសេរីភាពដោយឡែកពីការដាក់កម្រិតរបស់វប្បធម៌ ។ នៅពេលនោះគាត់មានកំហឹងច្របូកច្របល់ក្នុងចិត្តនិងទាមទារកយុត្តិធម៌ ។ តាំង គីម ខ្លួនឯងមិនយល់ស្របក្នុងការនិយាយជាសាធារណៈអំពីភាពយន្តឯកសារនោះបន្ទាប់ពីការផលិត ដោយសារតែការនិយាយអំពីរឿងនោះធ្លាប់ធ្វើឲ្យប៉ះពាល់ដល់ភាពស្ងប់ស្ងាត់របស់គាត់ៈ «ខ្ញុំគិតថាខ្ញុំគួរតែកុំបង្ហើបរឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំ ។ តាមរយៈនេះ អ្នកទាំងឡាយនឹងមិនស្គាល់ថាខ្ញុំជានរណា ហើយខ្ញុំខ្លួនឯងក៏មានអារម្មណ៍ស្ងប់ស្ងាត់ដែរ» ។ វាច្បាស់ណាស់ថា គាត់មិនចង់ឲ្យការឈឺចាប់របស់គាត់កម្រើកឡើងវិញទេ លុះត្រាតែគាត់ត្រូវបានធានាថាគាត់អាចប្រឈមមុខចំពោះជនដៃដល់និងទាមទារចម្លើយៈ «ប្រសិនបើពួកគេ(ជនដៃដល់) ទាំងនោះសារភាពពីកំហុសរបស់ពួកគេ នោះវាស្ថិតនៅលើខ្ញុំថាត្រូវអភ័យទោសឲ្យអ្នកទាំងនោះឬអត់» ។ ខ្សែភាពយន្តនេះថែរក្សារឿងរ៉ាវរបស់ តាំង គីម ជានិច្ច និងធ្វើឲ្យរឿងនេះនៅតែជារឿងថ្មីសម្រាប់អ្នកដែលមិនទាន់បានទស្សនា ថែមទាំងពុំចាំបាច់ឲ្យ តាំង គីម រៀបរាប់រឿងនេះម្តងទៀត ។ ខ្សែភាពយន្តនេះបានបន្សល់ទុកសំណួរចំហមួយអំពីរបៀបនៃការស្វែងរកការទទួលខុសត្រូវសម្រាប់ជនដៃដល់ដែលប្រព្រឹត្តមកលើគាត់ ។

ខ្សែភាពយន្តនេះបានបញ្ជូនសារដ៏សំខាន់មួយអំពីតួនាទីនៃសិល្បៈនិងការបង្កើតថ្មីដើម្បីការផ្សះផ្សា ។ ខ្សែភាពយន្តនេះកំពុងតែត្រូវបានបញ្ចាំងនៅទូទាំងប្រទេសកម្ពុជាដើម្បីជំរុញឲ្យមានការពិភាក្សានៅតាមសហគមន៍អំពីផ្នែកនៃប្រវត្តិសាស្ត្រដែលកប់បាត់ និងដើម្បីជំរុញការពិភាក្សាអំពីប្រធានបទដែលមានការលំបាកក្នុងការបង្ហាញដូចជាករណីរបស់ តាំង គីម ។ ខ្សែភាពយន្តនេះអាចធ្វើឲ្យមានសុពលភាពនូវរឿងរ៉ាវរំលោភផ្លូវភេទនៅមុនពេលដែលជនរងគ្រោះផ្សេងទៀតជ្រើសរើសរៀបរាប់រឿងរ៉ាវរបស់ខ្លួនឬអត់ ។ អ្នកផលិតភាពយន្ត ជាតរចនា បានពន្យល់ថា «ស្ត្រីត្រូវតែបានទទួលឱកាសក្នុងការចែករំលែករឿងរ៉ាវលំបាកវេទនារបស់ខ្លួនដើម្បីជាការរំឭកដល់អ្នកផ្សេងទៀតថា មិនមែនមានតែខ្លួនទេដែលជួបប្រទះរឿងរ៉ាវឈឺចាប់បែបនោះ» ។ ខ្សែភាពយន្តនេះក៏បានបម្រើឲ្យគោលបំណងនៃការផ្សះផ្សាបុគ្គលសម្រាប់ តាំង គីម និងស្ត្រីដទៃទៀតដែលតស៊ូប្រឆាំងនឹងសម្ពាធរបស់សង្គម ការចងចាំដែលសង្កត់សង្កិននិងការភ័យខ្លាចក្នុងការស្រម័យឃើញប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនោះ ។ ជាមធ្យោបាយអប់រំមួយដ៏មានប្រជាប្រិយភាព ខ្សែភាពយន្តនេះបានជំរុញការផ្សះផ្សាសង្គមតាមរយៈការអប់រំប្រជាជនកម្ពុជាអំពីបទពិសោធន៍ដ៏ជូរចត់របស់ស្ត្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ៥) សេចក្តីសន្និដ្ឋាន

ទស្សនៈរបស់ប្រជាជនកម្ពុជាចំពោះការផ្សះផ្សាបានវិវត្តជាប្រចាំចាប់តាំងពីពេលដែលរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ម្ល៉េះ ។ ឥឡូវនេះ ភាគច្រើននៃប្រជាជនកម្ពុជាបានទទួលស្គាល់ថាការផ្សះផ្សាមិនអាចសម្រេចបានទេប្រសិនបើគ្មានទម្រង់ណាមួយនៃការទទួលខុសត្រូវ ។ ការវិវត្តចុងក្រោយបំផុតនៃអង្គជំនុំជម្រះវិសាមញ្ញបានជំរុញឲ្យមានការពិភាក្សាជាច្រើនអំពីអ្វីដែលជាតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា ។ ទោះបីជាមិនគ្រប់ជ្រុងជ្រោយក៏ដោយ សាលាជំនុំជម្រះក្តីដែលនឹងកើតឡើងនៅពេលខាងមុខនេះប្រហែលជាចម្លើយនៃយុត្តិធម៌ដែលចាប់អ្នកប្រព្រឹត្តអំពើឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យមួយចំនួនតូចឲ្យទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះវិសាមញ្ញមិនមែនជាទីបំផុតនៃរឿងរ៉ាវផ្សះផ្សាជាតិរបស់កម្ពុជានោះទេ ។ ទោះបីជាលទ្ធផលបែបណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញនឹងលុបបំបាត់នូវអ្វីដែលចាំបាច់ក្នុងការបំពេញដើម្បីសម្រេចឲ្យបាននូវយុត្តិធម៌និងការផ្សះផ្សា ។ ការដោះស្រាយឧក្រិដ្ឋកម្មផ្លូវភេទប្រឆាំងនឹងស្ត្រីនឹងជាការប្តេជ្ញាចិត្តដ៏ពិតប្រាកដ ប៉ុន្តែការខកខានមិនបានធ្វើដូច្នេះនឹងធ្វើឲ្យបាត់បង់រឿងរ៉ាវរបស់ស្ត្រីជាច្រើនពីក្នុងប្រវត្តិសាស្ត្រ ។

**ខេទ្រីណា អាន់ជីសុន**

# រ៉្វាន់ដា៖ តើមានសង្ឃឹមសម្រាប់ប្រទេសនេះដែរឬទេ?

ពីខែមេសាដល់ខែកក្កដា ឆ្នាំ១៩៩៤ ប្រទេសរ៉្វាន់ដាបានឆ្លងកាត់អំពើហិង្សាដ៏សាហាវបំផុតមួយ នោះគឺជាអំពើប្រល័យពូជសាសន៍ ។ ក្នុងរយៈពេលមិនដល់មួយរយថ្ងៃផង ជនជាតិទុតស៊ីនិងជនជាតិហ៊ូទូនិយមកណ្តាល (ជនហ៊ូទូដែលមិនប្រកាន់ទស្សនៈជ្រុលនិយម) ជាង៨០ម៉ឺននាក់បានបាត់បង់ជីវិតដោយសារកាំបិតនិងគ្រាប់កាំភ្លើងរបស់ក្រុមខ្មាំងហ៊ូទូជ្រុលនិយម កងទ័ពរដ្ឋាភិបាល និងជនជាតិហ៊ូទូដែលជាអ្នកជិតខាងរបស់ខ្លួន ។ បើពិនិត្យមើលករណីរបស់ប្រទេសរ៉្វាន់ដា គ្រប់គ្នាតែងតែនឹកឃើញនូវសំណួរជាច្រើនៈ តើធ្វើដូចម្តេចទើបយើងអាចយល់បានពីមូលហេតុនិងរបៀបដែលសោកនាដកម្មបែបនេះកើតឡើង? តើយើងគួរតែចាប់ផ្តើមនិយាយអំពីសន្តិភាពនិងការផ្សះផ្សាពីកន្លែងណាមកជាមួយអ្នកដែលជួបប្រទះនូវអតីតកាលអាណោចអធ័មបែបនេះ?

នៅក្នុងអត្ថបទនេះ ខ្ញុំចង់រកឲ្យឃើញនូវរបៀបដែលយើងអាចឆ្លើយតបនឹងសំណួរបែបនេះ ។ ដើម្បីការពារសំណួរនេះកុំឲ្យក្លាយទៅជាការបញ្ចេញគំនិតនិងអារម្មណ៍របស់ខ្ញុំសុទ្ធសាធ ខ្ញុំនឹងសិក្សាតាមវិធីសាស្ត្រទូទៅមួយ ។ វិធីសាស្ត្រនេះខ្ញុំសំដៅដល់ការវិភាគទៅលើជម្លោះ ហើយក្នុងពេលជាមួយគ្នានោះដែរ ខ្ញុំក៏ព្យាយាមឆ្លើយតបទៅនឹងសំណួរដ៏ពិបាកអំពីទស្សនវិជ្ជានិងជាតិពន្ធដែលទាក់ទងទៅនឹងយុត្តិធម៌ ការអត់ឱន និងការផ្សះផ្សា ។ តាមរយៈការវិភាគដ៏ហ្មត់ចត់ ខ្ញុំនឹងរកមូលហេតុដែលបង្កជាអំពើប្រល័យពូជសាសន៍និងបង្ហាញអំពីរឿងរ៉ាវពិតប្រាកដដែលបង្កើតជាប្រវត្តិសាស្ត្រនៅប្រទេសរ៉្វាន់ដា ។ ការណ៍នេះនឹងអនុញ្ញាតឲ្យយើងយល់ដឹងអំពីអតីតកាល បច្ចុប្បន្នកាលនិងអនាគតរបស់រ៉្វាន់ដាបានច្បាស់ជាងមុន ។ ជាងនេះទៅទៀត តាមរយៈការដោះស្រាយរឿងរ៉ាវដែលប្រកបដោយបញ្ហាចិត្តសាស្ត្រនិងទស្សនវិជ្ជានៃអំពើប្រល័យពូជសាសន៍និងឥទ្ធិពលរបស់រឿងរ៉ាវនេះ ខ្ញុំនឹងបង្ហាញឲ្យឃើញថា ការដោះស្រាយជម្លោះនិងការកសាងសន្តិភាពមិនមែនជារឿងងាយស្រួលទេ ។

ជាអកុសល ការសិក្សាអំពីរ៉្វាន់ដាគឺភាគច្រើនខ្វះខាតការអនុវត្តវិធីសាស្ត្រទូទៅបែបនេះ ហើយបានបង្កជាការភ័ន្តច្រឡំដ៏មានគ្រោះថ្នាក់ជាច្រើនអំពីជម្លោះរបស់រ៉្វាន់ដា ។ ទីមួយ នៅក្នុងការពិនិត្យមើលអំពីបុព្វហេតុនៃអំពើប្រល័យពូជសាសន៍ ភាគច្រើននៃសំណេរគឺផ្តោតទៅលើការខកខានរបស់សហគមន៍អន្តរជាតិ និងការព្រងើយកន្តើយចំពោះកត្តាប្រវត្តិសាស្ត្រ កត្តាជាតិ និងកត្តាតំបន់ ព្រមទាំងវិវត្តន៍នៃជម្លោះ ។ តាមរយៈមធ្យោបាយនេះ បរិបទពេញលេញនៃអំពើប្រល័យពូជសាសន៍មិនទាន់ត្រូវបានបង្ហាញគ្រប់ជ្រុងជ្រោយនៅឡើយទេ ។ ជាលទ្ធផល មនុស្សជាច្រើនបានចាប់ផ្តើមជឿជាក់ថា ជនជាតិទុតស៊ីគឺជាជនរងគ្រោះតែមួយគត់នៃអំពើហិង្សា និង(ឬ)ថា អាណានិគមអឺរ៉ុបគឺជាអ្នកបង្កជម្លោះជាតិពន្ធនេះ ។ ដូចគ្នាដែរ មានសំណួរជាច្រើនដែលនៅតែមិនទាន់បានទទួលចម្លើយពេញលេញនៅឡើយដូចជាៈ តើអំពើប្រល័យពូជសាសន៍ត្រូវបានរៀបចំផែនការជាខ្សែសង្វាក់យ៉ាងដូចម្តេចនៅក្នុងរដ្ឋាភិបាលមួយដែលកំពុងតែស្ថិតនៅក្នុង «សម័យអន្តរកាលឆ្ពោះទៅរកប្រជាធិបតេយ្យ» ? តើជនជាតិហ៊ូទូសាមញ្ញរាប់សែននាក់ចូលរួមសម្លាប់អ្នកជិតខាងរបស់ខ្លួនដោយរបៀបណានិងដោយសារមូលហេតុអ្វី? ប្រសិនបើមាន តើអ្វីជាទំនាក់ទំនងនៅក្នុងជម្លោះនៅរ៉្វាន់ដា អ៊ុយហ្កាន់ដា ប៊ូរុនឌី និងកុងហ្គោ-ហ្សាអៀ ដែលសុទ្ធសឹងតែជាបញ្ហារវាងជាតិពន្ធហ៊ូទូនិងទុតស៊ី? ទីពីរ កាយវិការរបស់រដ្ឋាភិបាលដែលដឹកនាំដោយ «រណសិរ្សស្នេហាជាតិរ៉្វាន់ដា» នៅក្នុងប្រទេសរ៉្វាន់ដាក្រោយរបបប្រល័យពូជសាសន៍មិនត្រូវបានត្រួតពិនិត្យឲ្យគ្រប់ជ្រុងជ្រោយនៅឡើយទេ ។ សហគមន៍អន្តរជាតិ លើកលែងតែអង្គការសិទ្ធិមនុស្សមួយចំនួន បានទទួលស្គាល់ថា រដ្ឋាភិបាលរ៉្វាន់ដាថ្មីគឺជារដ្ឋាភិបាលត្រឹមត្រូវ ដូច្នេះហើយ សហគមន៍អន្តរជាតិទាំងនោះក៏បានបញ្ឈប់ការរាយការណ៍លម្អិតអំពីគោលនយោបាយផ្ទៃក្នុង

របស់រ៉្វាន់ដា ។ ទាក់ទងនឹងការកសាងសន្តិភាព ការពិភាក្សាភាគច្រើនបានផ្តោតទៅលើទិដ្ឋភាពផ្នែកច្បាប់នៃយុត្តិធម៌និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ ទន្ទឹមនឹងនោះដែរ ការពិភាក្សានេះបានព្រងើយកន្តើយចំពោះបញ្ហាចិត្តសាស្ត្រ គុណធម៌ និងទស្សនវិជ្ជានៃយុត្តិធម៌ ការអត់ឱន និងការផ្សះផ្សា ។

ដោយពិចារណាអំពីបញ្ហាទាំងនេះ ខ្ញុំនឹងបែងចែកការបកស្រាយសំណួរ «តើមានក្តីសង្ឃឹមសម្រាប់រ៉្វាន់ដាឬទេ?» ជាបីផ្នែក ។ នៅក្នុងផ្នែកទីមួយ «ការយល់ដឹងអំពីអតីតកាល» ខ្ញុំនឹងពិនិត្យមើលការវិវត្តន៍ជាប្រវត្តិសាស្ត្រនៃជម្លោះជាតិពន្ធ ។ តាមរយៈការពិនិត្យមើលបរិបទនិងមូលហេតុដែលបង្កទៅជាអំពើប្រល័យពូជសាសន៍ ខ្ញុំនឹងអះអាងដូចតទៅៈ ១) ខណៈដែលអាណានិគមនិយមមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កជាអំពើហិង្សាជាតិពន្ធនៅរ៉្វាន់ដា ក្រុម «រណសិរ្សស្នេហាជាតិរ៉្វាន់ដា» [ដែលភាគច្រើនជាជនជាតិទុតស៊ីដែលភៀសខ្លួនទៅប្រទេសអ៊ុយហ្កាន់ដានៅពេលមានជម្លោះ] បានធ្វេសប្រហែសចំពោះការជិះជាន់ជនជាតិហ៊ូទូនៅសម័យមុនអាណានិគម ២) ថ្នាក់ដឹកនាំនយោបាយជាជនហ៊ូទូបានផ្ទេរបុព្វសិទ្ធិទាំងអស់ពីទុតស៊ីទៅឲ្យហ៊ូទូ និងបានបង្កើតជាសង្គមរើសអើងពូជសាសន៍មួយនៅសម័យក្រោយអាណានិគម ៣) សង្គ្រាមស៊ីវិលជាមួយ«រណសិរ្សស្នេហាជាតិរ៉្វាន់ដា»បានបង្កបរិយាកាសសម្រាប់អំពើប្រល័យពូជសាសន៍ ដោយសារតែភាពជ្រុលនិយមរបស់ជនជាតិហ៊ូទូនៅរ៉្វាន់ដា ៤) អំពើប្រល័យពូជសាសន៍មិនមែនជាគម្រោងការសុទ្ធសាធរបស់រដ្ឋ ឬជាការផ្ទុះឡើងភ្លាមៗនៃការគុំកួនជាតិពន្ធជាយូរមកហើយនោះទេ និង ៥) ហេតុផលគួរឲ្យកត់សម្គាល់សម្រាប់ជនដៃដល់នៃអំពើប្រល័យពូជសាសន៍ទាំងនោះគឺជាមហិច្ឆតាចង់បានអំណាចនិងការព្រួយបារម្ភជ្រុលហួសហេតុ ។

នៅក្នុងផ្នែកទីពីរ «ការយល់ដឹងអំពីបច្ចុប្បន្នកាល» (ក្រោយឆ្នាំ១៩៩៤) ខ្ញុំនឹងចាប់ផ្តើមដោយពិនិត្យមើលមូលហេតុនិងការវិវត្តន៍នៃសង្គ្រាមក្នុងតំបន់ភាគខាងកើតប្រទេសកុងហ្គោ-ហ្សាអៀ ដើម្បីប្រៀបធៀបបច្ចុប្បន្នកាលរបស់រ៉្វាន់ដាទៅនឹងបរិបទនៃតំបន់ ។ ខ្ញុំនឹងអះអាងថា ជម្លោះនេះគឺជាលទ្ធផលនៃទំនាក់ទំនងដ៏ស្មុគស្មាញរវាងការមិនពេញចិត្តនៃក្រុមជាតិពន្ធ និងការគំរាមកំហែងសុវត្ថិភាពចំពោះរ៉្វាន់ដានិងចេញពីរ៉្វាន់ដា ។ តាមរយៈនេះខ្ញុំនឹងបង្ហាញថា យើងមិនអាចនិយាយអំពី «ក្តីសង្ឃឹមសម្រាប់រ៉្វាន់ដា» ដោយមិនបានគិតពីក្តីសង្ឃឹមសម្រាប់តំបន់ «ហ្គ្រេតឡេក (Great Lake)» ទាំងមូលទេ ។ បន្ទាប់មកខ្ញុំនឹងពិនិត្យមើលកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសន្តិភាពនៅរ៉្វាន់ដា (បន្ទាប់ពីរបបប្រល័យពូជសាសន៍) ដោយយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាយុត្តិធម៌ ការពិត ការអត់ឱន និងការផ្សះផ្សា ។ ជាការសន្និដ្ឋាន អ្វីដែលរដ្ឋាភិបាលរ៉្វាន់ដានិងសហគមន៍អន្តរជាតិបាននិងកំពុងធ្វើក្នុងនាមកអ្នកសាងសន្តិភាពគឺមិនត្រឹមតែមិនគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងករណីខ្លះបង្កជាគ្រោះថ្នាក់ដល់អនាគតរបស់ប្រទេសរ៉្វាន់ដាទៀតផង ។

នៅក្នុងផ្នែកចុងក្រោយ «ការឆ្ពោះទៅរកអនាគតដ៏មានសង្ឃឹម» ខ្ញុំនឹងផ្អែកទៅលើមូលដ្ឋានវិភាគពីផ្នែកមុនៗដើម្បីលើកជាសំណើនូវអ្វីដែលគួរតែអនុវត្តដើម្បីស្វែងរកអនាគតដ៏មានសង្ឃឹមរបស់ប្រទេសរ៉្វាន់ដានៅក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ ។ ខ្ញុំនឹងអះអាងថា អនាគតល្អឬអាក្រក់របស់រ៉្វាន់ដាគឺស្ថិតនៅលើការទទួលខុសត្រូវចម្បងបំផុតរបស់រដ្ឋាភិបាលបច្ចុប្បន្នដែលដឹកនាំដោយជនជាតិទុតស៊ី ។ បើទោះបីជាត្រូវប្រឈមមុខជាមួយការលំបាកក៏ដោយ រដ្ឋាភិបាលរ៉្វាន់ដាត្រូវតែពុះពារដើម្បីកសាងប្រវត្តិសាស្ត្រខ្ទុំទៅមួយ (លើកស្ទួយការគោរពសិទ្ធិមនុស្ស និងលុបបំបាត់ការរើសអើងជាតិពន្ធរវាងទុតស៊ីនិងហ៊ូទូ) ដើម្បីបញ្ចប់អំពើហិង្សានៅរ៉្វាន់ដា ។ សរុបមក កិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពទាំងនេះត្រូវតែមានមូលដ្ឋានលើការទទួលខុសត្រូវទាំងសងខាង និងការទទួលស្គាល់ដូចតទៅៈ ១) ភាពចាំបាច់ក្នុងការអត់ឱននិងក្នុងការទទួលបាននូវការអត់ឱន ២) ជោគវាសនាដូចគ្នាសម្រាប់ប្រជាពលរដ្ឋរ៉្វាន់ដាទាំងមូល និង៣) ដំណើរការដ៏យូរអង្វែងនិងដែនកំណត់នៃការកសាងសន្តិភាព ។

## ផ្នែកទី១ៈ ការស្វែងយល់អំពីអតីតកាល

### ១) ហេតុអ្វីបានជាការពិតនៃប្រវត្តិសាស្ត្រមានសារសំខាន់?

ដើម្បីស្វែងរកក្តីសង្ឃឹមសម្រាប់ប្រទេសរ៉្វាន់ដា ជំហានទីមួយ

គឺត្រូវបង្កើតឲ្យមានឯកសារពិតប្រាកដដែលបានបង្កើតជាប្រវត្តិសាស្ត្ររ៉្វាន់ដា ។ ដូចដែលខ្ញុំនឹងបង្ហាញនៅក្នុងនិក្ខេបបទនេះ បញ្ហាដែលកើតបានឡើងនៅក្នុងប្រវត្តិសាស្ត្រគឺជាចំណុចមូលដ្ឋានដែលបង្កជាជម្លោះនៅក្នុងប្រទេសរ៉្វាន់ដា ។ ការយល់ដឹងអំពីប្រវត្តិសាស្ត្រនិងការចងចាំប្រវត្តិសាស្ត្រខុសៗគ្នានៃជនជាតិទុតស៊ីនិងហ៊ូទូ បានដើរតួនាទីសំខាន់ក្នុងការញុះញង់ឲ្យមានអំពើហិង្សានិងធ្វើឲ្យអំពើហិង្សានេះទៅជាសកម្មភាពស្របច្បាប់ ។ ជនរងគ្រោះនិងជនដែលដែលម្នាក់ៗគិតថាខ្លួនជាជនរងគ្រោះ ហើយបានយកអំពើហិង្សាធ្វើជាដំណោះស្រាយក្នុងការទប់ស្កាត់មិនឲ្យមានអំពើហិង្សាសាជាថ្មីម្តងទៀត ។ រៀងរាល់ពេលប្រើប្រាស់វិធីទប់ស្កាត់បែបនេះតែងតែបណ្តាលឲ្យជនរងគ្រោះក្លាយទៅជាអ្នកប្រព្រឹត្តអំពើហិង្សាទៅវិញ ។ គំនិតជាទូទៅមួយនិយាយថា ប្រសិនបើមនុស្សមិនយល់ដឹងពីប្រវត្តិសាស្ត្រខ្លួនទេនោះ មនុស្សនឹងប្រព្រឹត្តកំហុសដដែលម្តងទៀត ។ ប៉ុន្តែចំពោះករណីប្រទេសរ៉្វាន់ដា ការយល់ឃើញផ្ទុយពីគំនិតនេះក៏មានលក្ខណៈត្រឹមត្រូវដែរ ពោលគឺមនុស្សដែលដឹងអំពីប្រវត្តិសាស្ត្រខ្លួនច្បាស់លាស់ពេកជាមនុស្សដែលនឹងប្រព្រឹត្តកំហុសដដែលសាជាថ្មី ។ ហេតុដូច្នេះ មុនពេលដែលយើងចង់កប់ចោលប្រវត្តិ-សាស្ត្រ យើងត្រូវគាស់កកាយប្រវត្តិសាស្ត្រទាំងឡាយឲ្យរស់ឡើងវិញតាមរយៈការពិចារណាឲ្យបានដិតដល់អំពីគំនិតទាំងពីរនៃប្រវត្តិសាស្ត្រ [ការយល់ឃើញផ្សេងគ្នាអំពីប្រវត្តិសាស្ត្ររ៉្វាន់ដារបស់ក្រុមទុតស៊ីនិងហ៊ូទូ] ។ ដោយមិនចាំបាច់បកស្រាយមតិទូទៅចំពោះមូលហេតុនិងវិធីដែលបង្កឲ្យមានឧក្រិដ្ឋកម្មនៅរ៉្វាន់ដា ការបំភ្លេចអតីតកាលនឹងមិនអនុញ្ញាតឲ្យប្រទេសនេះឆ្ពោះទៅរកអនាគតនៃក្តីសង្ឃឹមបានទេ ។ បើគ្មានការពិត យុត្តិធម៌ក៏មិនអាចមាន ហើយបើមិនមានយុត្តិធម៌ ការផ្សះផ្សាក៏មិនអាចកើតឡើងបានដែរ ។ នៅផ្នែកបន្ទាប់ទៅទៀតនេះ ខ្ញុំនឹងសិក្សាយ៉ាងហ្មត់ចត់អំពីប្រវត្តិនៃជម្លោះជាតិពន្ធ ក៏ដូចជាបណ្តុំមូលហេតុដែលបង្កឲ្យមានអំពើឧក្រិដ្ឋកម្មនៅប្រទេសរ៉្វាន់ដា ។ គោលបំណងនៃនិក្ខេបបទនេះគឺដើម្បីបង្ហាញទាំងការដែលធ្វើឲ្យអំពើហិង្សាទៅជាសកម្មភាពស្របច្បាប់និងកំហុសនៃគំនិតផ្សេងគ្នា [រវាងហ៊ូទូនិងទុតស៊ី]អំពីប្រវត្តិសាស្ត្រតែមួយរបស់រ៉្វាន់ដាដើម្បីបង្កើតមូលដ្ឋានទូទៅមួយសម្រាប់ស្វែងយល់អំពីអតីតកាលនៅប្រទេសរ៉្វាន់ដា ។

## ២) ឫសគល់និងការរីកដុះដាលនៃការបែកបាក់ជាតិពន្ធនៅមុននិងអំឡុងពេលប្រទេសរ៉្វាន់ដាធ្លាក់ក្រោមអាណានិគមបរទេស

បើយោងតាមប្រវត្តិសាស្ត្ររ៉្វាន់ដាដែលគាក់តែងឡើងដោយជនជាតិហ៊ូទូ ការភ័យខ្លាចនិងការស្អប់ខ្ពើមរបស់ជនជាតិហ៊ូទូចំពោះប្រជាជនទុតស៊ីគឺមានឫសគល់ពីការរំលោភបំពានរបស់ក្រុមទុតស៊ីដែលមានរយៈកាលរាប់សតវត្សរ៍កន្លងមកហើយ ។ តាមការពិត ជនកាន់អំណាចជ្រុលនិយមនិងជនដែលហ៊ូទូនៃឧក្រិដ្ឋកម្មដែលកើតឡើងនៅឆ្នាំ១៩៩៤ បានអះអាងនិងជឿជាក់យ៉ាងមុតមាំ (និងចំពោះករណីជាច្រើនរហូតមកដល់បច្ចុប្បន្ននេះ ជនហ៊ូទូនៅតែប្រកាន់គំនិតដដែល) ថា ការគ្រប់គ្រងរបស់ «រណសិរ្សស្នេហាជាតិរ៉្វាន់ដា» គឺគ្មានអ្វីក្រៅពីការវិលត្រឡប់មកវិញនៃអំណាចរបស់ក្រុមទុតស៊ី ដែលបណ្តាលឲ្យមានការបង្ខិតបង្ខំលើកម្លាំងពលកម្មនិងការចាត់ទុកហ៊ូទូជាទាសករតែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ របបដែលគ្រប់គ្រងដោយ «រណសិរ្សស្នេហាជាតិរ៉្វាន់ដា» បន្ទាប់អំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាបានក្លាយទៅជាប្រវត្តិសាស្ត្រមាសរបស់រ៉្វាន់ដាទៅវិញ ដោយនៅក្នុងរបបនេះ ក្រុមទាំងពីររស់នៅជាមួយគ្នាយ៉ាងចុះសម្រុងនិងបង្ហាញថាការបែងចែកបក្សពួកតាមរយៈជាតិពន្ធគឺជាមត៌ករបស់អាណានិគម ។ ដូច្នេះ វាមានសារសំខាន់ណាស់ក្នុងការពិនិត្យឲ្យបានដិតដល់ទៅលើឫសគល់និងការរីកលូតលាស់នៃការបែកបែកជាតិពន្ធនៅប្រទេសរ៉្វាន់ដា ។

ជនជាតិទុតស៊ី (ក្រុមអ្នកគង្វាលសត្វ) បានចូលមកទឹកដីរ៉្វាន់ដានៅអំឡុងសតវត្សរ៍ទី១៥ ។ ក្រុមទុតស៊ីបានប្រើប្រាស់សត្វនិងជំនាញចម្បាំងដើម្បីពង្រឹងអំណាចនិងកេរ្តិ៍ឈ្មោះសម្រាប់ក្រុមខ្លួន ។ ផ្ទុយទៅវិញ ក្រុមហ៊ូទូប្រៀបបីដូចជាអ្នកបម្រើរបស់ក្រុមទុតស៊ី ដោយសារត្រូវចំណាយប្រាក់ច្រើនទៅលើការជួលសត្វរបស់ក្រុមទុតស៊ី ។ បន្តិចម្តងៗសកម្មភាពនេះបានបង្កទៅជារបបសក្តិភូមិរវាងក្រុមទាំងពីរ ។ ទុតស៊ីបានប្រកាសខ្លួនថាមាន

សមត្ថភាពខ្ពស់អាចគ្រប់គ្រងលើក្រុមហ៊ូទូ និងបានបង្កើតជារាជវង្សទុតស៊ីនៅរ៉ាន់ដាភាគកណ្តាល ។ ក៏ប៉ុន្តែដូចដែល «រណសិរ្សស្នេហាជាតិរ៉ាន់ដា» បានបញ្ជាក់ នៅមុនពេលអាណានិគមក្រុមជនជាតិទាំងពីរនេះគឺជាក្រុមតែមួយដែលនិយាយភាសាកេនយ៉ា-រ៉ាន់ដាអស់រយៈពេលជាច្រើនសតវត្សរ៍តាមរយៈការរៀបការឆ្លងជាតិសាសន៍និងការផ្លាស់ប្តូរវប្បធម៌ទៅវិញទៅមក ។ លើសពីនេះ ក៏មានបម្រែបម្រួលសង្គមរវាងក្រុមទាំងពីរតាមរយៈប្រព័ន្ធមួយហៅថា «គ្វីហ៊ូទូរ៉ា» ។ នៅក្នុងប្រព័ន្ធនេះ ក្រុមហ៊ូទូដែលមានសិទ្ធិកាន់កាប់គោលើសពី១០ក្បាលអាចទទួលបានឋានៈសង្គមស្មើក្រុមទុតស៊ីដែរ ហើយទុតស៊ីដែលមានគោតិចជាង១០ក្បាលត្រូវបន្ថយឋានៈសង្គមស្មើហ៊ូទូវិញ ។

ប៉ុន្តែប្រព័ន្ធនេះអាចមានឥទ្ធិពលតែទៅលើក្រុមអ្នកមានហ៊ូទូមួយចំនួនតូចប៉ុណ្ណោះ ។ នៅអំឡុងសតវត្សទី១៩ ប្រព័ន្ធនេះក៏ត្រូវបានលុបបំបាត់ចោលដោយសារការទិញដូរដីធ្លីនិងកម្មសិទ្ធិដីធ្លី ។ នៅមុនសតវត្សរ៍ទី១៩ ការគ្រប់គ្រងដីធ្លីគឺស្ថិតនៅលើសែស្រឡាយគ្រួសារដែលបានរានយកដី ។ កាលពីដើមឡើយនៅប្រទេសរ៉ាន់ដា ម្ចាស់កម្មសិទ្ធិដីធ្លីជាច្រើនជាជនជាតិហ៊ូទូ ។ ប៉ុន្តែនៅពាក់កណ្តាលដំបូងនៃសតវត្សរ៍ទី១៩ ការគ្រប់គ្រងលើដីធ្លីត្រូវបានផ្លាស់ប្តូរមកឲ្យស្តេចទុតស៊ីដែលក្រោយមកបានផ្តល់កម្មសិទ្ធិគ្រប់គ្រងដីធ្លីឲ្យប្រជាជនទុតស៊ីរបស់ខ្លួន ។ តាមរយៈវិធីនេះ កសិករជនជាតិហ៊ូទូជាច្រើនបានបាត់បង់សិទ្ធិកាន់កាប់ដីធ្លីឲ្យទៅជនដែលចាត់ទុកថាជា«ក្រុមទុតស៊ី» ។

ការបន្ទុះបង្អាប់ក្រុមហ៊ូទូមានសភាពកាន់តែខ្លាំងក្លាទៅៗនៅក្នុងអំឡុងរជ្ជកាលស្តេច រ៉ាប៊ូហ្គីរី (ឆ្នាំ១៨៦០-១៨៩៥) ។ រ៉ាប៊ូហ្គីរី បានដាក់ឈ្មោះក្រុមហ៊ូទូដែលមានកម្មសិទ្ធិដីធ្លីថាជាទុតស៊ី និងលុបបំបាត់ចោលអំណាចនៃការគ្រប់គ្រងដីធ្លីតាមរយៈសែស្រឡាយរបស់ក្រុមហ៊ូទូ ។ ស្តេចអង្គនេះក៏បានបង្កើតឲ្យមានសេវាកម្មពលកម្មហៅថា «អ៊ូប៊ូរេត្វា» ដែលប្រជាជនហ៊ូទូត្រូវបង្ខំឲ្យធ្វើការបម្រើចៅហ្វាយនាយទុតស៊ីដើម្បីបានមកវិញនូវដីដែលខ្លួនបានបាត់បង់ ។ បញ្ហានេះបានបណ្តាលឲ្យជនជាតិហ៊ូទូជាពិសេសអ្នកក្រីក្រ ត្រូវជាប់បំណុលពលកម្មពីរឬបីថ្ងៃក្នុងចំណោម៦ថ្ងៃ ។ មកដល់ចុងសតវត្សរ៍ទី១៩ កសិករជនជាតិហ៊ូទូពាក់កណ្តាលនៅកណ្តាលភាគខាងត្បូងប្រទេសរ៉ាន់ដាត្រូវបានបង្ខំឲ្យលក់កម្លាំងពលកម្មជាប្រចាំ ។ នៅទីបំផុត សេវាកម្ម«អ៊ូប៊ូរេត្វា» បានកាត់បន្ថយកម្មសិទ្ធិរបស់ហ៊ូទូក្នុងការគ្រប់គ្រងដីធ្លី និងបានបង្កើតការចាត់ទុកជនជាតិហ៊ូទូទាំងមូលដូចជាខ្ញុំកញ្ជះដាច់ថ្លៃ ។ ដូចដែល មាំដានី បានលើកឡើង «ក្នុងនាមជាទុតស៊ីគឺមានអំណាចនៅក្បែរៗអ្នកមានអំណាច ឬត្រូវកំណត់ជាមនុស្សដែលមានអំណាច ប៉ុន្តែផ្ទុយទៅវិញ ក្នុងនាមជាហ៊ូទូគឺជាប្រជាជនធម្មតាសុទ្ធសាធ» ។ ដូច្នេះហើយ ប្រវត្តិរបស់ក្រុមហ៊ូទូនៅក្នុងប្រវត្តិ-សាស្ត្ររ៉ាន់ដា និងការភ័យខ្លាចចំពោះការវិលត្រឡប់ទៅរកសភាពជាទាសករក្រោមការគ្រប់គ្រងរបស់ទុតស៊ី គឺពិតជាប្រវត្តិសាស្ត្រដ៏មានសារសំខាន់ ។

ជាការពិត តួនាទីដ៏សំខាន់របស់អាណានិគមអឺរ៉ុបក្នុងការបែងចែកជាតិពន្ធុនៅរ៉ាន់ដាមិនអាចត្រូវបានមើលរំលងនោះទេ ។ ថ្វីដ្បិតតែវាមានកម្រិតបន្តិចបន្តួចក៏ពិតមែន ប៉ុន្តែបម្រែបម្រួលសង្គមនៅមុនពេលមានអាណានិគមមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងសង្គម គំនិត និងនយោបាយ នៅប្រទេសរ៉ាន់ដា ។ ពីដំបូងឡើយរដ្ឋបាលថ្នាក់ទាបៗជាច្រើនសុទ្ធសឹងតែមានជនជាតិហ៊ូទូជាអ្នកតំណាង ។ នៅពេលដែលប្រទេសអាល្លឺម៉ង់និងបែលហ្ស៊ិកបានដាក់អាណានិគមលើរ៉ាន់ដា សូម្បីតែអំណាចដ៏ស្តួចស្តើងរបស់ជនជាតិហ៊ូទូក៏ត្រូវបានបំផ្លាញដែរ ។ ដោយផ្អែកទៅលើគំនិតថាខ្លួនជាក្រុមប្រសើរជាងដោយសារពណ៌សម្បុរស្បែក ទាំងអាល្លឺម៉ង់និងបែលហ្ស៊ិកបានចាត់ទុកទុតស៊ីជាជនជាតិស្បែកខ្មៅជាន់ខ្ពស់ដោយសារទុតស៊ីមានរូបរាងខ្ពស់ស្បែកសម្បុរជ្រះនិងមុខមាត់ស្អាតបាត ប្រហាក់ប្រហែលនឹងជនជាតិខ្លួនដែរ ។ អាណានិគមទាំងពីរនេះក៏តម្រូវឲ្យសិស្សដែលដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យត្រូវតែជាប់ការប្រលងវាស់កម្ពស់ថែមទៀត ។ លើសពីនេះបែលហ្ស៊ិក (ពីឆ្នាំ១៩១៦ដល់ឆ្នាំ១៩៦២) ក៏បានបង្កើតប្រព័ន្ធរើសអើងជាតិសាសន៍រវាងក្រុមហ៊ូទូនិងទុតស៊ីតាមរយៈការបង្កើតប័ណ្ណសម្គាល់ខ្លួន ។ ការណ៍នេះទុតស៊ីបន្ថែមទម្ងន់គំនាបមកលើក្រុមហ៊ូទូកាន់តែធ្ងន់ថែមទៀត ។ ដោយសារមូល-

ហេតុនេះហើយបានជាទុតស៊ីដែលមានឋានៈខ្ពស់ៗនិងបានគ្រប់គ្រងផ្តាច់មុខលើអំណាចនយោបាយ ច្បាប់អាជ្ញាធរ ការអប់រំ និងឱកាសស្វែងរកការងារ ។ ជាលទ្ធផលអាណានិគមនេះបានធ្វើឲ្យក្រុមទុតស៊ីកាន់តែមានភាពជាអ្នកគ្រប់គ្រងបន្ថែមទៀត ព្រមទាំងបានបណ្តាលឲ្យជនជាតិហ៊ូទូស្អប់ខ្ពើមនិងចងកំហឹងចំពោះជនជាតិទុតស៊ីកាន់តែខ្លាំង ។ ជាការពិត កេរដំណែលដែលអាណានិគមបន្សល់ទុកនៅប្រទេសរ៉ាន់ដា គឺការបែងចែករវាងក្រុមជាតិពន្ធទាំងពីរដោយយោងទៅលើពណ៌សម្បុរ ហើយការបែងចែកនោះគឺថាហ៊ូទូជាជនជាតិដើមដែលមានចំនួនច្រើនលើសលុបនិងទុតស៊ីជាជនបញ្ចើភាគតិចប៉ុណ្ណោះ ។

ក៏ប៉ុន្តែ ចាំបាច់ត្រូវតែកត់សម្គាល់ថា អំណាចអាណានិគមនេះមិនបានបង្កើតឲ្យមានភាពរើសអើងទាំងស្រុងទេ ។ តាមការពិតទៅអាណានិគមនេះគ្រាន់តែបង្កើនភាពរើសអើងដែលមានស្រាប់នៅក្នុងសង្គមនេះតែប៉ុណ្ណោះ ។ លើសពីនេះ យើងក៏គួរតែទទួលស្គាល់ថាមានអ្នកចេះដឹងទុតស៊ីជាច្រើននាក់ដែលបម្រើការងារនៅក្នុងកម្មវិធីផ្សេងៗរបស់អាណានិគមនេះ ។ ជាឧទាហរណ៍ នៅពេលអាល្លឺម៉ង់បានសម្រេចឲ្យមានការគ្រប់គ្រងរ៉ាន់ដាដោយស្តេចជនជាតិទុតស៊ី ដើម្បីបង្កភាពងាយស្រួលសម្រាប់រដ្ឋបាលរបស់ខ្លួននោះ រាជាទុតស៊ីក៏បានទាញយកផលប្រយោជន៍តាមរយៈការប្រើកម្លាំងរបស់អាល្លឺម៉ង់មកពង្រីងមុខតំណែងរបស់ខ្លួនដែរ ។ ក្រុមទុតស៊ីថែមទាំងប្រើប្រាស់អាវុធដែលឧបត្ថម្ភដោយអាល្លឺម៉ង់សម្រាប់ទប់ទល់នឹងការប្រឆាំងរបស់ជនជាតិហ៊ូទូទៀតផង ។ ជារួម នៅពេលដែលអាណានិគមបានបង្កឲ្យមានពន្លកនៃការស្អប់ខ្ពើមនិងកំហឹងនៅក្នុងសង្គមរ៉ាន់ដា «រណសិរ្សស្នេហាជាតិរ៉ាន់ដា»ដែលយល់ឃើញថាប្រទេសរ៉ាន់ដាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាតិទុតស៊ីនោះ មិនត្រឹមតែមិនយកចិត្តទុកដាក់ចំពោះការគាបសង្កត់មកលើប្រជាជនហ៊ូទូនៅមុនពេលដាក់អាណានិគមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនបានអើពើចំពោះប្រវត្តិសាស្ត្រនិងគុណធម៌របស់ជនជាតិទុតស៊ីដែលមានតួនាទីជាអ្នកគ្រប់គ្រងនៅក្នុងអំឡុងពេលអាណានិគមទៀតផង ។

### ៣) មរតកនៃបដិវត្តន៍ឆ្នាំ១៩៥៩និងការបង្កើតសាធារណរដ្ឋទីមួយ

ការយល់ដឹងអំពីការចងចាំប្រវត្តិសាស្ត្ររបស់ជនជាតិហ៊ូទូអំពីការរើសអើងពូជសាសន៍ទាំងនៅមុននិងអំឡុងពេលមានអាណានិគមនៅរ៉ាន់ដា បាននាំឲ្យមានចម្លល់ចំពោះភាពស្របច្បាប់នៃបដិវត្តន៍របស់ជនជាតិហ៊ូទូនៅក្នុងឆ្នាំ១៩៥៩ ។ បដិវត្តន៍ឆ្នាំ១៩៥៩គឺជាពេលវេលាដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្ររ៉ាន់ដាដែលប្រជាជនថ្នាក់កណ្តាលទាំងពីរក្រុមមានការចងចាំផ្ទុយស្រឡះពីគ្នានិងយល់ឃើញថាក្រុមទាំងពីរជាសត្រូវយ៉ាងប្តូរផ្តាច់ ។ នៅពេលជនជាតិទុតស៊ីចងចាំថា អំឡុងពេលមានអាណានិគមនៅរ៉ាន់ដាជាពេលដែលក្រុមខ្លួនអាចប្រែក្លាយទៅជាប្រជាជនឋានៈកណ្តាលនោះ ជនជាតិហ៊ូទូបែរជាចងចាំថា បដិវត្តន៍ជាពេលដែលខ្លួនរួចផុតពីគំនាបអាណានិគមនិងភាពជាទាសករ ។ ដូច្នេះការពិចារណាអំពីការយល់ឃើញទៅលើបដិវត្តន៍ មិនថាចំពោះប្រជាជនហ៊ូទូឬទុតស៊ី គឺមានសារសំខាន់ក្នុងការបង្កើតឲ្យមានប្រវត្តិសាស្ត្រទូទៅតែមួយរបស់ប្រទេសរ៉ាន់ដា ។

ថ្វីដ្បិតតែរដ្ឋាភិបាលដែលដឹកនាំដោយ «រណសិរ្សស្នេហាជាតិរ៉ាន់ដា» ចាត់ទុកបដិវត្តន៍ជាការប្រឆាំងនឹងប្រជាជនទុតស៊ីក៏ដោយ ក៏យើងគួរដឹងថា បដិវត្តន៍នេះហើយដែលបានផ្តល់សិទ្ធិសេរីភាពជាច្រើនចំពោះការប្រើប្រាស់កម្លាំងពលកម្មនិងការគ្រប់គ្រងលើការបែងចែកទឹកដីនៅរ៉ាន់ដា ។ និយាយម្យ៉ាងបដិវត្តន៍គឺស្ទើរតែជាការឆ្លើយតបមួយមិនអាចចៀសវាងបានរបស់ជនជាតិហ៊ូទូ ។ នៅពេលដែលមានការទទួលស្គាល់ឯករាជ្យនៅរ៉ាន់ដា «ក្រុមប្រឹក្សាជាន់ខ្ពស់» ដែលដឹកនាំដោយជនជាតិទុតស៊ីមិនបានលាក់បាំងគោលបំណងរបស់ខ្លួនក្នុងការគ្រប់គ្រងអំណាចនៅរ៉ាន់ដាជានិរន្តរ៍នោះទេ គឺក្រុមនេះបានកោះហៅជនទុតស៊ីដែលមានឋានៈសង្គមខ្ពស់មកចូលរួមការហ៊ឹកហ៊ឺនជាបន្ទាន់មួយដើម្បីគ្រប់គ្រងរដ្ឋាភិបាល ។ ដើម្បីទប់ស្កាត់សភាពការណ៍នេះ អ្នកដឹកនាំហ៊ូទូជាច្រើនបានធ្វើសេចក្តីប្រកាស «បាហ៊ូទូ» ជាសាធារណៈ និងរិះរកវិធីបញ្ចប់ការគ្រប់គ្រងផ្តាច់មុខរបស់ក្រុមទុតស៊ីមកលើឯករាជ្យរ៉ាន់ដាបន្តទៅទៀត ។ នៅពេលដែលជនជាតិហ៊ូទូចាប់ផ្តើមរើបម្រះនៅឆ្នាំ១៩៥៩ ជនជាតិទុតស៊ីនៅតែព្យាយាមគ្រប់គ្រងអំណាចតាមរយៈការសម្លាប់ជនជាតិហ៊ូទូទាំង

ឡាយដែលប្រឆាំងនឹងក្រុមខ្លួន ។ នៅទីបំផុត ជនជាតិហ៊ូទូដែលជាក្រុមគណបក្សជ្រុលនិយមឈ្មោះថា «ផាមេហ៊ូទូ» បានវាយដណ្តើមយកអំណាចពីប្រជាជនទុតស៊ីបានទាំងស្រុង រហូតដល់ទុតស៊ីជាច្រើនរយពាន់នាក់បានភៀសខ្លួនទៅនៅប្រទេសជិតខាង ។

យោងតាមប្រភពពត៌មានពី«អង្គការឃ្លាំមើលសិទ្ធិមនុស្ស» ការធ្វើបដិវត្តន៍នេះបានបង្កឲ្យបាត់បង់ជីវិតជនជាតិទុតស៊ីពីរម៉ឺននាក់ ដែលជាមូលហេតុនៃការកើតមានអំពើឧក្រិដ្ឋកម្មនៅប្រទេសរ៉្វាន់ដា ។ តាមការពិត អ្វីដែលផ្តល់ទ្រង់ទ្រាយនយោបាយសម្រាប់អនាគតរ៉្វាន់ដាមិនមែនមកពីបដិវត្តន៍នោះទេ វាជាការឆ្លើយតបដ៏យោយៅនៃសាធារណរដ្ឋទីមួយចំពោះការប៉ុនប៉ងរបស់ក្រុមទុតស៊ីក្នុងការដណ្តើមយកអំណាចត្រឡប់មកវិញប៉ុណ្ណោះ ។ ដើម្បីឲ្យការគ្រប់គ្រងអំណាចរបស់ខ្លួនត្រឹមត្រូវតាមច្បាប់ បក្សសាធារណរដ្ឋ«ផាមេហ៊ូទូ»បានដាក់ឲ្យប្រើប្រាស់នូវច្បាប់ជាតិពន្ធនិងដាក់ការគាបសង្កត់បន្ថែមទៅលើក្រុមទុតស៊ី ។ ប្រជាជនថ្នាក់មូលដ្ឋានក៏ត្រូវប្រើប្រាស់ច្បាប់ទាំងអស់នេះដែរ ។ នៅចន្លោះឆ្នាំ១៩៦១និងឆ្នាំ១៩៦៦ ក្រុមទាហានទុតស៊ីជាច្រើនបានបើកការវាយប្រហារធំៗចំនួន១០លើកពីប្រទេសអ៊ុយហ្កាន់ដា តង់ហ្សានីប៊ូរុនឌី និងហ្សាអៀ ។ បន្ទាប់ពីការវាយប្រហារម្តងៗ បក្សសាធារណរដ្ឋ «ផាមេហ៊ូទូ» ពង្រឹងយុទ្ធនាការប្រឆាំងនឹងទុតស៊ីកាន់តែខ្លាំងឡើង ។ លើសពីនេះទៅទៀត ការកាប់សម្លាប់ជនជាតិទុតស៊ីនៅប្រទេសប៊ូរុនឌីដែលនៅជិតខាង បានធ្វើឲ្យជនជាតិទុតស៊ីនៅក្នុងប្រទេសរ៉្វាន់ដាចលាចលកាន់តែខ្លាំងឡើងៗ ។ ដូចជាអ្វីដែលបានកើតឡើងនៅក្នុងប្រទេសរ៉្វាន់ដាដែរ ជនជាតិទុតស៊ីរស់នៅក្នុងប្រទេសប៊ូរុនឌីក៏បានគ្រប់គ្រងអំណាចផ្តាច់មុខលើជនជាតិហ៊ូទូដែលមានសមាជិកច្រើនជាងជាយូរយារណាស់មកហើយដែរ(ជនទាំងពីរនេះជាជនបរទេសរស់នៅក្នុងប្រទេសប៊ូរុនឌី) ។ ប៉ុន្តែនៅចុងទសវត្សរ៍ឆ្នាំ១៩៦០និងឆ្នាំ១៩៧០ តំណែងដែលកាន់កាប់ដោយទុតស៊ីកាន់តែចុះខ្សោយទៅៗខណៈពេលដែលការប្រឆាំងរបស់ក្រុមហ៊ូទូកាន់តែមានសភាពខ្លាំងក្លាឡើង ។ ដើម្បីទប់ស្កាត់ការរីកដុះដាលនេះ ក្រុមទុតស៊ីដែលរស់នៅប្រទេសប៊ូរុនឌីបានសម្លាប់អ្នកចេះដឹងនិងសិស្សសាលាជាជនជាតិហ៊ូទូអស់ជាងម្ភៃប្រាំម៉ឺននាក់ក្នុងរយៈពេលប្រហែល៣ខែនៅក្នុងឆ្នាំ១៩៧២ ។ ឆ្លើយតបនឹងឧក្រិដ្ឋកម្មនេះគឺការកើនឡើងនៃកំហឹងយ៉ាងពុះកញ្ជ្រោលរបស់ក្រុមហ៊ូទូនៅរ៉្វាន់ដា ។ ការទប់ទល់ចំពោះភាពចលាចលនេះមានឥទ្ធិពលយ៉ាងខ្លាំងរហូតដល់ធ្វើឲ្យបក្សសាធារណរដ្ឋ«ផាមេហ៊ូទូ»ដួលរលំបន្ទាប់ពីមានរដ្ឋប្រហារមួយដែលធ្វើឡើងដោយ ហាប៊ីយ៉ារីម៉ាណា ។

ប៉ុន្តែទោះបីជាយើងទទួលស្គាល់សភាពដ៏គួរឲ្យសោកសង្រេងរបស់ក្រុមហ៊ូទូនៅមុននិងក្នុងអំឡុងពេលអាណានិគម ដែលក្នុងនោះរួមមានប្រវត្តិសាស្ត្រនៃបដិវត្តន៍និងការគំរាមកំហែងសន្តិសុខដែលសាធារណរដ្ឋទីមួយបានជួបប្រទះក៏ដោយ ក៏យើងមិនត្រូវគិតថាអំពើហិង្សាដែលបង្កឡើងដោយជាតិពន្ធទាំងពីរនេះនៅអំឡុងពេលសាធារណរដ្ឋដំបូងនៅរ៉្វាន់ដាគឺជាលទ្ធផលមិនអាចចៀសវាងបាននៃប្រវត្តិសាស្ត្រស្អប់ខ្ពើមរវាងគ្នានៃជាតិពន្ធទាំងពីរ ។ បើយើងក្រឡេកមើលទៅក្រោយវិញ បដិវត្តន៍ឆ្នាំ១៩៥៩និងការបង្កើតរបបសាធារណរដ្ឋទីមួយនៅឆ្នាំ១៩៦២ក៏អាចចាត់ទុកថាជាចំណុចរបត់វិជ្ជមានមួយនៅក្នុងប្រវត្តិសាស្ត្ររ៉្វាន់ដាដោយសារថាបដិវត្តន៍នេះបានបញ្ចប់បុព្វសិទ្ធិរបស់ក្រុមទុតស៊ីនិងបានបង្កើតជាសញ្ញាតិរួមមួយសម្រាប់រ៉្វាន់ដាដែលឯករាជ្យ ។ សាធារណរដ្ឋទីមួយមិនបានជួយដោះស្រាយមត៌កនៃអាណានិគមទេ ផ្ទុយទៅវិញបានបង្កឲ្យការរើសអើងជាតិពន្ធនៅរ៉្វាន់ដាមានសភាពកាន់តែអាក្រក់ថែមទៀត ។ ជាឧទាហរណ៍ការប្រកាសឯករាជ្យនៃក្រុមហ៊ូទូនៅឆ្នាំ១៩៥៩ត្រូវបានហៅថា «សេចក្តីប្រកាសឯករាជ្យបាហ៊ូទូ» មិនមែន «សេចក្តីប្រកាសឯករាជ្យរ៉្វាន់ដា»ទេ ។ ឯកសារនេះបានបញ្ជាក់ថា ឫសគល់នៃជម្លោះនៅរ៉្វាន់ដាគឺបណ្តាលមកពីជម្លោះរវាងក្រុមហ៊ូទូនិង«ហាមីទិក» ដែលជាក្រុមទុតស៊ីបរទេស ។ ជម្លោះនេះតម្រូវឲ្យមានការរំដោះក្រុមហ៊ូទូដល់ទៅពីរដង ទីមួយគឺត្រូវរំដោះក្រុមហ៊ូទូចេញពីក្រុមហាមីត (ក្រុមរបស់ទុតស៊ី) និងទីពីរចេញពីក្រុមអាណានិគមស្បែកសដែលហៅថា «បាហ្សុងហ្គូ» ។ ម្យ៉ាងវិញទៀត សាធារណរដ្ឋទីមួយបានបង្វែរគោលការណ៍ស្វែងរកយុត្តិធម៌មកជាការបង្កឲ្យមានអំពើហិង្សាទៅវិញ ។ នៅក្នុងប្រទេសរ៉្វាន់ដាចាប់ពីឆ្នាំ១៩៥៩មក

ជនជាតិទុតស៊ីមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសកម្មភាពនយោបាយក្នុងនាមជាប្រជាជនរ៉្វាន់ដាទេ ហើយអ្នកដែលនៅតែព្យាយាមប្រឡូកនៅក្នុងសកម្មភាពនយោបាយនឹងត្រូវបង្ក្រាបឬក៏ត្រូវសម្លាប់ចោលមិនថាជននោះមានទឹកចិត្តប្រឹងប្រែងប៉ុនណាទេ ។ «ដាមេហ៊ូទូ» រឹតតែខិតខំបែងចែកលក្ខណៈសម្គាល់រវាងក្រុមហ៊ូទូនិងទុតស៊ីបន្ថែមទៀត ដើម្បីប្រើប្រាស់ជាមធ្យោបាយក្នុងការពង្រឹងនិងធ្វើឲ្យអំណាចគ្រប់គ្រងរបស់ខ្លួនមានលក្ខណៈស្របច្បាប់ ។ នៅទីបំផុត អ្នកដឹកនាំនយោបាយហ៊ូទូបានដាក់មកគ្រប់គ្រងអំណាចផ្តាច់មុខនិងបង្កើតឲ្យមានសង្គមរើសអើងជាតិសាសន៍មួយបន្ទាប់ពីអាណានិគមនៅរ៉្វាន់ដា ។

ដូចជានៅក្នុងរបបផ្សេងៗដែរ បន្ទាប់ពីរបបអាណានិគមនិយមបានបញ្ចប់សាធារណរដ្ឋទីមួយរបស់រ៉្វាន់ដាមិនបានផ្តល់អ្វីដែលខ្លួនបានសន្យាថាដល់ប្រជាជនឡើយ ។ ទន្ទឹមនឹងវិបត្តិសេដ្ឋកិច្ចដែលចេះតែកើតមានជាបន្តបន្ទាប់ ការគាបសង្កត់លើក្រុមទុតស៊ីបានបង្កបញ្ហាដល់សង្គមយ៉ាងមហិមានិងមិនចេះឈប់ឈរ ។ ដូច្នេះហើយបានជានៅពេលដែលប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា បង្កើតសាធារណរដ្ឋទីពីរនៅឆ្នាំ១៩៧២ គាត់បានបូកបញ្ចូលការផ្សះផ្សាជាតិជាមួយនឹងដំណើរការស្វែងរកយុត្តិធម៌នៅក្នុងប្រទេសរ៉្វាន់ដា ដោយសារគាត់យល់យ៉ាងច្បាស់អំពីមូលហេតុបង្កអំពើហិង្សានៅប្រទេសរ៉្វាន់ដា ។ អ្វីដែលជាជំហានដំបូងរបស់របបហាប៊ីយ៉ារីម៉ាណាគឺការផ្លាស់ប្តូរនិយមន័យរបស់«ក្រុមទុតស៊ី»ពី«ជាតិសាសន៍មិនមែនជាជនជាតិដើម (ជនបរទេស)» ទៅជាជាតិសាសន៍ដើមភាគតិចព្រមទាំងបានចាប់ផ្តើមពិភាក្សាថា សិទ្ធិរបស់ក្រុមទុតស៊ីជា«សិទ្ធិរបស់ក្រុមជនជាតិភាគតិច»ដែរ ។ ការផ្លាស់ប្តូរ«ភាសានយោបាយ» ចំពោះការឲ្យនិយមន័យនេះមានអត្ថ-ប្រយោជន៍ជាច្រើនដោយសារ និយមន័យនេះបានបញ្ជាក់ថាក្រុមទុតស៊ីត្រូវបានទទួលស្គាល់ជាសមាជិកស្របច្បាប់នៅក្នុងសង្គមរ៉្វាន់ដា ។ អាចនិយាយម្យ៉ាងទៀតថា របបនោះបានទទួលស្គាល់វត្តមាននៃបញ្ហានយោបាយជាទូទៅរួមគ្នាពីអតីតកាល បច្ចុប្បន្ននិងអនាគតសម្រាប់ក្រុមទុតស៊ីនិងហ៊ូទូ ។ ក៏ប៉ុន្តែក្តីសង្ឃឹមនៃការផ្សះផ្សាជាតិមានអាយុកាលមិនយូរអង្វែងឡើយ ។ ចុងក្រោយបំផុត របបហាប៊ីយ៉ារីម៉ាណាសម្រេចចិត្តជ្រើសរើសយក«អំពើប្រល័យពូជសាសន៍»ជាវិធីសាស្ត្រសមហេតុសមផលក្នុងការសម្រេចឲ្យបាននូវគោលនយោបាយរបស់ខ្លួន ។ ដើម្បីស្វែងយល់អំពីសាច់រឿងពោរពេញដោយសោកនាដកម្មនៃការប្រែប្រួលនយោបាយរបស់សាធារណរដ្ឋទីពីរនេះ យើងចាំបាច់ត្រូវតែសិក្សាអំពីមូលហេតុនិងការផ្លាស់ប្តូរនៃសង្គ្រាមស៊ីវិលដែលផ្តើមចេញពីការឈ្លានពានរបស់ «រណសិរ្សស្នេហាជាតិ រ៉្វាន់ដា» នៅឆ្នាំ១៩៩០ ។ ដើម្បីសិក្សាអំពីមូលហេតុនៃសង្គ្រាមស៊ីវិល យើងក៏ចាំបាច់ត្រូវមើលឲ្យហួសពីប្រទេសរ៉្វាន់ដាទៀត ពោលគឺក្រឡេកមើលទៅព្រឹត្តិការណ៍វិវត្តន៍នៅផ្ទៃក្នុងនៅប្រទេសអ៊ុយហ្គាន់ដាជាមួយនឹងការចាប់អារម្មណ៍ពិសេសទៅលើជម្លោះផ្នែកសញ្ជាតិនិងសិទ្ធិ ។ ប្រសិនបើមិនសិក្សាលើមូលហេតុនៅតាមតំបន់និងភាពស្មុគស្មាញដែលបង្កឲ្យមានការផ្លាស់ប្តូរព្រឹត្តិការណ៍ផ្ទៃក្នុងរបស់ប្រទេសរ៉្វាន់ដាទេនោះ យើងក៏មិនអាចយល់ពីកត្តាដែលបង្កជាអំពើឧក្រិដ្ឋកម្ម ក៏ដូចជាមិនអាចស្វែងរកវិធីដោះស្រាយបញ្ហាជម្លោះនេះទេ ។

### ៤) វិបត្តិសញ្ជាតិនៅប្រទេសអ៊ុយហ្គាន់ដានិងសង្គ្រាមស៊ីវិល

បន្ទាប់ពីបដិវត្តន៍ឆ្នាំ១៩៥៩រួចមក ក្រុមទុតស៊ីបានភៀសខ្លួនចូលមករស់នៅប្រទេសអ៊ុយហ្គាន់ដានៅក្នុងដំណាក់កាលធំៗបី គឺពីឆ្នាំ១៩៥៩-១៩៦១ ពីឆ្នាំ១៩៦៣-១៩៦៤ និងឆ្នាំ១៩៧៣ ។ មកដល់ឆ្នាំ១៩៩០ មានជនភៀសខ្លួនទុតស៊ីប្រមាណពីរសែននាក់ដែលត្រូវបានហៅថា «បាន់យ៉ារ៉្វាន់ដា» មានន័យថា «អ្នកមកពីរ៉្វាន់ដា» ។ អ្វីដែលសំខាន់នោះគឺថា ជនភៀសខ្លួនទុតស៊ីទាំងនេះត្រូវបានទទួលរាក់ទាក់ជាខ្លាំងពីសំណាក់រាជវង្ស«បាហ៊ីម៉ា»របស់អ៊ុយហ្គាន់ដា ដោយសារធ្លាប់មានទំនាក់ទំនងជិតស្និទ្ធតាំងពីយូរលង់មកហើយ ។ ប្រទេសអ៊ុយហ្គាន់ដាក៏ជាប្រទេសមួយដែលបែកបាក់ជាតិពន្ធដូចជាប្រទេសរ៉្វាន់ដាដែរ ។ ដូចក្រុមទុតស៊ីដែរ ក្រុម«បាហ៊ីម៉ា»នៅអ៊ុយហ្គាន់ដាគឺជាអ្នកគ្រប់គ្រង ចំណែកក្រុម«បាយរូ»វិញគឺប្រៀបដូចជាក្រុមហ៊ូទូដែលជាអ្នកបម្រើ ។ ហេតុដូច្នេះហើយបានជាការមកដល់របស់ជនភៀសខ្លួនទុតស៊ីនៅក្នុងប្រទេសអ៊ុយហ្គាន់ដាបានបង្កបញ្ហាកាន់តែធំឡើងចំពោះ

ប្រទេសដែលកំពុងមានបញ្ហារើសអើងជាតិពន្ធុរួចជាស្រេចទៅហើយ នោះដោយសារក្រុម «បាយរូ»យល់ថាក្រុមទុតស៊ីមកចូលដៃជាមួយក្រុម«បាហ៊ីម៉ា»ដើម្បីដណ្តើមយកទឹកដីបន្តិចបន្តួចដែលខ្លួនកំពុងកាន់កាប់នៅក្នុងប្រទេសអ៊ុយហ្កាន់ដា ។ ប្រជាជនអ៊ុយហ្កាន់ដាដែលមានជីវភាពក្រីក្រក៏មានការច្រណែនឈ្នានីសនិងស្អប់ខ្ពើមពួកជនភៀសខ្លួនទាំងនោះ ដោយគិតថាជនភៀសខ្លួនទាំងនោះជាក្រុមដែលទទួលបានការឧបត្ថម្ភជាពិសេសពីរដ្ឋាភិបាលអ៊ុយហ្កាន់ដា (ក្រុមទុតស៊ីជាច្រើនទទួលបានការឧបត្ថម្ភពីសំណាក់ *UNHCR* ហើយភាគច្រើននៃអ្នកទាំងនេះថែមទាំងមានឱកាសចូលរៀននៅមហាវិទ្យាល័យថែមទៀត) ។

តាមការពិត ស្ថានការណ៍នៃជនភៀសខ្លួនទុតស៊ីមានលក្ខណៈអាក្រក់បំផុតនៅក្នុងតំបន់ ។ មិនដូចអ្វីដែលបានកើតឡើងនៅប្រទេសតង់ហ្សានីនិងហ្សាអៀនោះទេ សូម្បីតែកុមារជំនាន់ក្រោយរបស់ជនភៀសខ្លួនទុតស៊ីទាំងនោះក៏ត្រូវចាត់ទុកថាជាជនភៀសខ្លួនដែរ ហើយកុមារទាំងនោះមិនអាចគេចវេះពីស្លាកស្នាមសង្គមដ៏អាក្រក់នេះបានទេ មិនថាកុមារទាំងនោះបានរៀនសូត្រចេះដឹងខ្ពង់ខ្ពស់និងទទួលបានជោគជ័យប៉ុនណាក៏ដោយ ។ ដោយមូលហេតុត្រូវបានបដិសេធមិនផ្តល់សញ្ជាតិ ជនភៀសខ្លួនទុតស៊ីបានជួបប្រទះស្ថានការណ៍មិននឹងនជាច្រើនក្នុងពេលដែលមានវិបត្តិនយោបាយ ។ នៅទសវត្សរ៍ឆ្នាំ១៩៦០ រដ្ឋាភិបាល «អូបូតេទីមួយ(Obote I)» បានសង្កត់ធ្ងន់លើការធ្វើឲ្យក្លាយទៅជាជនជាតិអ៊ុយហ្កាន់ដា ហើយបានដាក់ឲ្យប្រើច្បាប់ជាច្រើន ឧទាហរណ៍ច្បាប់គ្រប់គ្រងជនភៀសខ្លួន(បរទេស) ដែលច្បាប់ទាំងនេះធ្វើឲ្យប្រជាជនរ្វ៉ាន់ដាស្ថិតក្នុងថ្នាក់ពិសេសមួយដែលប្រឈមមុខនឹងការសួរចម្លើយនិងការឃុំឃាំងដោយគ្មានហេតុផល ។ ហេតុដូច្នេះបានជានៅពេលដែល អាយឌី អាមី ផ្តួលរំលំរបប «អូបូតេ» ក្រុមបាន់យ៉ារ្វ៉ាន់ដាជាច្រើនបានចូលរួមគាំទ្រ អាយឌី អាមី ដោយក្តីរីករាយ ។ ក្រុមនេះថែមទាំងចូលក្នុងជួរទាហាននិងភ្នាក់ងារសម្ងាត់របស់របបអាមី ដោយជឿជាក់ថា អាមីនឹងធ្វើតាមពាក្យសន្យាក្នុងការជួយបង្កើតឲ្យមានរាជវង្សទុតស៊ីគ្រប់គ្រងនៅរ្វ៉ាន់ដាសាជាថ្មី ដែលនេះនឹងអាចឲ្យជនភៀសខ្លួនទុតស៊ីទាំងអស់វិលត្រឡប់ទៅរ្វ៉ាន់ដាវិញ ។ ប៉ុន្តែនៅក្នុងរបបថ្មីជីវិតជនភៀសខ្លួនទុតស៊ីភាគច្រើនមិនបានប្រសើរអ្វីឡើយ ។ ផ្ទុយទៅវិញ ការចូលរួមក្នុងរបបអាមីនេះ បែរជាទទួលបាននូវការស្អប់ខ្ពើមពីប្រជាជនអ៊ុយហ្កាន់ដាដែលសង្ស័យប្រជាជនទុតស៊ីទាំងនេះថាជាសត្រូវផ្ទៃក្នុង ហើយសភាពការណ៍បែបនេះបានបណ្តាលឲ្យជីវភាពរបស់ជនភៀសខ្លួនទុតស៊ីរឹតតែមានភាពលំបាកលំបិនថែមមួយកម្រិតទៀត ។

បន្ទាប់ពីការវិលត្រឡប់មកវិញរបស់របបអូបូតេនៅឆ្នាំ១៩៨០ ជនភៀសខ្លួនបាន់យ៉ារ្វ៉ាន់ដាជាច្រើនរូបបានចូលរួមនៅក្នុងសង្គ្រាមឈ្លបរបស់ម៉ូសេវេនី ដើម្បីវាយប្រឆាំងនឹងរបបអូបូតេទី២ (Obote II) ។ នេះស្ទើរតែក្លាយទៅជាការឆ្លើយតបយ៉ាងសាមញ្ញមួយសម្រាប់ជនភៀសខ្លួនទាំងនេះ ដោយសារខ្លួនចងចាំយ៉ាងច្បាស់នូវស្ថានការណ៍ដ៏លំបាកលំបិនដែលធ្លាប់បានប្រឈមមុខនៅក្នុងអំឡុងរបបអូបេតេទី១ ។ ហេតុការណ៍បន្ទាប់មកទៀតគឺរបបអូបេតេទី២ បានចាត់ទុកបាន់យ៉ារ្វ៉ាន់ដាជាទាហានរបស់ម៉ូសេវេនី ហើយបានបង្កើនការគាបសង្កត់លើក្រុមទាំងនេះ ។ នៅឆ្នាំ១៩៨២ ដោយមានជំនួយពីអាជ្ញាធរក្នុងស្រុកនិងយុវជនយោធាឆ្វេងនិយម រដ្ឋាភិបាលប្រទេសអ៊ុយហ្កាន់ដាចាប់ផ្តើមកាប់សម្លាប់យ៉ាងរង្គាល ឆក់ប្លន់យកទ្រព្យសម្បត្តិ និងវាយបណ្តេញក្រុមបាន់យ៉ារ្វ៉ាន់ដាមិនថាជាពលរដ្ឋឬជនភៀសខ្លួនរ្វ៉ាន់ដានោះទេ ។ ក្នុងរយៈកាលតែមួយឆ្នាំប៉ុណ្ណោះ ស្ថានការណ៍នេះបានបំផ្លិចបំផ្លាញគោចំនួនបួនម៉ឺនក្បាល ផ្ទះសម្បែងចំនួនមួយម៉ឺនប្រាំមួយពាន់ និងបណ្តេញជនភៀសខ្លួនចំនួនបួនម៉ឺននាក់ ។ នៅពេលអំណាចនយោបាយរបស់«គណបក្សសមាជប្រជាជនអ៊ុយហ្កាន់ដា»(Uganda People's Congress)របស់របបអូបេតេកាន់តែចុះខ្សោយនោះ របបនេះកាន់តែបន្ថែមការធ្វើទុក្ខបុកម្នេញទៅលើក្រុមទុតស៊ីបន្ថែមទៀត ។ នៅពេលដែលស្ថានការណ៍កាន់តែនោះអាក្រក់បែបនេះ ជនភៀសខ្លួនបាន់យ៉ារ្វ៉ាន់ដាកាន់តែច្រើនចូលរួមសហការណ៍ជាមួយក្រុមម៉ូសេវេនី ។ ជាលទ្ធផលនៅដំណាក់កាលចុងក្រោយដែលកងកម្លាំងតស៊ូជាតិរបស់ក្រុមម៉ូសេវេនី (National Resistance Army) បានវាយយកអំណាចនៅកាំប៉ាឡា

[រដ្ឋធានីរបស់ប្រទេសអ៊ុយហ្កាន់ដា]នៅខែមករា ឆ្នាំ១៩៨៦ បាន់យ៉ារ៉្វាន់ដាកាន់តំណែងស្មើរតែមួយភាគបួននៃការគ្រប់គ្រងទាំងមូលរបស់របបនេះ ក្នុងនោះនាយទាហានជាន់ខ្ពស់ជាច្រើនរួមមាន ហ្វ្រិដ រីកយេមុ និង ប៉ូល កាហ្គាមេ ក្លាយទៅជាអ្នកដឹកនាំប្រទេសរ៉្វាន់ដានៅសម័យក្រោយអំពើប្រល័យពូជសាសន៍ ។

រយៈពេលប៉ុន្មានឆ្នាំដំបូងនៃរបបហាប៊ីយ៉ារីម៉ាណា កងកម្លាំងតស៊ូជាតិបានខ្នះខ្នែងឲ្យនិយមន័យសិទ្ធិជាពលរដ្ឋស្មើភាពគ្នាជាជាងចាត់ទុកថាក្រុមណាជាម្ចាស់ទឹកដីឬជាជនបរទេស ។ របបនេះក៏បានព្យាយាមបង្កើតឲ្យមានរដ្ឋាភិបាលមួយដែលមានលក្ខណៈទូលំទូលាយ ។ ប្រសិនបើការណ៍នេះពិតជាបានជោគជ័យមែន កំណែទម្រង់បែបនេះប្រាកដជានឹងអាចធានានូវអនាគតនយោបាយសម្រាប់ជនភៀសខ្លួនរ៉្វាន់ដានៅក្នុងប្រទេសអ៊ុយហ្កាន់ដាមិនខាន ។ ប៉ុន្តែ អ្នកនយោបាយជាច្រើននៅក្នុងគណបក្សប្រឆាំងបានប្រើប្រាស់អារម្មណ៍ប្រឆាំងរបស់ខ្លួនចំពោះក្រុមបាន់យ៉ារ៉្វាន់ដាដើម្បីជាលេសយកផលប្រយោជន៍ផ្ទាល់ខ្លួននិងទាមទារថា ប្រជាជនអ៊ុយហ្កាន់ដាដែលជាប្រជាជនដើមនោះត្រូវតែមានអាទិភាពច្រើនជាងនៅក្នុងការគ្រប់គ្រងនយោបាយនៅក្នុងរបបថ្មីនេះ ។ ជាលទ្ធផល ឧត្តមសេនីយ៍របស់បាន់យ៉ារ៉្វាន់ដាជាច្រើនរូបនៅក្នុងរបបថ្មីនេះត្រូវបានបណ្តេញចេញពីមុខតំណែងជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៨៦ ។ បន្ទាប់ពីស្ថានការណ៍ដ៏លំបាកនេះ គឺជាការចាប់កំណើតរបស់«រណសិរ្សស្នេហាជាតិរ៉្វាន់ដា»នៅឆ្នាំ១៩៨៧ ដើម្បីធានាការរស់រានជីវិតនយោបាយរបស់បាន់យ៉ារ៉្វាន់ដានៅក្នុងតំបន់ហ្គ្រេតឡេក ។ ថ្វីដ្បិតថាមេដឹកនាំនៃក្រុមនេះគឺជាជាតិពន្ធហ៊ូទូក្តី ប៉ុន្តែក៏មានសមាជិកក្រុមទុតស៊ីនៅអ៊ុយហ្កាន់ដាដែរ ជាពិសេសអតីតសមាជិកក្រុមបក្សប្រឆាំងជាតិ ។

បន្ទាប់មកតើ«រណសិរ្សស្នេហាជាតិរ៉្វាន់ដា»ឈានទៅដល់សេចក្តីសន្និដ្ឋានចុងក្រោយថាការសង្គ្រោះតែមួយគត់គឺស្ថិតនៅលើការវិលត្រឡប់ទៅរកការតស៊ូប្រដាប់អាវុធនៅរ៉្វាន់ដាវិញដោយរបៀបណា? មូលហេតុគឺមកពីក្រុមម្ចាស់កសិដ្ឋានដែលជាប្រជាជនដើមរស់នៅភាគខាងត្បូងនៃប្រទេសអ៊ុយហ្កាន់ដាបានបះបោរប្រឆាំងនឹងរដ្ឋាភិបាលដែលគេមើលឃើញថាកាន់ជើងម្ចាស់កសិដ្ឋានជាជនបរទេសបាន់យ៉ារ៉្វាន់ដាទៅវិញនោះ ។ ដើម្បីធ្វើឲ្យម៉ូសេវេនីចុះខ្សោយ គណបក្សប្រឆាំងបានលើកយកបញ្ហាជាតិពន្ធនិងភាពជាម្ចាស់ទឹកដីមកធ្វើជាប្រធានបទពិភាក្សានយោបាយ ។ ដោយសារការគាបសង្កត់ចំពោះបញ្ហានេះ ម៉ូសេវេនី ក៏បានលុបចោលការទទួលស្គាល់សញ្ជាតិដូចគ្នាពីក្រុមបាន់យ៉ារ៉្វាន់ដាហើយបានដាក់ឈ្មោះក្រុមនេះជាជនបរទេសសាជាថ្មីម្តងទៀត ។ មុំដានី បានបកស្រាយថា «ផលវិបាកភ្លាមៗនៃការបះបោរដែលធ្វើឡើងដោយម្ចាស់កសិដ្ឋានទាំងនោះ គឺដើម្បីឲ្យមានភាពស្មើគ្នាចំពោះគំនិតនេះនៅក្នុងចំណោមជនភៀសខ្លួនទូទៅនិងជនភៀសខ្លួនដែលជាអ្នកដឹកនាំ ដែលការណ៍នេះបានប្រឆាំងនឹងលក្ខណៈធម្មតានៃប្រទេសរបស់ខ្លួននិងបង្កឲ្យមានការវិលត្រឡប់នៃការប្រទាញប្រទង់ប្រដាប់អាវុធនៅរ៉្វាន់ដាថែមទៀត» ។ ភាពចម្រូងចម្រាស់ប្រដាប់អាវុធនេះគឺជាការឈ្លានពានរបស់«រណសិរ្សស្នេហាជាតិរ៉្វាន់ដា» ដែលប្រព្រឹត្តទៅនៅក្នុងខែតុលា ឆ្នាំ១៩៩០ ដែលនេះបានបង្កជាសង្គ្រាមស៊ីវិលនៅរ៉្វាន់ដា ។ ម៉ូសេវេនី បានគាំទ្រក្រុម«រណសិរ្សស្នេហាជាតិរ៉្វាន់ដា»ដោយដាក់លក្ខខណ្ឌថានឹងមិនអនុញ្ញាតឲ្យក្រុមនេះវិលត្រឡប់មកអ៊ុយហ្កាន់ដាវិញទេ ហើយការធ្វើដូច្នេះគឺដើម្បីដោះស្រាយភាពស្មុគស្មាញនយោបាយសម្រាប់លោកផ្ទាល់ដែរ ។ នៅពេលដែលសង្គ្រាមចាប់ផ្តើមភ្លាម ប្រជាជនអ៊ុយហ្កាន់ដាចាប់ផ្តើមមានការថ្នាំងថ្នាក់ចំពោះ «រណសិរ្សស្នេហាជាតិរ៉្វាន់ដា» ដោយសាររណសិរ្សនេះប្រើប្រាស់ប្រទេសអ៊ុយហ្កាន់ដាជាទីតាំងធ្វើសង្គ្រាមសម្រាប់ដណ្តើមការគ្រប់គ្រងនៅរ៉្វាន់ដាវិញ ហើយអារម្មណ៍អវិជ្ជមានចំពោះប្រជាជនរ៉្វាន់ដាកាន់តែកើនច្រើនឡើងថែមមួយកម្រិតទៀតនៅក្នុងប្រទេសអ៊ុយហ្កាន់ដា ។ ជាលទ្ធផល «រណសិរ្សស្នេហាជាតិរ៉្វាន់ដា»ត្រូវបានបោះបង់ចោលនិងគ្មានជម្រើសអ្វីក្រៅតែពីបន្តព្យាយាមវាយលុកចូលរ៉្វាន់ដាដោយឆន្ទៈស្លួចស្តើងក្នុងការស្វែងរកអនាគតនៃនយោបាយរបស់ក្រុមខ្លួន ។

## ៥) ឱកាសនៃនយោបាយជ្រុលនិយមនៅរ៉្វាន់ដា

ទោះជាយ៉ាងណាក៏ដោយ សង្គ្រាមស៊ីវិលជាមួយនឹង«រណសិរ្សស្នេហាជាតិរ៉្វាន់ដា»អាចក្លាយទៅជាព្រឹត្តិការណ៍វិវត្ត

នាំទៅដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍បានតាមរយៈ ទំនាក់ទំនងដ៏សាំញ៉ាំជាមួយព្រឹត្តិការណ៍វិវត្តនៅក្នុងប្រទេសរ៉ូវ៉ាន់ដា ។ ដើម្បីយល់ពីព្រឹត្តិការណ៍វិវត្តផ្ទៃក្នុងទាំងនេះ ជាដំបូងយើងត្រូវតែត្រួតពិនិត្យមើលឱកាសនៃនយោបាយជ្រុលនិយមនៅរ៉ូវ៉ាន់ដា នៅអំឡុងពេលសង្គ្រាមស៊ីវិលជាមុនសិន ។ ខ្ញុំនឹងពន្យល់ឲ្យកាន់តែច្បាស់នៅពេលបន្ទាប់ថា ជនឆ្លៀតឱកាសហ៊ូទូដែលជាអ្នកបេះដឹង បានផ្លាស់ប្តូរវិបត្តិសង្គម សេដ្ឋកិច្ច និងនយោបាយ នៅរ៉ូវ៉ាន់ដាឲ្យទៅជាការរៀបចំទម្លាក់កំហុសលើក្រុមទុតស៊ីនិងប្រើប្រាស់សង្គ្រាមស៊ីវិលជាមួយនឹង«រណសិរ្សស្នេហាជាតិរ៉ូវ៉ាន់ដា»ជាវិធីសាស្ត្រក្នុងការពង្រឹងការឆ្លៀតឱកាសរបស់ខ្លួននៅរ៉ូវ៉ាន់ដា ។

**ក) កង្វះខាតធនធាននិងការភ័ន្តច្រឡំអំពីអត្តសញ្ញាណ សិទ្ធិនិងបញ្ហាច្បាប់**

នៅចន្លោះឆ្នាំ១៩៨០និងឆ្នាំ១៩៩១ ប្រជាពលរដ្ឋរ៉ូវ៉ាន់ដាបានកើនឡើងពី២លាននៅ៧,១៥លាននាក់ ។ មកដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ លែងមានដីដាំដុះសម្រាប់ឲ្យដណ្តើមគ្នាទៀតហើយ ហើយដង់ស៊ីតេប្រជាជនដែលរស់នៅលើដីដាំដុះនេះបានឈានដល់៤២២នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ។ ដូចជានៅក្នុងប្រទេសអ៊ុយហ្កាន់ដាដែរ ច្បាប់ទាក់ទងនឹងកម្មសិទ្ធិកាន់កាប់ដីធ្លីនៅរ៉ូវ៉ាន់ដាគឺអាចប្រែសម្រួលឲ្យមានន័យផ្សេងៗបាន ។ កង្វះខាតដីដាំដំណាំនិងការបកស្រាយច្បាប់មិនច្បាស់លាស់នេះហើយដែលបង្កឲ្យមានការភ័ន្តច្រឡំចំពោះប្រវត្តិសាស្ត្រអត្តសញ្ញាណនិងសិទ្ធិរបស់ប្រជាជននៅរ៉ូវ៉ាន់ដា ។ ប្រជាជនចាប់ផ្តើមដាក់សំណួរថា«តើអ្នកជិតខាងរបស់ខ្លួនមានប្រភពមកពីប្រទេសណា? តើអ្នកទាំងនោះជានរណា ហើយមានសិទ្ធិអ្វីខ្លះ? តើអ្នកទាំងនោះកំពុងដាំដំណាំលើដីដូនតារបស់ខ្ញុំមែនទេ?» ។ នេះបានបង្កជាការរីកដុះដាលនៃជម្លោះកម្មសិទ្ធិទឹកដី ហើយបញ្ជីឈ្មោះអ្នកដែលត្រូវដកហូតចេញពីការគ្រប់គ្រងដីធ្លីក៏កាន់តែកើនឡើងដែរ ។ អ្នកបេះដឹងហ៊ូទូក៏ឆ្លៀតឱកាសយកការភ័ន្តច្រឡំនេះមកធ្វើជាយុទ្ធវិធីក្នុងការផ្លាស់ប្តូរជម្លោះសង្គមនេះមកជាជម្លោះជាតិពន្ធុការតស៊ូប្រឆាំងចំពោះការរើសអើងពណ៌សម្បុរវិញ ។ ដូចគ្នានេះដែរ ជនឱកាសនិយមទាំងនេះក៏បានប្រើប្រាស់ជម្លោះនេះដើម្បីបង្កើនភក្តីភាពរបស់ជនក្រីក្រចំពោះក្រុមខ្លួនថែមទៀត ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ហ៊ូទូទាំងនោះបានទាញយកផលប្រយោជន៍ជាច្រើនពីការលក់ដីធ្លីខុសច្បាប់ដោយការទិញដីដែលមានដីជាតិជាច្រើនពីអ្នកក្រីក្រក្នុងតម្លៃទាប ។ បន្ទាប់មកក្រុមនេះក៏បានចាត់ទុកក្រុមទុតស៊ីជាជនបរទេសដែលបានដណ្តើមយកទឹកដីស្របច្បាប់របស់ហ៊ូទូ ។ អំពើដោយប្រយោលនេះបានបណ្តាលឲ្យប្រជាជនក្រីក្រទាំងនោះមិនសប្បាយចិត្តចំពោះក្រុមទុតស៊ីទាំងមូល ។ សង្គ្រាមស៊ីវិលជាមួយ «រណសិរ្សស្នេហាជាតិរ៉ូវ៉ាន់ដា» គឺធ្វើឲ្យការទម្លាក់កំហុសទៅលើក្រុមទុតស៊ីមានឥទ្ធិពលកាន់តែខ្លាំងឡើង ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលបំផុតនោះគឺក្រុមហ៊ូទូដែលពុំមានទឹកដីច្បាស់លាស់នោះ បានចាប់ផ្តើមបណ្តុះទ្រឹស្តី «អំណាចហ៊ូទូ»ដែលថា ជនជាតិទុតស៊ីដែលបានមករស់នៅក្នុងទឹកដីរ៉ូវ៉ាន់ដាចាប់តាំងពីសតវត្សរ៍ទី១៥ នោះគួរតែត្រូវបញ្ជូនឲ្យវិលត្រឡប់ទៅរស់នៅលើទឹកដីកំណើតរបស់ខ្លួនវិញនៅ«អេត្យូពី» ។

**(នៅមានត)**

**អាឌុង លី**

# ពាក្យស្លោកខ្មែរក្រហម

- ប្រយុទ្ធវណ្ណៈ មានវណ្ណៈខ្លះទទួលជ័យជម្នះ ហើយវណ្ណៈខ្លះទៀតត្រូវវិនាស នេះជាប្រវត្តិសាស្ត្រ។
- អាវុធជាកត្តាមួយសំខាន់ តែមិនមែនជាកត្តាឱ្យឈ្នះសង្គ្រាមទេ កត្តាសម្រេចធំបង្អស់គឺមនុស្ស មិនមែនជាសំភារៈម្យ៉ាងទេ។
- បដិវត្តជាសង្គ្រាមប្រជាជន មានតែការបំផុសបំផុលប្រជាជនទេ ទើបអាចធ្វើសង្គ្រាមបាន។

*(កំណត់ហេតុសិក្សារបស់សមមិត្ត ញ៉ុក សារុន)*

- សមរភូមិមុខ ជាតំណាងដ៏ឆ្នើមនៃមោទនភាពបដិវត្តន៍របស់ប្រជាជាតិនិងប្រជាជនកម្ពុជាទាំងមូល។
- ឈរជាប់ខាងនិងគ្រប់កាលៈទេសៈ លើថិហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់វាសនាខ្លួនដោយខ្លួនឯង។

*(សៀវភៅកំណត់ហេតុលេខ ០៧៦)*

# ការិយាល័យពត៌មានសាធារណៈ

*អគារលេខ៦៦ វិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ*

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង ៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជ័យ សុភារម្យ ឬ រ័ត្ន ដារា ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមនិស្សិតធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


ក្រុមដូនជីប្រជុំនៅបន្ទប់ពត៌មានសាធារណៈ

# ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា

(តចប់) ជំពូក៥

### ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា

### ១) សេចក្តីផ្តើម

នៅក្នុងជំពូកមុន ខ្ញុំបានវិភាគអំពីការស្រាវជ្រាវនិងធ្វើផែនការនៃការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា ។ ឥឡូវនេះ ខ្ញុំនឹងបន្ថែមយោបល់មួយចំនួនអំពីការផ្តល់ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា ។ ជំពូកនេះនឹងចែកចេញជាពីរផ្នែក ។ ផ្នែកទីមួយនឹងនិយាយអំពីវិធីសាស្ត្រដែលខ្ញុំលើកជាសំណើក្នុងការអប់រំអំពីសន្តិភាពដែលរួមមានៈ ការបង្រៀនអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ ការបង្រៀនអំពីមនោគមវិជ្ជាសាសនា ការអប់រំអំពីសន្តិភាពក្នុងចំណោមប្រជាជនកម្ពុជានៅស្រទាប់ក្រោម និងចុងបញ្ចប់គឺការផ្សព្វផ្សាយកម្មវិធីទាំងនោះតាមបណ្តាញសារព័ត៌មាន ។ ផ្នែកទីពីរនឹងបង្ហាញអំពីសារប្រយោជន៍នៃកម្មវិធីទាំងនេះ ។

### ២) ការសិក្សាអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ

នៅពេលអនាគតនឹងមានការប្រណាំងប្រជែងកាន់តែច្រើនឡើងៗ ដូច្នេះ ការសិក្សាអំពីសន្តិភាពនៅក្នុងសាលាគឺជាការចាប់ផ្តើមដ៏សំខាន់ ។

#### ក) គោលនយោបាយអប់រំកុមារ

នៅឆ្នាំ១៩៩៩ ក្រសួងអប់រំយុវជននិងកីឡានៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសថា គោលដៅនៃប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាគឺពង្រឹងសមត្ថភាពរបស់សិស្សទាំងផ្នែករាងកាយនិងស្មារតី ។ ដូច្នេះ កម្មវិធីមួយចំនួនត្រូវបានបង្កើតឡើងដើម្បីអនុវត្តនៅក្នុងសាលាដើម្បីឲ្យសិស្សអាចបង្កើនជំនឿទុកចិត្តចំពោះខ្លួនឯង ការទទួលខុសត្រូវ សមត្ថភាព ភាពរឹងប៉ឹង សាមគ្គីភាព និងគំនិតស្នេហាជាតិ ។ ដូច្នេះសិស្សនឹងគោរពច្បាប់និងសិទ្ធិមនុស្ស ។ សាលាមានតួនាទីមួយទៀតគឺបណ្តុះបណ្តាលសិស្សឲ្យទៅជាពលរដ្ឋល្អ ចេះរស់នៅដោយសន្តិភាពជាមួយអ្នកដទៃ និងចេះទទួលខុសត្រូវក្នុងក្រុមគ្រួសារនិងក្នុងសង្គម ។ ជាពិសេសប្រព័ន្ធអប់រំនៅវិទ្យាល័យមានគោលដៅពង្រឹងសមត្ថភាព ការគិតនិងការបញ្ចេញមតិយោបល់ អាកប្បកិរិយាអត់ឱន ការច្នៃប្រឌិត គុណធម៌សង្គម និងជំនាញដែលជាប្រយោជន៍ក្នុងការកសាងប្រទេសជាតិទៅរកភាពរុងរឿង ។

ឯកឧត្តម តុល ឡោះ អតីតរដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា បានឲ្យយោបល់នៅក្នុងអង្គប្រជុំរបស់ក្រសួងថា ការអប់រំនៅប្រទេសកម្ពុជាគួរតែផ្តោតទៅលើគោលការណ៍បួន ១) បង្កើនចំណេះដឹង ២) បង្កើនជំនាញ ៣) អប់រំសីលធម៌ និង ៤) អប់រំអំពីការរួមរស់ជាមួយគ្នាដោយសន្តិភាព ។

ចេញពីគោលការណ៍នេះ ក្រសួងបានផ្តល់ការអប់រំអំពីសិទ្ធិមនុស្សនិងភាពជាពលរដ្ឋដល់កុមារ ។ ក៏ប៉ុន្តែ ក្រសួងហាក់ដូចជាភ្លេចថា ការទាត់ចោលនូវប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍អាចផ្តល់គ្រោះថ្នាក់ដល់សន្តិភាពនៅប្រទេសកម្ពុជានៅពេលអនាគត ។ ក្នុងករណីនេះ ខ្ញុំសូមជូនយោបល់ឲ្យដាក់បញ្ចូលប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ទៅក្នុងកម្មវិធីសិក្សារបស់សិស្សនិងបង្រៀនតាមរបៀបជាការអប់រំអំពីសន្តិភាព ។

#### ខ) កម្មវិធី

ការសិក្សាប្រវត្តិសាស្ត្រមិនមែនសិក្សាតែអំពីវីរភាពនោះទេ ប៉ុន្តែគឺជាការពន្យល់អំពីដំណើរវិវត្តន៍នៃសង្គម ។ ការសិក្សាប្រវត្តិសាស្ត្រផ្តល់ឲ្យយើងនូវចំណេះដឹងអំពីអតីតកាលដែលនាំមកនូវដំណោះស្រាយសង្គមក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ។ ដូច្នេះ មុនពេលចាប់ផ្តើមសិក្សាប្រវត្តិរបៀបនេះ ការស្វែងរកបញ្ហាចម្បងនៅក្នុងសង្គមបច្ចុប្បន្នគឺជាចំណុចសំខាន់ ។

មុខវិជ្ជាប្រវត្តិសាស្ត្រត្រូវបានដាក់ក្នុងកម្មវិធីសិក្សារួចហើយ ដូច្នេះ ជំនួសឲ្យការបង្រៀនអំពីប្រវត្តិសាស្ត្រផ្សេងៗទៀតគួរតែបង្រៀនពីអំពើប្រល័យពូជសាសន៍នៅក្នុងមុខវិជ្ជានេះ ។ នៅក្នុងថ្នាក់ គ្រូបង្រៀនមិនគួរបង្រៀនសិស្សតែអំពីហេតុការណ៍នៃអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែគួរតែបង្ហាញអំពីមូលហេតុនិងផលប៉ះពាល់របស់ហេតុការណ៍ទាំងនោះផង ។

គំនិតចៀសវាងការកើតឡើងម្តងទៀតនៃរបបនេះនឹងធ្វើឲ្យសិស្សកាន់តែយល់ដឹង ។

កូនចៅជំនាន់ក្រោយរបស់ជនរងគ្រោះនិងជនដៃដល់នឹងរៀនសាលាជាមួយគ្នា ដូនកាលក្នុងថ្នាក់ជាមួយគ្នា ហើយនេះគឺជាឱកាសល្អសម្រាប់គ្រូក្នុងការផ្តល់ឱកាសឲ្យកុមារទាំងអស់នោះចែករំលែករឿងរ៉ាវនិងផ្លាស់ប្តូរគ្នាទៅវិញទៅមកៈ តើម្នាក់ៗយល់ឃើញដូចម្តេចចំពោះរបបកម្ពុជាប្រជាធិបតេយ្យ? តើកូនរបស់ជនដៃដល់យល់ឃើញដូចម្តេច? តើកូនរបស់ជនរងគ្រោះយល់ឃើញដូចម្តេច? និង តើអ្វីទៅដែលអ្នកទាំងពីរចង់និយាយជាមួយគ្នា? ដូច្នេះ គ្រូនឹងដើរតួនាទីជាអ្នកសម្របសម្រួលដឹកនាំសិស្សក្នុងដំណើរការដែលអាចនាំទៅដល់ការផ្សះផ្សា ការអត់ឱននិងការលើកលែងទោស ។

គ្រូបង្រៀនគួរតែដាក់ការងារឲ្យសិស្សធ្វើជាក្រុមឲ្យស្រាវជ្រាវព័ត៌មានអំពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងតំបន់ដែលសិស្សរស់នៅ និងឲ្យសួរមនុស្សចាស់ៗអំពីអារម្មណ៍របស់គាត់ តើគាត់ស្តាយក្រោយ ខឹង ឬសុំការអភ័យទោស ។ បន្ទាប់មក ឲ្យសិស្សសរសេរជារបាយការណ៍ហើយយកមកអានឲ្យមិត្តរួមថ្នាក់ស្តាប់ ។

### ក) យុទ្ធសាស្ត្រ

គ្រូបង្រៀនគួរតែបានទទួលការបណ្តុះបណ្តាលអំពីការអប់រំសន្តិភាពជាមុនសិន ព្រោះអ្វីដែលគ្រូទាំងនោះបានដឹងនិងជួបប្រទះពីមុនមកភាគច្រើនគឺការសម្លាប់រង្គាល ការបង្អត់អាហារ និងការធ្វើទារុណកម្ម ។ ដូច្នេះដំបូងបង្អស់ គ្រូត្រូវតែដឹងឲ្យច្បាស់អំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកដើម្បីក្លាយជាអ្នកកសាងសន្តិភាពបាន គ្រូត្រូវតែរៀនសូត្រអំពីជំនាញក្នុងការប្រឈមមុខនឹងអំពើហិង្សាក្នុងការយល់អំពីជម្លោះនិងសន្តិភាព និងអំពីរបៀបបង្រៀនសិស្សជុំវិញប្រធានបទសន្តិភាព ។

ក្រសួងអប់រំយុវជននិងកីឡាគឺជាអ្នកដែលមានឥទ្ធិពលបំផុតក្នុងការពង្រីកការអប់រំខណៈដែលអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានការយល់ដឹងគ្រប់គ្រាន់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ ដូច្នេះ ដើម្បីដំណើរការគម្រោងនេះ ខ្ញុំសំណូមពរឲ្យមានសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំយុវជននិងកីឡា ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំយុវជននិងកីឡាមិនទាន់បានបង្កើតរួមគ្នានូវក្រុមអ្នកកសាងសន្តិភាពនៅឡើយទេ ដូច្នេះគំនិតរបស់ខ្ញុំគឺគួរតែបង្កើតឲ្យមានក្រុមអ្នកកសាងសន្តិភាពមួយដើម្បីផលិតឯកសារអប់រំអំពីសន្តិភាពនិងផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀន ។ ចុងបញ្ចប់ ក្រុមអ្នកកសាងសន្តិភាពនឹងធ្វើការដើម្បីដឹកនាំការអប់រំអំពីសន្តិភាពទាំងពេលបច្ចុប្បន្ននិងពេលអនាគត ។

## ៣) សាសនា និង ការអប់រំអំពីសន្តិភាព

### ក) សាសនានៅប្រទេសកម្ពុជា

ក្នុងចំណោមប្រជាជនកម្ពុជាសរុបប្រមាណ១៣,៤លាននាក់ មាន៩៣ភាគរយជាពុទ្ធសាសនិក ។ ទ្រឹស្តីព្រះពុទ្ធសាសនាបានកប់យ៉ាងជ្រៅក្នុងទំនៀមទម្លាប់និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ។

ពុទ្ធឱវាទផ្តោតសំខាន់ទៅលើមេត្តា ករុណា និងការលើកលែងទោស ។ សម្តេច ប៊ួ គ្រី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា បានមានព្រះបន្ទូលថា ព្រះពុទ្ធតែងតែអភ័យទោសឲ្យមនុស្សគ្រប់រូប សូម្បីតែអ្នកនោះតាមព្យាបាទព្រះអង្គក៏ដោយ ។

ធម៌លើកលែងទោសបាននាំមនុស្សត្រឡប់ទៅរកអំពើល្អ ។ សម្តេចព្រះសង្ឃរាជ ប៊ួ គ្រី បានមានព្រះបន្ទូលបន្តថា ប្រជាជនកម្ពុជាគួរតែអភ័យទោសឲ្យខ្មែរក្រហម និងបានប្រទានព្រះឱវាទឲ្យប្រជាជនកម្ពុជាធ្វើដំណើរទៅមុខតាមផ្លូវត្រូវ ដូច្នេះប្រជាជនកម្ពុជាទាំងអស់នឹងអាចរស់នៅជាមួយគ្នាដោយសុខសន្តិភាព ។ សារនេះបានជះឥទ្ធិពលទៅលើជីវិតរបស់អង្គុលីមារដែលបានកាត់ម្រាមចង្អុលដៃរបស់មនុស្សមកធ្វើខ្សែពាក់ផ្សេង ។ អង្គុលីមារបានទទួលដឹងថាអំពើដែលគាត់បានប្រព្រឹត្តពីពេលមុនគឺខុស ជាលទ្ធផល អង្គុលីមារបានបួសជាសង្ឃដើម្បីលាងជម្រះចិត្តគំនិតនិងដើម្បីផ្សព្វផ្សាយទ្រឹស្តីព្រះពុទ្ធសាសនាដល់ប្រជាជនដទៃទៀត ក្នុងគោលបំណងកុំឲ្យមានអ្នកដទៃធ្វើដូចគាត់ ។ ប្រជាជនកម្ពុជាប្រហែល៦ភាគរយគឺជាមូស្លីម ។ គម្ពីរគូរ៉ាអានរបស់សាសនាឥស្លាមបានចែងថាៈ...ប្រសិនបើអ្នកដាក់ទណ្ឌកម្មជនណាម្នាក់ សូមឲ្យទណ្ឌកម្មរបស់អ្នកស្មើនឹងអ្វីដែលជននោះ

*បានប្រព្រឹត្តមកលើអ្នក ប៉ុន្តែប្រសិនបើអ្នកអាចអត់ទិនបាន នោះជាការប្រសើរបំផុត...*

ពាក្យនេះបង្ហាញថា ព្រះអាឡាបានប្រាប់ប្រជាជនកុំឲ្យដាក់ទណ្ឌកម្មចំពោះអ្នកដែលធ្វើខុស ។ គ្មាននរណាម្នាក់អាចដាក់ទណ្ឌកម្មឲ្យស្មើនឹងអំពើដែលបានខុសរួចមកហើយនោះទេ ហើយជននោះនឹងមានបាបប្រសិនបើដាក់ទណ្ឌកម្មមិនស្មើនឹងកំហុស ។

ពន់ យ៉ាមីន អ្នកដឹកនាំសាសនាឥស្លាមម្នាក់បាននិយាយថា បើតាមកំហឹងរបស់គាត់ គាត់ចង់តែសម្លាប់មេដឹកនាំខ្មែរក្រហម ប៉ុន្តែគាត់មិនធ្វើដូច្នេះទេ ពីព្រោះព្រះអាឡាបានប្រៀនប្រដៅឲ្យចៀសវាងអំពើសងសឹក ។

### ៣) កម្មវិធី

សាសនាព្រះពុទ្ធគឺជាប្រភពដ៏មានតម្លៃក្នុងការបង្កើតសន្តិភាពនៅប្រទេសកម្ពុជា ។ ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានជាពិសេសវិទ្យុ អាចបញ្ជូនទ្រឹស្តីព្រះពុទ្ធសាសនាយ៉ាងមានប្រសិទ្ធភាពទៅដល់ប្រជាជនសាមញ្ញនៅទូទាំងប្រទេស ។ តាមរយៈកម្មវិធី «អប់រំអំពីសន្តិភាពតាមរយៈព្រះពុទ្ធសាសនា» ទស្សនៈព្រះពុទ្ធសាសនាគួរតែផ្សាយឲ្យបានទូលំទូលាយនិងធ្វើឲ្យលេចធ្លោ ដើម្បីឲ្យប្រជាជនបានទទួលចំណេះដឹងអំពីសង្គមរបស់ខ្លួន ។

ដើម្បីធ្វើការងារនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាគួរតែសហការជាមួយអង្គការព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាដើម្បីបង្កើតកម្មវិធីអប់រំដោយព្រះសង្ឃ ។ កម្មវិធីនេះគួរតែផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌល ។

វត្តអារាមក៏ជាកន្លែងសម្រាប់ផ្តល់ការអប់រំអំពីសន្តិភាពដែរ ។ វត្តគឺជាកន្លែងដ៏សំខាន់ដែលប្រជាជនទាក់ទងគ្នានិងរៀនសូត្រ ។ តាមរយៈធម៌ទេសនា ព្រះសង្ឃដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញផ្លូវដល់ប្រជាជនក្នុងការដោះស្រាយបញ្ហានិងការស្វែងរកសន្តិភាពក្នុងចិត្ត ។

រៀងរាល់ថ្ងៃសីល ប្រជាជន (មនុស្សវ័យចំណាស់និងវ័យកណ្តាល) ជួបជុំគ្នានៅវត្តដើម្បីរៀនធម៌ព្រះពុទ្ធពីព្រះសង្ឃ ។ នៅថ្ងៃសីលនេះហើយដែលព្រះសង្ឃផ្តល់ធម៌ទេសនាដោយលើកយកទ្រឹស្តីព្រះពុទ្ធសាសនាមកភ្ជាប់នឹងបញ្ហាក្នុងសង្គមបច្ចុប្បន្ននិងឲ្យដំបូន្មានប្រជាជនថាតើគួរប្រព្រឹត្តដូចម្តេចចំពោះអតីតខ្មែរក្រហម ។ លើសពីនេះ ព្រះសង្ឃអាចឲ្យដំបូន្មានខ្លះៗដើម្បីបញ្ចប់ការរើសអើងនៅក្នុងភូមិ ។

ទោះជាយ៉ាងនេះក៏ដោយ ការផ្សព្វផ្សាយទ្រឹស្តីព្រះពុទ្ធសាសនាប្រហែលជាអាចរំខានដល់ប្រជាជនមួយចំនួនដែលកាន់សាសនាឥស្លាម ។ ឆ្លើយតបនឹងបញ្ហានេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីមួយដែលធ្វើការជាមួយសហគមន៍ជនជាតិខ្មែរឥស្លាមដើម្បីប្រមូលចងក្រងប្រវត្តិសាស្ត្រតាមការនិយាយរៀបរាប់ ។ មានកម្មវិធីមួយទៀតដែលមានឈ្មោះថា «ការអប់រំសន្តិភាពតាមរយៈសាសនាឥស្លាម» ហើយកម្មវិធីនេះគួរតែសហប្រតិបត្តិការជាមួយកម្មវិធី «អប់រំសន្តិភាពតាមរយៈព្រះពុទ្ធសាសនា» ។

ក្រុមអ្នកសាងសន្តិភាពអាចបើកវគ្គបណ្តុះបណ្តាលអំពីសន្តិភាពនិងអំពីទំនាក់ទំនងរវាងទ្រឹស្តីសាសនាព្រះពុទ្ធនិងទ្រឹស្តីសាសនាឥស្លាម ។ ជាងនេះទៅទៀតក៏គួរតែផ្តល់ការបណ្តុះបណ្តាលអំពីវិធីប្រតិបត្តិតាមទស្សនវិជ្ជាសាសនាព្រះពុទ្ធនិងសាសនាឥស្លាមនិងតួនាទីរបស់ព្រះសង្ឃក្នុងព្រះពុទ្ធសាសនានិងតួន-ហាគិមនៅក្នុងសាសនាឥស្លាម ។

### ៤) ការអប់រំសន្តិភាពដល់ប្រជាជននៅស្រុកស្រែចម្ការ

សង្គមគ្រួសារគឺជាកន្លែងដ៏សំខាន់ក្នុងការអប់រំកុមារ ។ ហេតុនេះកម្មវិធី«អប់រំអំពីសន្តិភាព» គួរតែលាតសន្ធឹងដល់ស្រទាប់គ្រួសារ ហើយគ្រួសារគួរតែចូលរួមចំណែកឲ្យបានច្រើននិងសកម្ម ។ គ្រួសារនិងសាលាគឺជាកន្លែងពីរដែលងាយនឹងជះឥទ្ធិពលលើកុមារ ងាយនឹងបង្រៀនកុមារឲ្យស្អប់ឬឲ្យស្រលាញ់ ។ ទោះជាដំបូងបង្អស់កុមារទទួលឥទ្ធិពលដ៏ខ្លាំងក្លាពីគ្រួសារក៏ដោយ ប៉ុន្តែបទពិសោធន៍នាពេលក្រោយៗមក ជាពិសេសនៅសាលារៀនអាចផ្លាស់ប្តូរឬពង្រឹងបុគ្គលិកលក្ខណៈរបស់កុមារបាន ។

### ក) ទិវាចងកំហឹង

នៅក្នុងភូមិ ទោះជាឥឡូវនេះជនរងគ្រោះនិងជនដៃដល់រស់នៅជិតគ្នាក្តី ក៏គ្រាប់ពូជនៃការផ្សះផ្សាមិនទាន់ត្រូវបានដាំនៅឡើយទេ ។ «ទិវាចងកំហឹង» តែងតែត្រូវបានប្រារព្ធធ្វើនៅថ្ងៃទី២០ ខែឧសភា នៅទូទាំងប្រទេសតាំងពីរបបកុម្មុយនិស្តចូល

គ្រប់គ្រងអំណាចមក ។ «ទិវាចងកំហឹង»ពិតជាងាយនឹងបន្តឲ្យមានផលប៉ះពាល់ខ្លាំងចំពោះប្រជាជនកម្ពុជាទាំងពីរខាង គឺទាំងជនរងគ្រោះ ទាំងជនដៃដល់ ។ ទោះជាពេលបច្ចុប្បន្ននេះក្តី ប្រជាជនទៅកាន់កន្លែងដែលមានការសម្លាប់រង្គាលដើម្បីដាក់បាច់ផ្កា សែនម្ហូបចំណី និងអុជធូប ដើម្បីរំឭកដល់អ្នកដែលបានស្លាប់ទៅ ។ នេះនៅតែជានិមិត្តរូបនៃ «ទិវាចងកំហឹង» ។

ប្រជាជនកម្ពុជាមិនទាន់បានចាត់ទុកការចងចាំប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យជាបរិបទនៃប្រវត្តិសាស្ត្រទេ ។ គាត់រំឭករឿងរ៉ាវអតីតកាលជាមួយនឹងការរំជួលចិត្ត ។ ដើម្បីរំដោះប្រជាជនចេញពីការចងចាំរបៀបនេះ និងដើម្បីផ្លាស់ប្តូរទស្សនៈរបស់គាត់ឆ្ពោះទៅរកការកសាងសន្តិភាពនៅពេលអនាគត ដំបូងបង្អស់ប្រជាជនត្រូវតែមើលឲ្យឃើញថា ការចងចាំរបស់គាត់គឺជាប្រវត្តិសាស្ត្រដែលបានកើតឡើងយ៉ាងពិតប្រាកដកាលពីអតីតកាល ហើយគាត់ត្រូវតែប្រើប្រាស់ការចងចាំនោះដើម្បីបង្កើតសន្តិភាពនៅប្រទេសកម្ពុជា ។ «ទិវាចងកំហឹង» គួរតែប្រែក្លាយទៅជា «ទិវាលើកលែងទោស» ឬ «ទិវារៀបរាប់ការពិត» ។

### ១) កម្មវិធី

តាមរយៈការបង្រៀនជាជំហានទី១តាមប្រព័ន្ធសារព័ត៌មាននូវទ្រឹស្តីនៃសាសនាអំពី «សន្តិភាពនិងការលើកលែងទោស» ប្រជាជនកម្ពុជានឹងភ្ញាក់ពីការចងចាំរបស់ខ្លួនបន្ទាប់មកទស្សនៈលើកលែងទោសនិងសន្តោសអាចចូលមកស្ថិតនៅក្នុងចិត្តរបស់ប្រជាជន ។ ការអប់រំអំពីទ្រឹស្តីព្រះពុទ្ធសាសនាព្រមជាមួយនឹងជំនឿទៅលើសាសនានេះ មិនត្រឹមតែលើកទឹកចិត្តជនដៃដល់ឲ្យនិយាយអំពីអារម្មណ៍របស់ខ្លួននិងហ៊ានប្រឈមមុខទទួលខុសត្រូវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យជនរងគ្រោះមានឱកាសសិក្សាអំពីការលើកលែងទោសនិងការសន្តោសដែរ ។

គោលដៅសំខាន់នៃកម្មវិធីនេះគឺបង្កើតអង្គប្រជុំដើម្បីឲ្យប្រជាជនចែករំលែកអារម្មណ៍របស់ខ្លួនចំពោះគ្នាទៅវិញទៅមក ។ ដូច្នេះ អ្នកកសាងសន្តិភាពគួរតែមានការិយាល័យអចិន្ត្រៃយ៍នៅគ្រប់ខេត្ត ដើម្បីផ្តល់យោបល់ដល់ប្រជាជនណាដែលជួបប្រទះនឹងការរើសអើងនៅក្នុងភូមិរបស់ខ្លួន ។

នៅក្នុងដំណើរការនេះ វគ្គបណ្តុះបណ្តាលអំពី«ការដោះស្រាយជម្លោះនិងធម៌អហិង្សា» គួរតែត្រូវបានបង្កើតឡើងដើម្បីពង្រឹងសមត្ថភាពជំនាញរបស់ប្រជាជន ។ កាលវិភាគប្រជុំឬសកម្មភាពផ្សេងៗទៀតគួរតែត្រូវបានរៀបចំដើម្បីផ្តល់ឱកាសដល់ប្រជាជនទាំងក្នុងនិងក្រៅសហគមន៍ជួបពិភាក្សាគ្នានិងចែករំលែកបទពិសោធន៍ជាមួយគ្នា ។

ការជួបសន្ទនារវាងជនរងគ្រោះនិងជនដៃដល់នឹងរួមចំណែកព្យាបាលស្នាមរបួស ។ នៅក្នុងការសន្ទនានោះ សកម្មភាពពីអតីតកាលត្រូវបាននិយាយចេញ ហើយការយល់ចិត្តគ្នាទៅវិញទៅមកក៏កើតមានឡើង ។ ការប្រជុំគ្នាបែបនេះធ្វើឲ្យប្រជាជនរកឃើញដំណោះស្រាយចំពោះបញ្ហារបស់គាត់ និងរកឃើញវិធីក្នុងការរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព ។

«ទិវាលើកលែងទោស» គួរតែប្រារព្ធធ្វើឡើងនៅថ្ងៃទី២០ ខែឧសភា រៀងរាល់ឆ្នាំ ដែលរៀបចំដោយ«ក្រុមអ្នកកសាងសន្តិភាព» និងអាជ្ញាធរមូលដ្ឋាន ។ នៅក្នុងថ្ងៃនេះ ជនរងគ្រោះនិងជនដៃដល់នឹងទៅទីតាំងសម្លាប់នានាដើម្បីគោរពវិញ្ញាណក្ខន្ធនិងបួងសួងដល់អ្នកស្លាប់ ។ ទាំងជនរងគ្រោះនិងជនដៃដល់គួរតែទទួលបានឱកាសនិងពេលវេលាស្មើគ្នាសម្រាប់បញ្ចេញយោបល់និងអារម្មណ៍របស់ខ្លួន ។ ដំណើរការសុំអភ័យទោសរបស់ជនដៃដល់និងការលើកលែងទោសរបស់ជនរងគ្រោះគួរតែផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មាន ជាពិសេសវិទ្យុ ។

យើងអាចប្រមើលបានថា ការលើកទឹកចិត្តជនរងគ្រោះឲ្យនិយាយអំពីអារម្មណ៍របស់ខ្លួនគឺជាការងាយស្រួល ប៉ុន្តែសម្រាប់ជនដៃដល់ ការនិយាយជាសាធារណៈពីអំពើរបស់ខ្លួនកាលពីអតីតកាលគឺជារឿងពិបាក ។ ទោះជាជនរងគ្រោះបានបង្ហាញការអភ័យទោសនិងក្តីអាណិតចំពោះជនដៃដល់ដែលបានសារភាពរួចហើយក៏ដោយ ក៏ទាំងពីរនាក់នៅតែត្រូវការពេលវេលាបន្ថែមទៀតដើម្បីរំលាយកំហឹងនិងការស្អប់ខ្ពើមហើយបំពេញវិញដោយការអាណិតនិងអភ័យទោស ។

### ៥) សារសំខាន់នៃកម្មវិធីនេះ

កម្មវិធីដែលបាននិយាយខាងលើនឹងជួយអភិវឌ្ឍជំនាញរបស់ប្រជាជនកម្ពុជានិងលើកកម្ពស់ការយល់ដឹងនិងតម្លៃ ។

*ការយល់ដឹងៈ* ចំណេះដឹងចាំបាច់បំផុតដែលកម្មវិធីនេះនឹង

បង្រៀន គឺប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យនិងរបៀបដែលរបបនេះត្រូវបានបំប្លែង ។ ការណ៍នេះនឹងធ្វើឲ្យប្រជាជនកម្ពុជាដឹងអំពីវិធីបញ្ចៀសការកើតឡើងវិញនៃហេតុការណ៍បែបនោះ ។

*ជំនាញៈ* ជំនាញក្នុងការវិភាគប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួននឹងបង្កើតការពិភាក្សាមួយ ហើយនៅក្នុងការពិភាក្សានោះសិស្សអាចបង្កើនជំនាញក្នុងការការគិតឲ្យបានត្រឹមត្រូវ ។ ជំនាញក្នុងការដោះស្រាយបញ្ហានិងទ្រឹស្តីអហិង្សាក៏នឹងត្រូវបានផ្តល់ជូនសិស្សនៅសាលានិងមនុស្សនៅក្នុងសហគមន៍ ។

*តម្លៃៈ* តាមរយៈការបង្កើតការពិភាក្សារវាងជនរងគ្រោះនិងជនដៃដល់ប្រជាជននឹងបង្កើនការអាណិតអាសូរ ការជឿទុកចិត្ត ការរាប់អានគ្នា និងការជឿជាក់លើខ្លួនឯង ។

## ៦) សន្និដ្ឋាន

កម្មវិធី«អប់រំអំពីសន្តិភាព»ត្រូវបានផ្តោតជាសំខាន់ទៅលើការផ្សះផ្សារវាងជនដៃដល់និងជនរងគ្រោះ លើកកម្ពស់វប្បធម៌អហិង្សាក្នុងចំណោមសិស្សនិងមនុស្សចាស់ ថែរក្សាប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងចៀសវាងការកើតមានឡើងវិញនៃរបបនោះនៅពេលអនាគត ។

ការអធិប្បាយដូចនៅក្នុងកម្មវិធីខាងលើបានកើតមានរួចហើយនៅក្នុងវប្បធម៌កម្ពុជា ។ យើងនឹងប្រើប្រាស់ប្រភពធនធានដែលកម្ពុជាមានស្រាប់ដើម្បីធ្វើឲ្យការងារនេះបានសម្រេច ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងជាកន្លែងដែលមានសក្តានុពលក្នុងការធ្វើការងារវិស័យ«អប់រំអំពីសន្តិភាព» ពីព្រោះមជ្ឈមណ្ឌលនេះបានបំពេញកិច្ចការសំខាន់ៗជាច្រើនរួមទាំងការផលិតកម្មវិធីវិទ្យុនិងឯកសារប្រវត្តិសាស្ត្រនិងការភ្ជាប់បណ្តាញការងារជាមួយប្រជាជនក្នុងប្រទេសនិងក្រុមសាសនា (ទាំងសាសនាព្រះពុទ្ធនិងសាសនាឥស្លាម) ។ នាពេលបច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែធ្វើការងារយ៉ាងសកម្មលើគម្រោង«ផ្សះផ្សាជាតិ» ដូច្នេះ «ការអប់រំអំពីសន្តិភាព» គួរតែជាផ្នែកមួយដ៏សំខាន់នៃគម្រោងនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើឲ្យសម្រេចគម្រោង«ការអប់រំអំពីសន្តិភាព» ។

## សរុបសេចក្តី

ការអប់រំគឺជាដំណើរការជួយប្រជាជនឲ្យអភិវឌ្ឍន៍បុគ្គលិកលក្ខណៈផ្ទាល់ខ្លួន អាកប្បកិរិយានិងសមត្ថភាព ។ ការអប់រំនឹងផ្តល់ដល់ប្រជាជននូវការគិតថ្មីនិងអាកប្បកិរិយាថ្មី ។ ទាំងការអប់រំក្នុងប្រព័ន្ធនិងការអប់រំក្រៅប្រព័ន្ធដើរតួនាទីយ៉ាងសំខាន់ក្នុងការស្ថាបនាការយល់ដឹងរបស់ប្រជាជន ។ ការអប់រំអាចឲ្យផលទាំងល្អទាំងអាក្រក់ ដូច្នេះការអប់រំអាចទាញពិភពលោកទៅរកសង្គ្រាមឬទៅរកសន្តិភាព ។

ក្នុងនាមជាអ្នកកសាងសន្តិភាពម្នាក់ បេតធី រៀដាន់ បានសរសេរថាៈ

*ការអប់រំគឺជាដំណើរការមួយដែលតាមរយៈនេះយើងអាចសិក្សាអំពីរបៀបផ្សេងៗនៃការគិតនិងការសម្តែងអាកប្ប-កិរិយានិងអាចប្រមើលអំពីអនាគតរបស់យើង ។*

ឧទាហរណ៍នៃប្រទេសរ៉្វាន់ដានិងអៀរឡង់ខាងជើងបង្ហាញយ៉ាងច្បាស់នូវឥទ្ធិពលនៃការអប់រំ ។ ការអប់រំផ្អែកលើការប្រកាន់ពូជសាសន៍បានបង្កឲ្យជនជាតិហ៊ូទូសម្លាប់ជនជាតិទុតស៊ីនៅក្នុងប្រទេសរ៉្វាន់ដា និងបង្កឲ្យមានជម្លោះហិង្សារវាងក្រុមនិយមប្រូតេស្តង់និងក្រុមនិយមកាតូលិកនៅប្រទេសអៀរឡង់ខាងជើង ។ ប៉ុន្តែការអប់រំអំពីសន្តិភាពក៏មានឥទ្ធិពលសំខាន់ក្នុងការនាំយកជនជាតិហ៊ូទូនិងជនជាតិទុតស៊ីមករស់នៅជាមួយគ្នាជាជាតិរ៉្វាន់ដាតែមួយនិងនាំក្រុមនិយមប្រូតេស្តង់និងក្រុមនិយមកាតូលិកឲ្យឈានទៅរកការយល់គ្នាបានប្រសើរជាងមុន ។

ការអប់រំក្នុងប្រព័ន្ធនិងការអប់រំក្រៅប្រព័ន្ធមិនត្រឹមតែមានសក្តានុពលក្នុងការផ្សះផ្សាសង្គមក្រោយសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសក្តានុពលក្នុងការនាំយកសន្តិភាពឲ្យពិភពលោកទៀតផង ។ ដើម្បីឈានដល់គោលដៅនេះ ដំបូងបង្អស់ការអប់រំអំពីសន្តិភាពត្រូវតែធ្វើឲ្យប្រជាជនយល់ថា ការប្រើប្រាស់អំពើហិង្សាដើម្បីតបតនៅក្នុងជម្លោះគឺមិនមែនជាជម្រើសដ៏ប្រសើរនោះទេ ។ បន្ទាប់មកទៀត ការអប់រំអំពីសន្តិភាពត្រូវតែបង្វែរទៅឲ្យប្រជាជននូវអាកប្បកិរិយាសន្តិភាពដើម្បីឲ្យប្រាកដថាសន្តិភាពសម្រាប់ពិភពលោកត្រូវបានទ្រទ្រង់ ។

ចំណុចសំខាន់នៃការអប់រំអំពីសន្តិភាពនៅក្នុងដំណាក់កាល

ក្រោយសង្គ្រាមនិងនៅក្នុងសង្គមដែលមានការបែងចែកជាតិសាសន៍គឺការព្យាយាមនាំយកប្រជាជនឲ្យរួមរស់ជាមួយគ្នា កសាងជំនឿទុកចិត្តនិងការយល់គ្នាទៅវិញទៅមក និងបង្កើនឥរិយាបថអត់ឱនលើកលែងទោស អភ័យទោស និងយល់ពីតម្លៃនៃការរស់នៅជាមួយគ្នា ។

ការរៀនសូត្រអំពីបទពិសោធន៍ដ៏អាក្រក់នៃប្រវត្តិសាស្ត្រក៏អាចជួយប្រជាជនឲ្យសម្លឹងទៅមុខឆ្ពោះទៅរកអនាគតដ៏ប្រសើរ ។ ការរៀនសូត្រពីអំពើប្រល័យពូជសាសន៍នៅប្រទេសរ្វាន់ដា កាលពីឆ្នាំ១៩៩៤អាចជួយឲ្យចៀសវាងការកើតឡើងវិញម្តងទៀតនៃហេតុការណ៍នេះ អភិវឌ្ឍអាកប្បកិរិយាអត់ឱន និងបង្កើនតម្លៃនៃការរស់នៅដោយសន្តិភាពជាមួយជាតិសាសន៍របស់ខ្លួន ។ ផ្ទុយទៅវិញ លទ្ធផលដ៏គួរឲ្យរន្ធត់នៃការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរបានជំរុញឲ្យប្រជាជនជប៉ុនធ្វើកិច្ចការដែលពាក់ព័ន្ធនឹងការប្រឆាំងនឹងនុយក្លេអ៊ែរ ។

នៅប្រទេសកម្ពុជា ការរើសអើងនិងអាកប្បកិរិយាហិង្សាត្រូវបានបង្រៀនពីមួយជំនាន់ទៅមួយជំនាន់ ។ ការអប់រំអំពីសន្តិភាពមិនទាន់បានផ្សព្វផ្សាយនៅក្នុងគំនិតរបស់ប្រជាជនកម្ពុជានៅឡើយទេ ។ ប្រវត្តិសាស្ត្រអំពីរបបប្រល័យពូជសាសន៍ត្រូវបានសរសេរស្ទើរយ៉ាងខ្លីនៅក្នុងសៀវភៅសិក្សា ។

ឆ្លុះបញ្ចាំងទៅនឹងស្ថានភាពនេះ ការអប់រំអំពីសន្តិភាពគឺត្រូវការជាចាំបាច់ដើម្បីផ្លាស់ប្តូរការគិតរបស់ប្រជាជនកម្ពុជាចំពោះអតីតកម្មាភិបាលខ្មែរក្រហមនិងដើម្បីលុបបំបាត់អាកប្បកិរិយាហិង្សា ។ ការយល់ឃើញរបស់ខ្ញុំគឺថា គួរតែប្រើប្រាស់មេរៀនពីអតីតកាលដើម្បីបង្រៀនប្រជាជនកម្ពុជាឲ្យយល់អំពីហេតុនិងផលនិងដើម្បីចៀសវាងការកើតឡើងម្តងទៀតនៃរបបនោះនៅពេលអនាគត ។ ប្រជាជនកម្ពុជាអាចប្រើប្រាស់ការយល់ដឹងខាងផ្លូវអារម្មណ៍និងតម្លៃរបស់ខ្លួនដើម្បីយកឈ្នះការភ័យខ្លាចនិងកំហឹង ។

មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាកន្លែងផ្ទុកឯកសារប្រវត្តិសាស្ត្រដ៏ធំដែលបានដំណើរការកិច្ចការជាច្រើនដូចជាការស្រាវ-ជ្រាវ ការធ្វើវណ្តាដែនទី ការចុះបញ្ជីឯកសារ ការបោះពុម្ពផ្សាយទស្សនាវដ្តី និងការបង្កើតកម្មវិធីវិទ្យុ ។ កិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយក្រសួងអប់រំយុវជននិងកីឡាដែលបានលើកឡើងជាលម្អិតនៅក្នុងជំពូកទី៦គួរតែធ្វើឲ្យប្រាកដថាសិស្សានុសិស្សបានទទួលចំណេះដឹងអំពីរបបប្រល័យពូជសាសន៍ និងចំណេះដឹងនិងជំនាញដើម្បីបង្កើនសមត្ថភាពនិងអាកប្បកិរិយាដើម្បីក្លាយជាមនុស្សពេញវ័យដែលស្រលាញ់សន្តិភាពនៅពេលអនាគត ។

កម្មវិធីបង្រៀនអំពីសន្តិភាពនិងការលើកលែងទោសតាមរយៈទ្រឹស្តីសាសនាគួរតែផ្សព្វផ្សាយតាមបណ្តាញពត៌មាន ព្រោះកម្មវិធីនេះអាចជួយប្រជាជនកម្ពុជាឲ្យជម្រុះអារម្មណ៍ភ័យខ្លាចនិងកំហឹង និងពង្រឹងអារម្មណ៍ឡើងវិញ ។ ជាងនេះទៅទៀត ការប្រែក្លាយ «ទិវាចងកំហឹង» ទៅជា «ទិវាលើកលែងទោស» នឹងដាស់តឿនប្រជាជនកម្ពុជាឲ្យរក្សាប្រវត្តិសាស្ត្រពីអតីតកាល ប៉ុន្តែបោះជំហានឆ្ពោះទៅរកការផ្សះផ្សានិងការរស់នៅជាមួយគ្នាដោយសន្តិភាព ។

សរុបសេចក្តីមក ខ្ញុំសូមបញ្ជាក់ម្តងទៀតថា គោលការណ៍នៃការអប់រំអំពីសន្តិភាពគឺដើម្បីផ្លាស់ប្តូរពិភពលោកឲ្យទៅជាពិភពមួយដែលគ្មានអំពើហិង្សា ។ នៅប្រទេសកម្ពុជា ខ្ញុំមានការជឿជាក់យ៉ាងមុតមាំថា ការអប់រំអំពីសន្តិភាពនឹងជួយប្រជាជនកម្ពុជាឲ្យផ្លាស់ប្តូរ «កេរដំណែលនៃអ្នកចម្បាំង» ទៅជា «កេរដំណែលនៃអ្នកកសាងសន្តិភាព» វិញ ។

ទោះជាយ៉ាងណាក៏ដោយ ការសិក្សាអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យការយល់ដឹងខាងអារម្មណ៍និងការផ្លាស់ប្តូរពី«ទិវាចងកំហឹង»ទៅជា«ទិវាលើកលែងទោស» គឺមិនគ្រប់គ្រាន់នឹងបង្កើត «កេរដំណែលនៃអ្នកកសាងសន្តិភាព» នៅក្នុងចំណោមប្រជាជនកម្ពុជាទេ ។ កម្មវិធីទាំងអស់គ្រាន់តែជាជំហានទីមួយក្នុងការនាំប្រជាជនទៅរកការផ្សះផ្សានិងការលើកលែងទោសនិងក្នុងការចៀសវាងការកើតឡើងវិញនៃអំពើប្រល័យពូជសាសន៍នៅពេលអនាគត ។ ដើម្បីកសាងកម្ពុជាមួយដែលមានសន្តិភាព មានកិច្ចការជាច្រើនទៀតដែលត្រូវតែធ្វើ បូករួមទាំងការអប់រំអំពីសន្តិភាពរយៈពេលវែងផង ។

**គីម កែវកន្និដ្ឋា**

*អត្ថបទមកពីមិត្តអ្នកអាន*

# សមរភូមិក្រោយនៃជីវិតដោះ

ខេត្តព្រះវិហារជាខេត្តមួយស្ថិតនៅភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យខេត្តនេះត្រូវបានចាត់ចូលក្នុងតំបន់១០៣ដែលមានស្រុកចំនួន១៤ ក្នុងនោះបូករួមទាំងស្រុកពីរបស់ខេត្តស្ទឹងត្រែង គឺស្រុកថាឡាបរិវ៉ាត់ និងស្រុកសៀមបូក ។ តំបន់១០៣មានចម្រៀងមួយបទជានិមិត្តរូបរបស់ខេត្តព្រះវិហារៈ

*តំបន់ព្រះវិហារ តំបន់ខ្លាំងក្លា ជាប់ភ្នំដងរែក មានស្រុកដប់បួន ល្អល្អះប្លែកៗ បម្រើទ្រគប់ផ្នែក បង្អែកបដិវត្ត ។ ពីល្វាក្រសាំង ព្រាលខ្នារវៀង កក់ពោនកំពត សាមគ្គីជោគជ័យ ត្នោតមូឡាតដ្ឋជ័យសែនឆ្នារប្រាច់ ម៉ឺនរាជភូមិថ្មី ។ ពើកទួលពុទ្រា សង្គមថ្មីជាប្រធាតុទួលស្រី ស្រណោះភ្នំត្បែង គូលេនត្រពាំងបី ខទម្ពរថ្មីជាំក្សាន្តប្រជុំមិត្ត ។ វីរភាពតស៊ូ ជាប់កំពង់ពោធិ៍ កំពង់ស្រឡៅពិត ជិតព្រះរង្កិល ដូរទន់ប្រាកដ ថាឡាបរិវ៉ាត់ សៀមបូកកោះព្រះ ។ បងប្អូនប្រយុទ្ធ អង់អាចមោះមុត ជម្នះឧបសគ្គ តាំងពីសង្គ្រាម ជាបង្អែកជាក់ ខ្លាំងក្លាអនត្ស សមរភូមិមុខ ។*

នៅឆ្នាំ១៩៧៣ ខ្ញុំធ្វើដំណើរឆ្លងកាត់ព្រៃព្រឹក្សាលតាវល្លិ៍ពីភូមិមួយទៅភូមិមួយដែលមានសភាពស្ងាត់ជ្រងំ ។ ការធ្វើដំណើរដោយទោចក្រយានពោរពេញដោយការលំបាកក្រៃលែងកាត់ព្រៃភ្នំក្រមថ្ម ផ្លូវរទេះ ខ្សាច់ ថ្មភក់ ។ នៅដើមខែតុលា ខ្ញុំបានមកដល់គោលដៅគឺស្រុករវៀងនៅម៉ោង១០ព្រឹក ដោយចំណាយពេលអស់មួយថ្ងៃកន្លះ ។ តំបន់១០៣ឬព្រះវិហារ រដ្ឋអំណាចរបស់ខ្មែរក្រហមកែប្រែរៀបចំជាសហករណ៍និងសហគមន៍រួចស្រេចបាច់អស់មុនពេលខ្ញុំទៅដល់ម្ល៉េះ ។ សហករណ៍គឺជាក្រុមសាមគ្គីបង្កើនផល ធ្វើការរួមគ្នា ចែកផលគ្នា និងហូបតាមផ្ទះរៀងខ្លួន ។ ចំណែកសហគមន៍គឺជាក្រុមសាមគ្គីដូចសហករណ៍ដែរតែផលរបបមិនត្រូវបានចែកតាមផ្ទះទេ គឺធ្វើរួមហូបរួមក្នុងផ្ទះបាយតែមួយ និយាយឲ្យខ្លីងាយយល់គឺសមាជិកសហគមន៍គ្មានអ្វីជាកម្មសិទ្ធិក្រៅពីខោអាវនិងចានមួយស្លាបព្រាមួយម្នាក់ប៉ុណ្ណោះទាំងមនុស្សចាស់ទាំងកុមារ ។ ខ្ញុំរស់នៅជាមួយបងស្រីនិងក្មួយតូចៗ ក្រោមការឃ្លាំមើលយ៉ាងប្រុងប្រយ័ត្នពីកងសេនាជនឃុំផ្សាររវៀង ។ មានដំណឹងសាយភាយពាសពេញឃុំផ្សាររវៀងថារូបខ្ញុំជាគិញរបស់ លន់ ណុល, សិរិមតៈ, ស៊ឹង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង សុស្តែន ។

ដំណឹងនេះបានលេចឮដល់គណៈតំបន់១០៣ ឈ្មោះ តាហង់ ។ ខ្ញុំព្រួយបារម្ភអំពីអាយុជីវិតរបស់ខ្លួនដែលអាចនឹងត្រូវខ្មែរក្រហមសម្លាប់ដោយសារតែដំណឹងនេះ ។ នៅយប់មួយប្រហែលម៉ោង១រំលងអធ្រាត្រ ខ្ញុំកំពុងតែដេកលក់ស្កប់ស្កល់ស្រាប់តែបងស្រីខ្ញុំដាស់ខ្ញុំពីដំណេក ហើយខ្សឹបសួរដាក់ត្រចៀកខ្ញុំទាំងតក់ក្រហល់ថា «តើហ្អែងមកនេះជាគិញរបស់ លន់ នល់មែនទេ?» ពេលនោះទឹកភ្នែកខ្ញុំហូរធ្លាក់មករកពាក្យអ្វីនិយាយមិនចេញ ។ បងស្រីខ្ញុំយកដៃស្ទាបមុខនិងថ្ពាល់ខ្ញុំទាំងងងឹតសូន្យសុង ប្រហែលជាគាត់ដឹងថាខ្ញុំគ្មានពាក្យអ្វីនឹងនិយាយប្រាប់គាត់ទេ ។ យប់នោះបន្ទាប់ពីបងស្រីចូលសម្រាន្ត ខ្ញុំដេកមិនលក់ទេ ។

ការសង្ស័យបានសាបរលាបបន្តិចម្តងៗពីក្នុងចិត្តបងប្អូនក្រុមគ្រួសារនិងប្រជាជនឃុំផ្សាររវៀង ប៉ុន្តែខ្ញុំនៅតែត្រូវខ្មែរក្រហមតាមដានដដែល ។ ពេលយប់ស្ងាត់មានសេនាជនឬឈ្លបរបស់ខ្មែរក្រហមចូលមកលបស្តាប់ ឬក៏យកចង្អង្រឹងមកចងដេកក្រោមផ្ទះបងស្រីខ្ញុំរាល់យប់ ។ មានថ្ងៃមួយនោះ ម៉ោងប្រហែល៨ព្រឹក ខ្ញុំកំពុងតែស្រោចដំណាំបានឮដំណឹងថាមេៗខ្មែរក្រហមទៅធ្វើសន្និបាតនៅវត្តស្រះចក ក្នុងភូមិកំពត ឃុំស្រែធំ ស្រុករវៀង ។ ខ្ញុំធ្វើដំណើរទៅកន្លែងធ្វើសន្និបាតក្រែងបានជួបអតីតមិត្តភក្តិដែលបានរួមការងារក្នុងចលនាប្រឆាំង លន់ ណុល នៅទីក្រុងកំពង់ចាម ប៉ុន្តែបំណងរបស់ខ្ញុំពុំបានសម្រេចឡើយ ដោយអង្គសន្និបាតធ្វើនៅអតីតព្រះវិហារវត្តស្រះចកដែលស្ថិតនៅចម្ងាយប្រហែលពី៦០ទៅ៨០គីឡូម៉ែត្រឯណោះ ។ ពេលដើរត្រឡប់ក្រោយវិញ ខ្ញុំគិតថាតើត្រូវរាយការណ៍អំពីការងារដែលខ្ញុំធ្លាប់បានធ្វើនៅខេត្តកំពង់ចាមឬត្រូវលាក់តទៅទៀត ។ ទីបំផុត ខ្ញុំសម្រេចចិត្តថាលាក់រឿងនេះតទៅទៀត ។

រស់នៅក្រោមការឃ្លាំមើលរបស់កងសេនាជន ខ្ញុំខិតខំបញ្ចេញស្នាដៃដាំដំណាំគ្រប់ប្រភេទដើម្បីក្លាយជាកសិករគំរូ ។ នៅឆ្នាំ១៩៧៤ អង្គការបានអនុញ្ញាតឲ្យខ្ញុំចូលជាសមាជិកសហករណ៍ក្រុមទី១ ឃុំផ្សាររវៀង ដែលចេញជា៧ក្រុម ។ ពីក្រុមទី១ ដល់ក្រុមទី៥ ជាក្រុមសាមគ្គីធ្វើរួមហូបតាមផ្ទះ ។ ក្រុមទី៦និងក្រុមទី៧ ជាសហគមន៍ធ្វើរួមហូបរួមជាក្រុមគំរូឈានមុខ ។ នៅថ្ងៃទី២៥ ខែមករា ក្រុមទី១ត្រូវបានកោះប្រជុំដាក់ផែនការទៅកាប់ព្រៃកូនឌុិ ។ ព្រៃនេះជាព្រៃស្រោងប្រកបដោយគ្រោះថ្នាក់បំផុត គឺជាតំបន់គ្រុនចាញ់ ។ សមាជិកឃុំផ្សាររវៀងទាំងប្រាំពីរក្រុមបានចេញដំណើរទៅព្រៃកូនឌុិដើម្បីកាប់ចម្ការ ។ នៅថ្ងៃទី១កុម្ភៈ ខ្ញុំបានធ្វើដំណើរតាមរទេះជាមួយអតីតគ្រូបង្រៀននៅស្រុករវៀង គឺលោក អ៊ុង ឈឹន ។ ដំណើររបស់យើងបានដល់ទីដៅនៅម៉ោង១១ថ្ងៃត្រង់ ។ ព្រឹកថ្ងៃបន្ទាប់ ទាំងប្រាំពីរក្រុមបានចេញទៅកាប់ឈើនិងឫស្សីឃ្លៃតាមក្រុមដែលបែងចែករួចមកហើយ ។ ខ្ញុំជាយុវជនពេញកម្លាំងទទួលភារកិច្ចកាប់រំលំដើមឈើធំៗ ចំណែកចាស់ៗជាអ្នកត្រាយកូនឈើតូចៗនិងវល្លិ៍ ។ សូរស័ព្ទបានលាន់ឮក្តុងក្តាំងពីសន្ទឹកនៃការរលំដើមឈើ ។ ទីព្រៃមួយបានក្លាយទៅជាទីវាលបន្តិចម្តងៗ ។ រយៈពេលប្រមាណ១៥ថ្ងៃ ព្រៃស្រោងបានក្លាយទៅជាតំបន់គំនរឈើដេកស្តូកស្តឹងរដូករណែល ។ ខ្ញុំសោកស្តាយណាស់ ព្រោះនៅស្រុកកំណើតរបស់ខ្ញុំពុំធ្លាប់ស្គាល់ឈើល្អៗបែបនេះ ។ ពីរសប្តាហ៍កន្លងផុតទៅ យើងកាប់ឆ្ការបានដីបីហិកតា ទើបត្រឡប់ទៅសម្រាករង់ចាំឲ្យឈើដែលកាប់រួចស្ងួតសិន ។ បន្ទាប់ពីសម្រាកបានមួយអាទិត្យ ក្រុមទី១និងក្រុមទីប្រាំពីរទទួលការចាត់តាំងទៅរកត្រីនៅស្ទឹងសែន ។ ស្ទឹងសែនជាស្ទឹងដែលសំបូរត្រីជាងគេ និងជាកន្លែងដែលខ្ញុំបានស្គាល់ជាលើកដំបូងក្រោយពីឃ្លាតពីទន្លេមេគង្គ ។ អន្លង់ប្រាជាឈ្មោះភូមិសាស្ត្រតាមដងស្ទឹងចន្លោះភូមិកេរ្តិ៍ស្រុករវៀងនិងភូមិស្រែវាលស្រុកសណ្តាន់មានចម្ងាយពីរួមស្រុករវៀង២០គីឡូម៉ែត្រ ។ ក្រុមនេសាទធ្វើដំណើរតាមរទេះគោបានទៅដល់អន្លង់ប្រានៅម៉ោង៣រសៀល ។ ត្រីតូចធំពុលស្លាប់អណ្តែតលើផ្ទៃទឹកដែលប្រជាជនប្រមូលយកពុំអស់ ។ ស្អែកឡើងក្រោយពីស្រស់ស្រូបអាហារពេលព្រឹករួចក្រុមខ្ញុំបានយកអួនមួយរយម៉ែត្រទៅហ៊ុមព័ទ្ធកន្លែងលិចទឹកមួយដែលមានជម្រៅបួនម៉ែត្រ ។ ថ្ងៃដំបូងក្រុមខ្ញុំប្រមូលបានត្រីពី៥០០ទៅ៦០០គីឡូក្រាមជាប្រភេទត្រីក្លាំងហាយ សណ្តាយ ខ្យា ក្អែក គ្រំនិងត្រីលិញ ។

ក្រោយរំដោះទីក្រុងភ្នំពេញមួយសប្តាហ៍ តាហង់ គណៈតំបន់១០៣ បានអនុញ្ញាតឲ្យប្រជាជនឈប់សម្រាកដើម្បីចូលរួមអបអរសាទរជ័យជម្នះនេះ ម្យ៉ាងទៀតពិធីបុណ្យចូលឆ្នាំខ្មែរក៏មិនទាន់បានបញ្ចប់ផង ។ ប្រជាជនម្នាក់ៗ ជាពិសេសយុវជនយុវនារី ធ្វើដំណើរទៅលេងសប្បាយពីភូមិមួយទៅភូមិមួយនៅជិតៗទីរួមស្រុករវៀង ។ ភាពសប្បាយរីករាយមិនបានប៉ុន្មានផងស្រាប់តែមានរថយន្តដឹកសម្លៀកបំពាក់ពីភ្នំពេញមកចែកជូនប្រជាជនតាមសហគមន៍ខ្លះ ។ អង្គការប្រាប់ថាសម្លៀកបំពាក់ទាំងនោះជាជយភណ្ឌ ។ តមកទៀតស្រាប់តែឃើញរថយន្តកាំមីញ៉ុងធំៗដឹកប្រជាជនជាច្រើនមកពីភ្នំពេញ ។ ប្រជាជនមូលដ្ឋានដែលធប់ធល់នឹងអង្គការបានប្រមាថអ្នកទើបមកពីភ្នំពេញដែលមិនស្គាល់ស្រូវ ។ ភាពអត់ឃ្លានក៏កើតមានបន្តបន្ទាប់ ។ ប្រជាជនមូលដ្ឋានបានចំអកដល់កូនចៅចិនថា «មិនដឹងថាប្រហុកហូបឆ្ងាញ់យ៉ាងនេះសោះ ទើបតែដឹងនៅពេលនេះ» ។ ភាពជ្រួលច្របល់ក៏កើតមានបន្តទៀត គឺប្រជាជនមួយចំនួនកើតជំងឺគ្រុនចាញ់ស្លាប់ជាបន្តបន្ទាប់ ។ នៅឯមន្ទីរពេទ្យព-២ ពោរពេញទៅអ្នកជំងឺគ្រុនចាញ់ ហើម រាករូស ។

ហេតុការណ៍ថ្មីមួយទៀតបានមកដល់ទឹកដីខេត្តព្រះវិហារ ។ អង្គការបានកំណត់អត្តសញ្ញាណអ្នកដែលជាសីហនុនិយម ហើយបែងចែកពង្រាយតាមភូមិឃុំជុំវិញស្រុករវៀង ។ អ្នកទាំងនោះមានរាជវង្សានុវង្សនិងអស់លោកដែលធ្លាប់មានបុណ្យស័ក្តិតំណែងធំៗក្នុងសង្គមរាស្ត្រនិយម ។ ក្រៅពីនេះ មាននិស្សិតបញ្ញវន្តដែលមកពីបរទេស ។ អ្នកទាំងនោះមិនស្គាល់ការងារស្រែចម្ការបន្តិចបន្តួចសោះ ។

ការហូបចុកចេះតែលំបាកឡើងៗ ការវាយសម្រុកចេះលើកបន្ត រហូតមានពាក្យចចាមអារ៉ាមថា «ធ្វើស្រែប្រវាស់មេឃ ស៊ីបាយ ធ្វើស្រែនឹងទំនប់ប្រឡាយស៊ីបបរ» ។

**យិម ណារិន**

# ជីវិតក្នុងភាពនឹងថ្កល់

**ឃឹម ម៉េង**

**យុទ្ធជន**

*(បទសម្ភាសន៍ជាមួយ ហាវ វ៉ា អាយុ៦០ឆ្នាំ ត្រូវជាបងថ្លៃ និង គីម សេង អាយុ៥៦ឆ្នាំ ត្រូវជាបងស្រី នៅស្រុកកោះសូទិន ខេត្តកំពង់ចាម)*

**ហាវ វ៉ា៖** ម៉េង បួសជានេនបានបីបួនវស្សាដែរ ។ ប្រហែលមួយឆ្នាំក្រោយទម្លាក់សម្ដេច គាត់សឹកទៅធ្វើការនៅរោងចក្រអុសធ្យូងនៅក្រចេះ ។ ខ្ញុំនិងអ្នកភូមិប្រាប់ ម៉េង ថាកុំទៅក្រចេះ ព្រោះនៅទីនោះកំពុងតែមានការកេណ្ឌទាហាន ។ ថាយ៉ាងម៉េចក៏គាត់នៅតែទៅ ។ ថ្ងៃមួយពេលដែល ម៉េង កំពុងតែបើកប្រាក់ខែ ស្រាប់តែគាត់ត្រូវចាប់បង្ខំឲ្យចូលធ្វើទាហាន លន់ ណុល ។ បានបីខែ ម៉េង លួចរត់ត្រឡប់មកផ្ទះវិញ ។ កាលណោះគាត់ស្គមសល់តែស្បែកដណ្ដប់ឆ្អឹង ។ ម៉េង ខឹងក្ដៅក្រហាយពីរឿងនេះ ទើបគាត់ចូលរួមតស៊ូស្រោចស្រង់ប្រទេសជាតិ ។



យឹម ម៉េង (រូបឆ្វេង) ថតជាមួយប្អូនចុងឈ្មោះ សុះ ប្រហែលឆ្នាំ១៩៧៥

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ប្រជាជនប្រមូលផ្ដុំនៅត្រើយម្ខាងទន្លេដើម្បីប្រយុទ្ធ ។ អ្នកតស៊ូទាំងនោះនាំគ្នាកាប់រំលំដើមតទម្លាក់ចូលទន្លេដើម្បីរាំងផ្លូវកប៉ាល់ ។ ប្រជាជននិងអ្នកនៅលើកប៉ាល់បាញ់តគ្នា ។ នៅតំបន់នេះមានការទម្លាក់គ្រាប់បែកជាច្រើនពីសំណាក់អាមេរិកនិងវៀតណាមខាងត្បូង ។ ផ្ទះសម្បែងនិងសាលារៀនរាប់រយខ្នងត្រូវបំផ្លាញខ្ទេចខ្ទីគ្មានសល់ ។ ទាំងរថក្រោះនិងយន្តហោះចូលស្រុករកតែប្រជាជនដេកពួនមិនបាន ។ ប្រជាជននាំគ្នាយកសសរនិងគ្រឿងគ្រោងផ្ទះរបស់ខ្លួនទៅសង់លេណដ្ឋាននិងជម្រកធ្វើពីដី ។

ខ្មែរក្រហមស្រែកថា «ជយោសម្ដេចឪ! អ្នកដែលមិនទៅកាប់ចោល!» ។ ដូច្នេះយើងនាំគ្នាចូលបក្សខ្មែរក្រហមដើម្បីទាមទារឲ្យសម្ដេចវិលត្រឡប់មកវិញ ។ ប្រជាជនដើរដង្ហែជាក្បួនដូចធ្វើបាតុកម្ម ។ អ្នកទាំងនោះមកទាញកអាវយើងឲ្យទៅចូលរួមជាមួយគ្នា យើងមិនអាចឈរក្រពាត់ដៃមើលបានទេ ។

ទាហានលន់ណុលឲ្យយើងជួបនៅម៉ោង៧ព្រឹកដើម្បីចរចារឿងយាងសម្ដេចមកពីប្រទេសបារាំងវិញ ប៉ុន្តែមានតែគ្រាប់កាំភ្លើងមកជំនួស ។ អ្នកនៅជួរមុខស្លាប់អស់ជាច្រើននាក់ ។ ក្រោយពីនេះ យុវជនយុវនារីក្មេងៗជាច្រើននាក់នាំគ្នាចូលព្រៃ ។ ម៉េង ក៏ទៅនឹងគេដែរ ។ ពេល ម៉េង ចូលរួមបដិវត្តន៍ ខ្មែរក្រហមកំពុងតែសហការជាមួយវៀតណាមដើម្បីប្រយុទ្ធ ។ កាលណោះក្នុងកងរបស់ ម៉េង មានមេបញ្ជាការខ្មែរផងវៀតណាមផង ។ អ្នកនៅទីនោះហៅវិធីច្បាំងរបស់ខ្លួនថា ដាក់កុង ឬយុទ្ធសាស្ត្រផ្ការីក ។

ម៉េង មកផ្ទះនៅឆ្នាំ១៩៧៤ ហើយប្រាប់ថា គាត់នឹងត្រឡប់មកម្ដងទៀតនៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមបានគ្រប់គ្រង

ប្រទេស ប៉ុន្តែមិនដែលឃើញគាត់ ។

នៅរវាងឆ្នាំ១៩៧៥-៧៩ ប្រជាជនត្រូវជម្លៀសចេញពីភូមិ ។ ពេលនោះលំបាកណាស់ កុមារជាច្រើនបានស្លាប់ ។ កូនខ្ញុំទាំង៦នាក់បានស្លាប់ ឪពុកខ្ញុំហើមរហូតដល់ស្លាប់ដោយសារឃ្លានខ្លាំងពេក ។

**គីម ស្រៀង:** ពេលនៅក្មេង ម៉េង ចូលចិត្តស្លៀកខោអាវទាហានណាស់ ។ ម៉េង ជាក្មេងស្អាតបាត មានរបៀប គាត់តែងតែដាក់អាវក្នុងខោជាប់ជានិច្ច ។ ម៉េង យកដើមចេកធ្វើកាំភ្លើង ។ មានក្មេងៗជាច្រើនចូលចិត្តលេងជាមួយគាត់ ប៉ុន្តែគាត់ខុសប្លែកពីគេ គាត់ចូលចិត្តកាំភ្លើងគ្រប់ម៉ូដ ។

ម្តាយខ្ញុំយល់សប្តិឃើញ ម៉េង ត្រូវគេចងព្យួរឡើងលើ ប៉ុន្តែអត់ស្លាប់ទេ ។ ម៉ែរំឭកអំពីសុបិនរបស់គាត់ម្តងហើយម្តងទៀត ។ ម៉េង ជាកូនដែលម៉ែស្រឡាញ់ជាងគេ ទៅណាក៏ដោយក៏ម៉ែយក ម៉េង ទៅជាមួយដែរ ។ គ្រួសារយើងមានដីធ្លីតែ៣ម៉ែត្រ ៦តឹកប៉ុណ្ណោះ ។ ពេលដែល ម៉េង ចេញទៅធ្វើកម្មករគាត់ទុកលុយតែ១០រៀលសម្រាប់ខ្លួនគាត់ទេ សល់ពីនោះគាត់ជូនម៉ែទាំងអស់ ។

ឪពុកយើងយកប្រពន្ធទីពីរជាជនជាតិចាម ។ បុរសម្នាក់ទៀតនៅក្នុងរូបថតនេះឈ្មោះ សុស ជាកូនប្រុសរបស់ម្តាយចុងខ្ញុំ ។ ម៉េង និង សុស ធ្លាប់ជាមិត្តភក្តិនិងធ្លាប់ធ្វើទាហានជាមួយគ្នា ។ អ្នកទាំងពីរមិនដឹងថាឪពុករបស់ខ្ញុំបានរៀបការជាមួយម្តាយរបស់ សុស ទេ ព្រោះពេលនោះទាំងពីរនាក់នៅបម្រើក្នុងជួរកងទ័ព ។ ក្រោយពេលដឹងរឿងនេះ អ្នកទាំងពីរឈប់រាប់អានគ្នាតទៅទៀត ។

ម្តាយខ្ញុំចង់ឲ្យ ម៉េង រៀបការ ប៉ុន្តែ ម៉េង មិនរវីរវល់នឹងស្រីណាម្នាក់ឡើយ ។ ម៉េង មិនចង់ដឹងពូរឿងស្តីដណ្តឹងរៀបការអីទេ ។ ម្តាយខ្ញុំនិយាយជាមួយ ម៉េង ថា «ឯងល្មមយកប្រពន្ធហើយ» ប៉ុន្តែ ម៉េង និយាយថា «ម៉ែកុំនិយាយពីរឿងខ្ញុំរៀបការឲ្យសោះ» ។

ពេល ម៉េង មកលេងផ្ទះ គាត់ប្រាប់ថាគាត់នឹងមកលេងម្តងទៀតក្នុងពេលឆាប់ៗនេះ ប៉ុន្តែគាត់បាត់ឈឹងរហូត ។ ◆◆◆

# អ៊ុយ វ៉ែន ហៅ ម៉ៅ
# យុទ្ធនារីកងអនុសេនាធំ៥៥

*(បទសម្ភាសន៍ជាមួយ ស៊ុំ ទូច អាយុ៥៨ឆ្នាំ ត្រូវជាបងថ្លៃស្រី នៅស្រុកស្អាង ខេត្តកណ្តាល)*



អ៊ុយ វ៉ែន មុនឆ្នាំ១៩៧៥

វ៉ែន ជានារីសាមញ្ញម្នាក់មានរូបរាងគ្រាន់បើដែរ ។ គាត់ចូលរួមខ្មែរក្រហមនៅស្រុកកណ្តាលស្ទឹង ក្នុងឆ្នាំ១៩៧១ គឺពេលគាត់មានអាយុ១៩ឆ្នាំ ។ អ្នកភូមិគ្រប់គ្នាចូលរួម ហើយ វ៉ែន ក៏សុំការអនុញ្ញាតពីឪពុកម្តាយដើម្បីចូលរួមនឹងគេគ្រាន់បើជាងនៅផ្ទះលើកដីដែរ ។ ក្រុមយុវនារីនៅភូមិយើងដែលត្រូវខ្មែរក្រហមស្នើឲ្យរែកដីនៅទួលក្រសាំង (ខេត្តកណ្តាល) បានបាត់ខ្លួនទាំងអស់គ្នា ។

ជំនាន់នោះប្រធានភូមិឈ្មោះ ហួន ។ គាត់ដើរកេណ្ឌប្រជាជន ។ នៅភូមិខ្ញុំ អ្នកណាដែលបដិសេធមិនព្រមចូលរួមបដិវត្តន៍ត្រូវខ្មែរក្រហមយកទៅមន្ទីរសន្តិសុខ-០៨នៅត្រែទ្រឿង ឬមន្ទីរ១៥នៅកោះថ្មី ។ ហួន សាហាវបន្តិចដែរ គឺគាត់ហ្នឹងហើយជាអ្នកសម្លាប់បងថ្លៃប្រុសរបស់គាត់ ។

វ៉ែន ត្រូវបញ្ជូនទៅសមរភូមិនៅក្បែរទន្លេមេគង្គ ។ នៅកងរបស់គាត់មានសុទ្ធតែនារីៗ ទៅប្រយុទ្ធនៅសមរភូមិមុខ ។ វ៉ែន



អ៊ុយ វ៉ែន ថតជាមួយមិត្តរួមការងារ ប្រហែលឆ្នាំ១៩៧៧

ជាមេក្រុម ។ កូនទាហានរបស់គាត់ហៅគាត់ថា «យាយម៉ៅ» នេះប្រហែលមកពីគាត់មានសម្បុរខ្មៅហើយមើលទៅ ។ គាត់ចូលប្រយុទ្ធក្នុងសមរភូមិពីរនៅខេត្តកណ្តាល មុនដំបូងនៅកក់ចេះ បន្ទាប់មកនៅច្រិនច្រុម ។

មួយរយៈក្រោយខ្មែរក្រហមបានកាប់កាប់ភ្នំពេញ រ៉ែន មកលេងភូមិបានម្តងពេលគាត់ដើរមករកមើលគោ ។ នៅខែកក្កដាឆ្នាំ១៩៧៧ គាត់បានមកភូមិម្តងទៀតដើម្បីរកស្បៀង ។ ម្តងនេះគាត់ជិះឡានទាហានមក ។ អ្នកមកជាមួយគាត់មានកាន់កាំភ្លើង តែគាត់អត់កាន់អ្វីទេ ។ គាត់កាន់កាំភ្លើងតែនៅក្នុងសមរភូមិប៉ុណ្ណោះ ។ អ្នកភូមិជាច្រើនមកសួរសុខទុក្ខគាត់ តែគាត់បានសម្រាកលេងតែមួយយប់ព្រលឹមឡើងក៏ត្រឡប់ទៅវិញ ។

គាត់អត់មាននិយាយអ្វីច្រើនទេ គ្រាន់តែប្រាប់ថាកុំឲ្យជ្រលក់ខោអាវពណ៌ខ្មៅទាំងអស់ ព្រោះមិនយូរទេរបបថ្មីនឹងចូលមក ហើយគាត់នឹងត្រឡប់មកវិញពេលចប់សង្គ្រាម ។ បន្ទាប់ពីនេះ គាត់បាត់ខ្លួនរហូត ។

ខ្ញុំទុករូបថត រ៉ែន ក្រែងលោថ្ងៃណាមួយគាត់បានត្រឡប់មកវិញ តែខ្ញុំផ្ទាល់គិតថាគាត់មិនរួចខ្លួនពីរបបប៉ុលពតទេ ។ មានមនុស្សនិយាយថា រ៉ែន ស្លាប់នៅព្រៃយ៉ុងដោយការទម្លាក់គ្រាប់បែក ។ ក្រោយមកទៀត មានស្ត្រីម្នាក់ឈ្មោះ ដាន បានប្រាប់ខ្ញុំថា រ៉ែន ត្រូវអង្គការយកទៅទួលស្លែង ។ ក្នុងចំណោមមនុស្សជាច្រើនដែលបានចូលរួមបដិវត្តន៍ជាមួយ រ៉ែន មានតែ ដាន ម្នាក់ប៉ុណ្ណោះដែលនៅរស់ ។ ខ្ញុំបានធ្វើបុណ្យជាច្រើនដើម្បីឧទ្ទិសកុសលដល់ រ៉ែន ។ ◆◆◆

## អ៊ិត អាន
## អនុប្រធានកងវរសេនាធំលេខ១២ កងពល៣១០

*(បទសម្ភាសន៍ជាមួយ អ៊ិត ឡូន អាយុ៦៨ឆ្នាំ ត្រូវជាប្អូនស្រី នៅស្រុកកងមាស ខេត្តកំពង់ចាម)*

បងអាន បួសជាសង្ឃតាំងពីគាត់អាយុ៧-៨ឆ្នាំ រហូតដល់គាត់អាយុ២២ឆ្នាំទើបសឹក ។ បងអាន និយាយថា បានជាគាត់សឹកព្រោះធ្វើជាលោកសង្ឃត្រូវការពេលវេលាយូរអង្វែង ហើយម្យ៉ាងគាត់ចង់ធ្វើការវិញម្តង ។ ពេលគាត់សឹកខ្ញុំប្រាប់គាត់ថាមិនអីទេ បើគាត់ចង់សឹកក៏ស្រេចតែគាត់ចុះ ។ កាលណោះបើ



អ៊ិត អន និងប្រពន្ធឈ្មោះ ចាន់ គិនស្រ៊ីម ថតក្នុងកំឡុងឆ្នាំ១៩៧៣

គាត់នៅក៏ពិបាកដែរ ព្រោះនៅភូមិមានបញ្ហាជាច្រើនកើតឡើង ។ បងអាន បានស្ម័គ្រចិត្តចូលបដិវត្តន៍នៅឆ្នាំ១៩៦៩ គឺពេលដែលគាត់មានអាយុ២៣ឆ្នាំ ។ ខ្ញុំមិនយល់សោះថា ហេតុអ្វីបានជាគាត់ចូលរួមចលនានេះ ហើយគាត់ក៏មិនបានប្រាប់ខ្ញុំដែរ ។

គាត់ទៅទីរួមខេត្តកំពង់ចាម ។ ខ្ញុំបានជួបគាត់នៅទីនោះ ហើយគាត់ក៏បានឲ្យនាឡិកាដៃមួយមកប្តីខ្ញុំ ។ ក្រោយមកគាត់បានផ្លាស់ទៅកន្លែងផ្សេងៗដូចជាខេត្តក្រចេះនិងភ្នំពេញ ។

បងអាន មកលេងគ្រួសារបានពីរដង ។ លើកទីមួយគាត់មកពីកំពង់ចាម នៅលេងបានប្រហែលបួនប្រាំថ្ងៃ ។ គាត់មិនបានយកអ្វីមកតាមក្រៅពីកាំភ្លើងខ្លីមួយដើមប៉ុណ្ណោះ ។ បងអាន ប្រាប់ខ្ញុំថា ការងាររគាត់ជារឿងលាក់ការណ៍ ហើយគាត់ក៏មិនបាននិយាយអ្វីជាមួយអ្នកដទៃទៀតដែរ ។

លើកទីពីរគាត់មកលេងនៅឆ្នាំ១៩៧៣ គឺកន្លះខែក្រោយពីគាត់រៀបការហើយ ។ អង្គការជាអ្នករៀបចំពិធីរៀបការរបស់គាត់ ។ ខ្ញុំមិនបានទៅចូលរួមពិធីរៀបការគាត់ទេ ដោយសារខ្ញុំត្រូវនៅចាំស្រែចម្ការ តែខ្ញុំបានជូនពរគាត់ឲ្យមានអនាគតភ្លឺស្វាង ។

គាត់មានកូនស្រីតូចមួយឈ្មោះ ហាយ នីន ។ កាលកំណើតកូនស្រីគាត់ បងអាន សប្បាយចិត្តដូចបានឡើងឋានសួគ៌ ។

និរសាររបស់គាត់បានមកភូមិនេះម្តងដែរ ។ ខ្ញុំធ្លាក់ខ្លួនឈឺបាត់បង់ឈាមច្រើន ។ និរសាររបស់គាត់ប្រាប់ខ្ញុំថា បើខ្ញុំមិនបានធូរស្បើយទេបងប្រុសខ្ញុំចង់ឲ្យខ្ញុំទៅរកពេទ្យនៅភ្នំពេញ ។ ដំបូងខ្ញុំមិនចង់ទៅទេ ប៉ុន្តែនិរសារគាត់មកម្តងទៀតហើយនាំខ្ញុំទៅមន្ទីរពេទ្យនៅភ្នំពេញ ។ ខ្ញុំនៅទីនោះបានបីខែដោយមានការថែទាំយ៉ាងដិតដល់ពីអ្នកនៅទីនោះ ។ ពេទ្យនៅទីនោះស្រឡាញ់ខ្ញុំទុកដូចម្តាយ ហើយខ្ញុំជួយបោកគក់ខោអាវឲ្យពេទ្យញឹកញាប់ដែរ ។

នៅពេលនោះបងប្រុសខ្ញុំរស់នៅក្បែរភ្នំពេញ ។ ខ្ញុំអត់ស្នាក់នៅជាមួយគាត់ទេ តែបានឆ្លៀតទៅលេងផ្ទះគាត់ដែរ ។ ផ្ទះគាត់ជាផ្ទះល្វែងមានជណ្តើរជាច្រើនកាំទម្រាំតែឡើងដល់ ។ ពេលទំនេរខ្ញុំក្រឡេកមើលជុំវិញឃើញមានត្រី មាន់ និងអាហារជាច្រើននៅទីនោះ ។ កៅអីដែលខ្ញុំបានប៉ះសុទ្ធតែជារបស់ថ្មីៗ ។ ខ្ញុំឃើញមានស្បែកជើងជាច្រើនគូ គ្រឿងសំអាង និងចង្កៀង ។ ខ្ញុំសុំចង្កៀងមួយពីបងប្រុសខ្ញុំ គាត់ថាចង់បានអ្វីយកតាមតែចិត្តខ្ញុំចុះ ។ បងប្រុសខ្ញុំប្រមូលបានប្រាក់ច្រើនសន្ធឹក តែខ្ញុំអត់មានបានមួយកាក់មួយសេនពីគាត់ទេ ។

ក្រោយពេលខ្ញុំចេញពីពេទ្យ បងអាន យកខ្ញុំទៅផ្លូវជ្រោយចង្វារខាងកើតទន្លេសាបឯក្រុងភ្នំពេញដើម្បីលាគ្នា ។ គាត់ថាគាត់បែកលើកនេះមិនដឹងថាពេលណាបានជួបគ្នាវិញទេ ហើយគាត់បានដាស់តឿនខ្ញុំថាកុំឲ្យតមាត់ជាមួយនឹងអង្គការ ព្រោះអង្គការប្រមូលមនុស្សទៅសម្លាប់ ។ យប់នោះខ្ញុំទៅជិះទូកទៅផ្ទះតាមផ្លូវអត់មានភ្លើងបំភ្លឺអ្វីទាំងអស់ ដូច្នេះខ្ញុំត្រូវសម្គាល់មើលមេឃដើម្បីរកផ្ទះខ្ញុំ ។

បងប្រុសខ្ញុំមិនបំភ្លេចខ្ញុំទេ ។ មិនដល់មួយខែផងគាត់បញ្ជូននិរសាររបស់គាត់មកជួបខ្ញុំម្តងទៀត ។ និរសារនោះថា បងអាន នឹកខ្ញុំណាស់ ហើយចង់យកខ្ញុំទៅភ្នំពេញវិញ តែខ្ញុំមិនដែលបានទៅទៀតទេ ។

មានមនុស្សនិយាយថា បងអាន នៅរស់កន្លែងឆ្ងាយៗឯណោះ ។ តែខ្ញុំគិតថាគាត់ច្បាស់ជាត្រូវអង្គការសម្លាប់ចោលហើយ ដោយសារគាត់ធ្លាប់កាន់តំណែងធំដុំ ។ ខ្ញុំឮសួរថាប្រពន្ធគាត់ នៅរស់នៅឡើយ តែខ្ញុំមិនដឹងថានៅទីណា ។ ខ្ញុំមិនដឹងថាក្មួយស្រីខ្ញុំធំប៉ុនណាហើយទេមកដល់ឥឡូវនេះ ។ ◆◆◆

## លី ឈុនឡេង
## យុទ្ធជនកងពល៩២០

*(បទសម្ភាសន៍ជាមួយ អាន ឈុនអី អាយុ៦០ឆ្នាំ ត្រូវជាបងស្រី នៅស្រុកកងមាស ខេត្តកំពង់ចាម)*

ពេលមានសង្គ្រាម ឈុនឡេង ឈប់រៀន ហើយនៅជួយការងារស្រែចម្ការគ្រួសារបានមួយរយៈខ្លី ។ នៅឆ្នាំ១៩៧០



លី ឈុនឡេង (រូបស្តាំ) ថតក្នុងឆ្នាំ១៩៧១

ទាហានលន់ណុលមកកេណ្ឌគាត់យកទៅ ។ កាលណោះបើ ឡេង មិនព្រមរត់ទេ ទាហានទាំងនោះមុខជាចាប់គាត់មិនខាន ។ ១៥ថ្ងៃក្រោយមក ឡេង រត់ចូលព្រៃធ្វើកងទ័ពខ្មែរក្រហម ព្រោះគាត់ចង់ឲ្យសម្តេច សីហនុ ចូលស្រុកវិញ ។

ឪពុកម្តាយខ្ញុំមិនចង់ឲ្យគាត់ធ្វើកងទ័ពទេ តែទម្រាំតែគាត់ទាំងពីរបានដឹងរឿងនេះ ឡេង បានរត់គេចចូលព្រៃបាត់ទៅហើយ ។ ឈុនឡេង គិតថាបើគាត់នៅភូមិតទៅទៀតគាត់ពិតជាស្លាប់ ។

នៅអំឡុងឆ្នាំ១៩៧១ នៅភូមិយើងគ្មានអ្នកណាម្នាក់ដេកលក់ទេ ។ មានការទម្លាក់គ្រាប់បែកមិនឈប់អស់រយៈពេល ៧យប់៧ថ្ងៃ ធ្វើឲ្យផ្ទះសម្បែងខ្ញុំខ្ទេចខ្ទីអស់ ។ ពេលឮសូរទម្លាក់គ្រាប់បែកម្តងៗខ្ញុំរត់ទៅពួននៅតាមផ្នូរខ្មោចនិងតាមប្រឡាយទឹក ។ ទីបំផុតខ្ញុំក៏រើទៅនៅក្បែរប្រឡាយទឹកដោយសង់កូនខ្ទមមួយសម្រាប់ខ្លួនឯង ។

ឈុនឡេង មកលេងផ្ទះបានមួយយប់នៅឆ្នាំ១៩៧៥ ក្រោយថ្ងៃរំដោះ ។ គាត់ជិះឡានមកជាមួយនិងអង្គរក្សពីរនាក់សុទ្ធតែមានកាន់កាំភ្លើង ។ ពេល ឡេង មកលេង ពុកម៉ែប្រាប់គាត់ថាឲ្យឈប់ធ្វើខ្មែរក្រហមទៅតែគាត់មិនស្រពម ។ ពុកម៉ែព្យាយាមបញ្ចុះបញ្ចូល ឡេង ឲ្យត្រឡប់មកផ្ទះវិញ តែ ឡេង និយាយថាបើនៅផ្ទះគ្មានធ្វើអ្វីក្រៅពីរែកដីទេ ។ ឡេង មិនចង់ឲ្យអ្នកណាម្នាក់នៅភូមិត្រួតត្រាគាត់ទេ ទើបគាត់សម្រេចចិត្តបន្តរស់នៅជាមួយខ្មែរក្រហមទៀត ។

ពេល ឈុនឡេង មកលេងផ្ទះជាលើកទីពីរ គាត់ប្រាប់ខ្ញុំថាគាត់ក្លាយជាប្រធានកងពលនៅខេត្តមណ្ឌលគិរី ។ ឡេង និយាយថារស់នៅព្រៃពិបាកណាស់ ណាមួយត្រូវគេចពីគ្រាប់បែក ផងណាមួយសម្បុរមូសខាំឲ្យផង ។ គាត់ថែមទាំងណែនាំខ្ញុំថា បើអង្គការប្រាប់ខ្ញុំឲ្យធ្វើការ ខ្ញុំត្រូវតែធ្វើការឲ្យសកម្ម បើមិនដូច្នោះទេអង្គការពិតជាសម្លាប់ខ្ញុំចោលមិនខាន ។ ប្រាប់ហើយគាត់ត្រឡប់ទៅមណ្ឌលគិរីវិញ ។

នារីម្នាក់ឈ្មោះ សៀង ធ្វើការជាមួយ ឡេង បានប្រាប់ខ្ញុំថា អង្គការចាប់ឡេងយកទៅនៅឆ្នាំ១៩៧៨ ។ ប្តីរបស់ សៀង ក៏ត្រូវអង្គការចាប់ខ្លួនយកទៅដូចប្អូនប្រុសខ្ញុំដែរ ។ អង្គការមកប្រាប់ ឡេង ថា បញ្ជូនទៅប្រជុំ តែតាមពិតសុទ្ធតែពាក្យកុហក ។ ក្រោយមកអង្គការបានសម្លាប់ ឡេង ដោយចោទថា ជាសេ.អ៊ី.អា និងជាខ្សែបណ្តាញវៀតណាម ។

គ្រូទាយបានប្រាប់ខ្ញុំថា ប្អូនប្រុសខ្ញុំនៅរស់តាមព្រំដែនថៃ ។ ខ្ញុំបានទៅទីនោះកាលពីបីឆ្នាំមុន ប៉ុន្តែរកគាត់មិនឃើញសោះ ។ គ្រូទាយប៉ុន្មាននាក់នោះបោកលុយខ្ញុំអស់ជាង៦ម៉ឺនរៀល ។

ថ្វីបើប្អូនប្រុសខ្ញុំមានឋានៈខ្ពស់ក៏ពិតមែន តែខ្ញុំអត់មានអ្វីហូបគ្រប់គ្រាន់ ហើយត្រូវធ្វើការយ៉ាងលំបាកលំបិនទៀត ។ ខ្ញុំត្រូវតែធ្វើដូចនេះ បើមិនដូច្នោះទេអង្គការនឹងសម្លាប់ខ្ញុំ ។ តាមការពិតខ្ញុំត្រូវអង្គការចោទថាជាអ្នកមានតំណែងធំនិងជាចក្រពត្តិ ។ មិនត្រឹមតែប៉ុណ្ណោះ ក្រោយពេល ឈុនឡេង បាត់ខ្លួន ខ្មែរក្រហមបានមកសួរអ្នកភូមិជាច្រើនលើកអំពីប្រវត្តិរូប ។ ខ្ញុំមិនហ៊ានតមាត់នឹងអង្គការសូម្បីតែមួយម៉ាត់ ។

នៅក្នុងរបបនោះយើងមិនដែលបានផឹកទឹកទាល់តែសោះ ហើយយើងអាចផឹកទឹកតែតាមអូរដែលប្រជាជនទុកជាកន្លែងបន្ទោរបង់ ។ ថ្ងៃមួយខ្មែរក្រហមថាសន្ទូងខ្ញុំងាប់អស់ហើយ បើខ្ញុំនៅតែធ្វើការផ្ការដូច្នេះទៀត អង្គការនឹងបញ្ជូនខ្ញុំទៅអូរគ្រួននៅស្រុកកងមាស ។ ទីនោះមានចម្ងាយប្រមាណជាពីរគីឡូម៉ែត្រពីភូមិខ្ញុំនៅ ។ នៅទីនោះមានក្បាលខ្មោចច្រើនណាស់ ។ ក្រោយមកអង្គការរកឃើញថាខ្ញុំមិនមែនជាអ្នកធ្វើឲ្យសន្ទូងងាប់ទេ ទើបខ្ញុំរួចខ្លួន ។

ប្អូនស្រីខ្ញុំម្នាក់ទៀតជាអ្នករដ្ឋការជាន់ខ្ពស់ដែលរស់នៅភ្នំពេញ វាជាប្រជាជនថ្មី ។ វាត្រូវអង្គការជម្លៀសចេញពីភ្នំពេញមករស់នៅជាមួយខ្ញុំ ។ អង្គការចាត់ឲ្យវារែកដី ។ វាត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៧ ។ សមាជិកគ្រួសារខ្ញុំម្នាក់ទៀតក៏ស្លាប់នៅក្នុងរបបនោះដែរ ។ គាត់ឡើងដើមដូងហើយខ្មែរក្រហមវាយគាត់ទាល់តែស្លាប់ ។ ប្តីខ្ញុំឈ្មោះ ឈន ជាគណៈភូមិ ត្រូវខ្មែរក្រហមវាយនឹងអង្កត់ឈើ តែសំណាងល្អគាត់មិនស្លាប់ ។ ◆◆◆

## ឈួន ស្រឿន
## យុទ្ធជន

*(បទសម្ភាសន៍ជាមួយ ឈាន សាន អាយុ៧៣ឆ្នាំ ត្រូវជាម្តាយ និង ឈួន មឿន អាយុ៥៨ឆ្នាំ ត្រូវជាប្អូនស្រី នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម)*

**ឈាន សានៈ** ស្រឿន បានចូលរួមបដិវត្តន៍នៅឆ្នាំ១៩៧០ ពេលអាយុបាន១៨ឆ្នាំ ។ កាលណោះមានប្រជាជនជាច្រើននាក់នាំគ្នាចូលរួម ទើបវាទៅនឹងគេដែរ ។ ស្រឿន មិនបានប្រាប់ខ្ញុំថាទៅណាទេ ។ អ្នកទៅជាមួយវាបីនាក់ទៀតសុទ្ធតែមិនឃើញត្រឡប់មកវិញ ។

ខ្ញុំគិតថា ស្រឿន សម្រេចចិត្តទៅដោយសារតែការវាយដំរបស់ឪពុកវា ។ ពេលត្រូវឃ្វាលគោវាបែរជាទៅដើរលេងវិញ ។


ឈួន ស្រឿន (រូបឆ្វេង)

ថ្ងៃមួយគោចូលទៅស៊ីស្រូវអ្នកដទៃ ឪពុកវាខឹងវាខ្លាំងណាស់ទើបវាយវា ។ ស្រឿន ក្តៅចិត្តនឹងឪពុកក៏ខឹងហើយរត់ចេញពីផ្ទះទៅ ។

នៅឆ្នាំ១៩៧៣ យើងរស់នៅទួលស្រែក្នុងខេត្តកំពង់ចាម ព្រោះទាហានលន់ណុលនិងទាហានខ្មែរក្រហមកំពុងតែប្រយុទ្ធគ្នា និងមានការទម្លាក់គ្រាប់បែកបេ-៥២ជាច្រើនគ្រាប់នៅភូមិខ្ញុំទើបយើងនាំគ្នារត់ចេញ ។ ប្រជាជនជាច្រើនបានស្លាប់នៅតាមផ្លូវ ។ កាលណោះ ស្រឿន មកលេងផ្ទះបានមួយយប់ ។ យើងបានសុំឲ្យវាមកនៅជាមួយយើងវិញដែរ តែវាមិនចង់មកវិញ ។

ស្រឿន ត្រឡប់មកម្តងទៀតនៅឆ្នាំ១៩៧៥ គឺក្រោយខ្មែរក្រហមកាន់កាប់បានបន្តិច ។ វាអត់មានប្រាប់យើងពីរឿងអ្វីទាំងអស់ ។ ក្រោយមក កូនប្រុសបន្ទាប់របស់ខ្ញុំឈ្មោះ ខឿន និងកូនស្រីខ្ញុំឈ្មោះ ហៀង បានបាត់ខ្លួន ។

ពេលមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញប្រវត្តិរូបរបស់ស្រឿន ខ្ញុំត្រេកអរណាស់ ។ ពីមុនខ្ញុំគិតថាកូនប្រុសខ្ញុំនៅរស់ តែឥឡូវខ្ញុំច្បាស់ហើយថាខ្មែរក្រហមបានសម្លាប់វាមែន ។

**ឈួន មឿនៈ** រុន ជានិវាសរបងប្រុសខ្ញុំ បានយករូបថតនេះមកឲ្យម្តាយខ្ញុំក្រោយខ្មែរក្រហមវាយយកបានភ្នំពេញ ។ បងស្រឿន រៀបការនិងមានកូនពីរបីនាក់ ។ ម្តាយខ្ញុំបានផ្ញើផ្លែឈើខ្លះឲ្យ បងស្រឿន និងប្រពន្ធគាត់តែយើងមិនដែលបានជួបអ្នកទាំងពីរម្តងណាសោះ ហើយខ្ញុំមិនដឹងថាគ្រួសារគាត់ស្នាក់នៅឯណាដែរបច្ចុប្បន្ន ។

បងស្រឿន មកលេងផ្ទះតែម្នាក់ឯងបានពីរបីដងដែរ ។ នៅឆ្នាំ១៩៧៣ គាត់ជិះម៉ូតូមកលេងផ្ទះជាលើកទី១ ។ គាត់ធ្វើស្រែនៅខាងជើងភ្នំពេញ ។ គាត់ថាគាត់នៅកងពល៣១៥ ។

បងស្រឿន បានផ្ញើសំបុត្រឲ្យយើងមួយមុនពេលគាត់ត្រូវចាប់ខ្លួន ។ នៅក្នុងសំបុត្រនោះ ។ គាត់សរសេរថាកុំរំពឹងអ្វីអំពីគាត់ឲ្យសោះ ។ គាត់ថា «ថ្ងៃនេះខ្ញុំល្អ តែថ្ងៃស្អែកខ្ញុំអាចក្លាយទៅជាអាក្រក់ផងក៏ថាបាន» ។ ដំបូងយើងមិនយល់រឿងនេះទេ តែក្រោយមកយើងចាប់ផ្តើមដឹងថា កងទ័ពខ្មែរក្រហមផ្សេងទៀតត្រូវអង្គការចាប់ខ្លួន ។ នៅឆ្នាំ១៩៧៦ បងប្អូនជីដូនមួយរបស់ម្តាយខ្ញុំប្រាប់ខ្ញុំថា បងស្រឿន និងប្រពន្ធកូនគាត់ ត្រូវអង្គការស្នើយកទៅរៀនសូត្រ ហើយបាត់ខ្លួនរហូត ។

ក្រោយពីនេះ ស្ថានការណ៍កាន់តែតានតឹង ហើយការសម្លាប់ក៏កើតមាន ។ គណៈភូមិបានមកសួរថាបងប្រុសខ្ញុំនៅរស់ឬអត់ ។ យើងឆ្លើយថាគាត់នៅរស់ ។ ឪពុកម្តាយខ្ញុំពិតជាមិនបានកុហកពីរឿងនេះទេ ។ ពុកម៉ែខ្ញុំថាបានដំណឹងខ្លះៗពី បងស្រឿន ដែរ ។ នៅពេលនោះដូចអ្នកដឹងហើយថា គ្រួសារទាហានខ្មែរក្រហមជាច្រើនត្រូវបញ្ជូនទៅឆ្ងាយៗដោយស្នាដៃគណៈឃុំនេះឯង ។

◆◆◆

## រអៀន អាន
## ប្រធានកងតូចកងដឹកជញ្ជូនភ័ស្តុភារ

*(បទសម្ភាសន៍ជាមួយ ជា អន អាយុ៥៤ឆ្នាំ ត្រូវជាបងប្រុស និង ជា សុខឿន អាយុ៤៦ឆ្នាំ ត្រូវជាប្អូនស្រី នៅស្រុកកងមាស ខេត្តកំពង់ចាម)*

**ជា សុខឿនៈ** ឪពុកម្តាយខ្ញុំចង់ឲ្យ បងអាន បានរៀនសូត្រចេះដឹងនឹងគេ ទើបគាត់ខំលក់ដីធ្លីដើម្បីឲ្យកូនបានចូលរៀន ។ បងអាន ឈប់រៀននៅឆ្នាំ១៩៧០ ពេលដែលខ្មែរក្រហមត្រួតត្រាភូមិយើងនិងចាត់តាំងគាត់ឲ្យធ្វើកងទ័ព ។ មួយរយៈក្រោយមក គាត់រត់ចេញពីជួរទ័ពមកជួយការងារឪពុកម្តាយនៅឯស្រែ

ចម្ការវិញ ។

ក្រោយគាត់មកផ្ទះបានបន្តិច បងអាន បានសុំការអនុញ្ញាតទៅចូលរួមបដិវត្តន៍ម្តងទៀត ។ ឪពុកម្តាយខ្ញុំមិនចង់ឲ្យគាត់ទៅទេ ប៉ុន្តែអង្គការបានយកថ្នាំពេទ្យនិងសឺរ៉ាំងមកឲ្យ បងអាន រៀនពេទ្យ ។ គាត់ផ្តើមធ្វើការងារពេទ្យនៅឃុំបានប្រហែលមួយឆ្នាំដែរ ។ បន្ទាប់មក ខ្មែរក្រហមបានបញ្ជូនគាត់ទៅសមរភូមិនៅខេត្តកំពង់ចាមនិងកំពង់ឆ្នាំងឲ្យគាត់ជួយព្យាបាលអ្នករបួស ។ គាត់ដេកនៅក្នុងរណ្តៅគ្រាប់បែក ។

ឆ្នាំ១៩៧៤ បងអាន ត្រូវរបួសនៅសមរភូមិខេត្តកំពង់ចាម ។ ពេលគាត់ដេកពេទ្យបានជាងមួយខែ អង្គការបញ្ជូនគាត់ទៅធ្វើការនៅភ្នំពេញ ។ គាត់មើលខុសត្រូវសមាជិក១២នាក់ ម្នាក់ៗមានកង់មួយនិងវិទ្យុមួយ ។ ពេល បងអាន មកភូមិម្តងៗគឺគាត់មកស្រាវជ្រាវរកប្រវត្តិរូបអ្នកទាំងនោះ ។



អៀង អាន ថតប្រហែលក្នុងឆ្នាំ១៩៧៦

**ជា អនៈ** ខ្ញុំបានទៅភ្នំពេញសួរសុខទុក្ខ អាន នៅឆ្នាំ១៩៧៥ ។ ពេលខ្ញុំទៅដល់ជាយក្រុង មានកងទ័ពចាប់ខ្ញុំដាក់គុកអស់មួយយប់ ព្រោះមិនចង់ឲ្យខ្ញុំនៅក្នុងទីក្រុង ប៉ុន្តែមានមនុស្សប្រាប់ អាន ថា ខ្ញុំត្រូវចាប់ខ្លួនហើយ អាន បានបញ្ជាឲ្យកងទ័ពទាំងនោះលែងខ្ញុំ ។ អាន យកខ្ញុំមកនៅកន្លែងធ្វើការរបស់គាត់ ។ ខ្ញុំស្នាក់នៅជាមួយគាត់បានបីយប់ដែរ ។ ខ្ញុំមានហូបគ្រប់គ្រាន់កន្លែងដេកស្អាត ។ ប្អូនប្រុសខ្ញុំមិនបាននិយាយអ្វីពីការងារគាត់ទេ ។ គាត់ចេញបាត់ៗតាំងពីព្រលឹមរហូតដល់រសៀលទើបត្រឡប់មកវិញ ។

អាន បានយករូបថតដែលគាត់ថតនៅមុខផ្ទះល្វែងនៅភ្នំពេញមកទីនេះម្តងនៅឆ្នាំ១៩៧៦ ។ គ្រាន់តែឃើញយើងអាចដឹងភ្លាម ព្រោះរូបនេះគាត់ឈរនៅកន្លែងខ្ពស់មានដើមឈើនៅពីក្រោយនិងមានផ្ទះល្វែងតូចមួយ ។ ខ្ញុំដឹងថាគាត់ត្រូវអង្គការប្រគល់តំណែងធំមួយ ហើយអ្នកនៅទីនោះហៅគាត់ថា «តាបេត» ។ នេះមកពីខ្មែរក្រហមហៅកងកាំភ្លើងធំទំហំ៨០មីលីម៉ែត្រហ្នឹងថា «តា» និងម្យ៉ាងគាត់មានកាន់កាំភ្លើង៨០មីលីម៉ែត្រដែរ ។

អ្នកក្រោមបន្ទាប់ប្អូនប្រុសខ្ញុំម្នាក់ដែលធ្វើការនៅភ្នំពេញបាននិយាយថា អង្គការបានយកប្អូនខ្ញុំទៅរៀនសូត្រនៅគុកព្រៃស ។ ក្រោយពីនៅទីនោះបានមួយឆ្នាំ ប្អូនខ្ញុំបាត់ខ្លួន ។ ខ្ញុំមិនជឿថា ប្អូនអាន បានប្រព្រឹត្តកំហុសអ្វីឬក៏សម្លាប់អ្នកណាម្នាក់ឡើយ គឺអង្គការចាប់ដាក់គុកតែទាំងអស់ហ្នឹងឲ្យតែអ្នកនោះជាប្រធានកង ។

**ជា អនៈ** នៅក្នុងរបបខ្មែរក្រហម ខ្ញុំជាអ្នករកត្រី ស្ទូងស្រូវ និងជាន់រហាត់ទឹក ។ សក់ខ្ញុំជ្រុះអស់ដោយសារតែខ្វះអាហារ ។ នៅរវាងឆ្នាំ១៩៧៦-៧៧ខ្មែរក្រហមនាំជនជាតិចិននិងប្រជាជនថ្មីមកពីភ្នំពេញ ជាពិសេសអ្នកមានវ័យចំណាស់និងក្មេងៗដឹកតាមទូកយកទៅខ្មោ ។ ខ្មោស្ថិតនៅស្រុកនេះដែរទេ ប៉ុន្តែយើងត្រូវចំណាយពេលពីរថ្ងៃទើបទៅដល់ ។ គ្រាន់តែប្រជាជនទៅដល់ខ្មោភ្លាមត្រូវខ្មែរក្រហមចាប់ឃុំឃាំងភ្លាម ។ មុនពេលយកអ្នកទាំងនោះទៅសម្លាប់ ខ្មែរក្រហមចាក់ចម្រៀងឮៗដើម្បីកុំឲ្យអ្នកដទៃឮសូរសម្រែករបស់ជនរងគ្រោះ ។

**ជា សុខឿនៈ** នៅឆ្នាំ១៩៧៥អង្គការនាំខ្ញុំត្រឡប់មកភូមិមួយក្បែរភូមិកំណើតដែរ ហើយខ្ញុំត្រូវចាត់តាំងឲ្យធ្វើប្រធានក្រុមកុមារនៅពេលព្រឹក ហើយពេលរសៀលខ្ញុំដើរប្រមូលអាចម៍គោនិងដេញចាបកុំឲ្យស៊ីស្រូវ ។ ដំបូងខ្ញុំមិនចង់បង្រៀនក្មេងៗអស់នោះទេ ព្រោះយើងមានអាយុស្មើរតែស្រករៗគ្នា ។ តែពេលដែលគណៈភូមិចេញបញ្ជាខ្ញុំក៏យល់ព្រម ។

ក្រោយមកបានមួយឆ្នាំ ខ្ញុំដើរត្រឡប់ទៅភូមិវិញ ។ ពេលខ្ញុំមកដល់ ខ្ញុំឃើញឪពុកខ្ញុំកំពុងតែសម្រួចបុស្ស៊ី ។ ពុកសប្បាយចិត្តណាស់រហូតស្រក់ទឹកភ្នែកព្រោះតែអាណិតខ្ញុំ ។ នៅឆ្នាំ១៩៧៨ឪពុកខ្ញុំស្លាប់ដោយសារតែខ្វះអាហារ ។

# រកឃើញអ៊ុំប្រុសតាមរយៈប្រវត្តិរូប

ថ្ងៃដំបូងនៃការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរឆ្នាំរកាកន្លងទៅថ្មីៗនេះ ខ្ញុំបានស្កាត់មកជួបអ៊ុំស្រីបង្កើតខ្ញុំនៅឯភូមិយកបាត្រ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ព្រោះខ្ញុំដឹងច្បាស់ថាគាត់ប្រាកដជាមកលេងស្រុកកំណើតដើម្បីជួបជុំបងប្អូនក្នុងពេលបុណ្យចូលឆ្នាំនេះ ។ ខ្ញុំបានជម្រាបគាត់ឲ្យដឹងអំពីដំណឹងអ៊ុំប្រុសដែលបានបាត់ដំណឹងឈឹងតាំងពីឆ្នាំ១៩៧៧ ។ នៅពេលខ្ញុំប្រាប់គាត់ថាខ្ញុំបានរកឃើញប្រវត្តិរូបរបស់អ៊ុំប្រុស ប៉ែន ដៀន ជាប្រភេទប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ដែលតម្កល់នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា មុនដំបូងគាត់ហាក់ដូចជាស្រឡាំងកាំង ប៉ុន្តែបន្តិចក្រោយមកគាត់បានសម្រួលអារម្មណ៍ឡើងវិញ ។ ខ្ញុំយល់បានថា អ៊ុំស្រីរបស់ខ្ញុំហាក់លែងចង់ដឹងចង់ឮអ្វីតទៅទៀតហើយនៅពេលនេះ ។


ប៉ែន ដៀន ឆ្នាំ១៩៧៧

រយៈពេលជិត៣០ឆ្នាំបានកន្លងផុតទៅ ខួបលើកទី៣០នៃថ្ងៃជ័យជម្នះរបស់របបខ្មែរក្រហមក៏ត្រូវបានប្រារព្ធធ្វើឡើងរួចរាល់ដែរ ។ ឯការទន្ទឹងរង់ចាំសម្រាប់អ្នកដែលនៅសេសសល់ពីសេចក្តីស្លាប់ ចំពោះការបាត់ដំណឹងសូន្យឈឹងរបស់ក្រុមសាច់ញាតិខ្លួនបានអូសបន្លាយទៅនិងស្ទើរតែរង់ចាំតទៅទៀតលែងបាន ។

បើរំឭករឿងរ៉ាវពីអតីតកាលវិញ ក្រុមគ្រួសារនីមួយៗតែងខ្វាយខ្វល់និងស៊ុះស្វែងរកហោរាទស្សន៍ទាយពីភ័ព្វវាសនានៃអ្នកដែលបាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាញឹកញាប់ ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០និងឆ្នាំ១៩៩០ ម្តាយនិងអ៊ុំស្រីបង្កើតរបស់ខ្ញុំបានស្វែងរកហោរាទស្សន៍ទាយស្ទើរគ្រប់ប្រកលួកដើម្បីមើលពីជោគវាសនាអ៊ុំប្រុស ថាតើស្លាប់ឬរស់ ។ គ្រូហោរាភាគច្រើនបានផ្តល់នូវក្តីសង្ឃឹមដល់ក្រុមគ្រួសារខ្ញុំយ៉ាងខ្លាំង ដែលជាហេតុធ្វើឲ្យពួកគាត់ចំណាយពេលវេលានិងប្រាក់កាសច្រើនទៅលើការទស្សន៍ទាយនេះ ។ ភាពស្រពេចស្រពិលទាំងឡាយនៅតែបានដក់ជាប់ក្នុងអារម្មណ៍ម្តាយអ៊ុំស្រីនិងក្រុមគ្រួសាររបស់ទាំងមូល ។ កាលពីឆ្នាំ២០០១ ម្តាយខ្ញុំបានស្លាប់ដោយជំងឺមហារីកទាំងភាពមន្ទិលសង្ស័យ ។ អ៊ុំស្រីបានបៀមទុក្ខព្រួយអស់រយៈពេលជិត៣០ឆ្នាំ ។ នៅទីបញ្ចប់ការពិតត្រូវបានរកឃើញតាមរយៈប្រវត្តិរូបមួយសន្លឹកនេះ ។

អ៊ុំប្រុស ដៀន ត្រូវបានចាប់ខ្លួននៅទីក្រុងភ្នំពេញនិងបញ្ជូនទៅដាក់នៅមន្ទីរឃុំឃាំងគុកទួលស្លែងឬមន្ទីរស-២១ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧ ។ ដំណឹងនេះមិនបានធ្វើឲ្យអ៊ុំស្រីសោកសៅខ្លាំងដូចកាលពីប៉ុន្មានឆ្នាំមុនទេ ។ រាល់ពិធីបុណ្យប្រពៃណីធំៗ ដូចជាបុណ្យភ្ជុំបិណ្ឌនិងចូលឆ្នាំ ក្រុមគ្រួសារនិងសាច់ញាតិទាំងអស់ដែលជាប់សែស្រឡាយជាមួយអ៊ុំប្រុសតែងតែឧទ្ទិសកុសលផលបុណ្យរំឭកដល់វិញ្ញាណក្ខន្ធគាត់ជានិច្ច ។

នឹកដល់រឿងដែលកន្លងផុតទៅ គឺពេលដែលខ្ញុំបាននៅជួបជុំឪពុកម្តាយបងប្អូនកាលពីនៅវ័យសិក្សា ម្តាយខ្ញុំ អ៊ុំស្រីនិងឪពុកខ្ញុំតែងតែនិយាយពីរឿង អ៊ុំដៀន ប្រាប់ខ្ញុំនិងប្អូនៗជារឿយៗ ។ ខ្ញុំធ្លាប់ស្តាប់រឿងនេះស្ទើរតែសាំត្រចៀកទៅហើយ ។ មួយរយៈពេលក្រោយៗមកទៀត ការរំឭករឿងរ៉ាវរបស់អ៊ុំប្រុសហាក់ត្រូវបានបំភ្លេចចោលបន្តិចម្តងៗរហូតដល់លែងមានការនិទាន ។ ចាប់តាំងពីម្តាយខ្ញុំលាចាកលោកទៅ សាច់ញាតិខាងម្តាយខ្ញុំ កាន់តែឃ្លាតឆ្ងាយពីគ្នាបន្តិចម្តងៗ ។ អ៊ុំស្រីខ្ញុំពុំសូវមកលេងផ្ទះខ្ញុំឡើយ ព្រោះតែជីវភាពរបស់គាត់ ។ កូនស្រីទាំងពីររបស់គាត់បានរៀបការនិងមានកូនរៀងៗខ្លួន ។ ដោយសារជីវភាព កូនៗរបស់គាត់បានទៅរស់នៅឆ្ងាយៗពីគ្នាម្នាក់ៗខំប្រឹងប្រែងរកស៊ីចិញ្ចឹមជីវិតរៀងៗខ្លួន ។ កូនប្រុសច្បង

របស់អ៊ំស្រីបានរិះគន់របបខ្មែរក្រហមថា បានធ្វើឲ្យជីវភាពក្រុមគ្រួសារគាត់ធ្លាក់ចុះរកទីបំផុតគ្មាន ។

បើក្រឡេកមើលរូបថតរបស់អ៊ំប្រុសដែលបិទភ្ជាប់នឹងប្រវត្តិរូបរបស់គាត់វិញគឺបានបញ្ជាក់ពីស្នាមញញឹមទាំងបង្កប់នឹងហាក់មិនរវីរវល់ដល់ក្រុមគ្រួសារដែលបានបែកខ្ញែកឡើយ ។ ប៉ុន្តែផ្ទុយទៅវិញ ការធ្វើរបៀបនេះប្រហែលមកពីភាពបាក់ស្បាតក្នុងការធ្វើទារុណកម្មជ្រុលហួសប្រមាណពីកងសន្តិសុខខ្មែរក្រហម ។ នៅក្នុងប្រវត្តិរូបរបស់អ៊ំប្រុស ប៉ែន ដៀន បានបញ្ជាក់យ៉ាងច្បាស់ថា គាត់គឺជាអតីតគិញនៅក្រសួងមហាផ្ទៃកាលពីរបប លន់ ណុល ហើយគឺជាកសិករនៅក្នុងរបបខ្មែរក្រហម ។ ប៉ុន្តែអ៊ំស្រីជាប្រពន្ធរបស់គាត់បានដឹងត្រឹមតែថា ប្តីរបស់គាត់គឺជានាយទាហានជើងអាកាសម្នាក់កាលពីជំនាន់ លន់ ណុល និងមានឈ្មោះមួយទៀតគឺ ប៉ែន ឌិន ។ នៅក្នុងប្រវត្តិរូបក៏បានបញ្ជាក់ដែរថា អ៊ំស្រី ប៊ុត យន គឺជាប្រពន្ធរបស់គាត់ ។ តាំងពីដើមមកឈ្មោះហៅក្រៅរបស់អ៊ំស្រីគឺ យ៉េ ។ គាត់គឺជាកូនស្រីច្បងក្នុងចំណោមបងប្អូន៣នាក់ ។ សព្វថ្ងៃអ៊ំស្រីជាស្ត្រីមេម៉ាយម្នាក់ដែលមាននាទីមើលចៅៗបីបួននាក់នៅក្នុងបន្ទុក ។

បន្ទាប់ពីខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជាទាំងស្រុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់អ៊ំស្រីត្រូវបានជម្លៀសទៅខេត្តក្រចេះ ។ នៅថ្ងៃដែលខ្មែរក្រហមបង្ខំឲ្យប្រជាជនជម្លៀសទាំងអស់ធ្វើប្រវត្តិរូបចម្រាញ់រកអ្នករដ្ឋការដើម្បីត្រឡប់ទៅបំពេញការងារដូចដើមវិញ អ៊ំប្រុស ប៉ែន ដៀន បានបំពេញក្នុងប្រវត្តិរូបពីការងារពិតរបស់គាត់ ។ មិនយូរប៉ុន្មានគាត់ក៏ត្រូវអង្គការបដិវត្តន៍កោះហៅឲ្យមកធ្វើការនៅភ្នំពេញតាមការសន្យា ។ តាំងពីនោះមក អ៊ំប្រុស ដៀន បានបាត់ខ្លួនរហូត ។ កូនទាំងបីរបស់គាត់ថ្វីដ្បិតតែនៅចំណាំមុខឪពុកច្បាស់ ប៉ុន្តែរហូតមកដល់ពេលនេះគាត់ពុំមានបន្សល់ទុកនូវរូបថតឪពុករបស់ខ្លួនមួយសន្លឹកណាឡើយ ។ ចំណែកខ្ញុំវិញ ថ្វីដ្បិតតែបានទទួលការថ្នាក់ថ្នមពីគាត់កាលនៅវ័យកុមារក៏ដោយ ក៏ខ្ញុំមិនដែលបានស្គាល់មុខរបស់គាត់ដែរ ។

នៅខណៈពេលដែលខ្ញុំកំពុងតែធ្វើបញ្ជីឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានប្រទះឃើញប្រវត្តិរូបមួយសន្លឹកពេលនេះធ្វើឲ្យខ្ញុំនឹកឃើញភ្លាមថាឈ្មោះនេះគឺប្តីរបស់អ៊ំស្រីខ្ញុំ ។ កាន់តែច្បាស់ជាងនេះទៅទៀតនោះគឺខ្ញុំបានឃើញឈ្មោះអ៊ំស្រី ប៊ុត យន និងទីលំនៅកំណើតរបស់អ៊ំប្រុស ។ ភ្លាមៗនោះខ្ញុំហាក់អស់សង្ឃឹមយ៉ាងខ្លាំងចំពោះព្រឹត្តិការណ៍បែបនេះ ប៉ុន្តែខ្ញុំមានសេចក្តីរំភើបបន្តិចឡើងវិញព្រោះខ្ញុំបានរកការពិតមួយជូនអ៊ំស្រីរបស់ខ្ញុំដែលនៅតែខ្វាយខ្វល់ពីសុខទុក្ខប្តីរបស់គាត់អស់រយៈពេលជិត៣០ឆ្នាំមកហើយ ។

អ៊ំប្រុស ប៉ែន ដៀន ប្រហែលជាត្រូវបានសម្លាប់នៅជើងឯកជាមួយអ្នកទោសជាច្រើននាក់ផ្សេងទៀត ។ អ៊ំស្រីខ្ញុំមិនអាចរកយុត្តិធម៌ជូនប្តីរបស់គាត់បានទេ គឺបានត្រឹមតែឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធឲ្យបានដល់សុគតិភពនិងចាប់ជាតិជាថ្មីតែប៉ុណ្ណោះ ។ កូនៗទាំងបីនាក់បានទទូចសុំផ្តិតរូបថតដែលបានបិទជាប់នឹងប្រវត្តិរូប ដើម្បីទុកជាទីសក្ការៈនិងគ្រាន់ទុកបង្ហាញដល់ចៅៗជំនាន់ក្រោយដែលមិនស្គាល់មុខជីតា ។

ភាពអយុត្តិធម៌ទាំងឡាយនឹងត្រូវបានវែកញែករកខុសត្រូវនៅពេលដែលអង្គជំនុំជម្រះមួយដែលត្រូវបានបង្កើតឲ្យមានទម្រង់បទដ្ឋានតាមច្បាប់អន្តរជាតិនាពេលដ៏ខ្លីខាងមុខ ។

**ផេង ពង្សរ៉ាស៊ី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# សេចក្ដីប្រកាសរកកូនប្រុសឈ្មោះ ទូន ឆាន



នាងខ្ញុំឈ្មោះ សាន ឃិន អាយុ៧០ឆ្នាំ រស់នៅភូមិរកា ឃុំរកាជន្ទឹង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល សូមសួររកកូនប្រុសច្បងឈ្មោះ ទូន ឆាន ហៅ ឃឿន ដែលបានចូលបម្រើបដិវត្តន៍កាលពីឆ្នាំ១៩៧៣ ហើយបាត់ខ្លួនរហូតបច្ចុប្បន្ន ។ មុនពេលចូលបដិវត្តន៍ ឆាន បួសជាសង្ឃនៅវត្តស្វាយពោធិ នៅក្នុងស្រុកកំណើត ។ បន្ទាប់មក ឆាន ធ្វើដំណើរទៅរៀនបន្តនៅវត្តត្នោតឫស្សីស្រុកនៅខេត្តកំពង់ចាម ។ បីឆ្នាំក្រោយ ពេលដែល ឆាន អាយុ២៥ឆ្នាំ គឺនៅឆ្នាំ១៩៧៣ ឆាន បានសឹកពីបួសហើយចូលបម្រើបដិវត្តន៍ដោយមិនប្រាប់ម្ដាយឪពុកឲ្យដឹងឡើយ ។ នៅឆ្នាំ១៩៧៩ ស្រី នៅក្នុងភូមិជាមួយគ្នាបានប្រាប់ខ្ញុំថា គាត់បានជួប ឆាន នៅខេត្តកំពង់ឆ្នាំង ហើយបានបបួល ឆាន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ ឆាន ប្រកែក ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ គ្រួសារខ្ញុំបានទទួលសំបុត្រមួយពី ឆាន សួររកក្រុមគ្រួសារនៅភូមិកំណើត ប៉ុន្តែពេលនោះយើងទាំងអស់គ្នាមិនបានយកចិត្តទុកដាក់នឹងសំបុត្រនោះប៉ុន្មានទេ ព្រោះរវល់តែខ្វាយខ្វល់នឹងឪពុករបស់ ឆាន ដែលមានជំងឺជាទម្ងន់ ។ ក្រោយពេលធ្វើបុណ្យសពឪពុករបស់ ឆាន រួចមក សំបុត្រនោះក៏បាត់រហូត ហើយខ្ញុំក៏មិនបានទទួលដំណឹងអ្វីពី ឆាន ទៀតដែរ ។

បើកូនបានឃើញសេចក្ដីប្រកាសនេះ ឬញាតិមិត្តណាបានដឹងដំណឹងអំពី ទូន ឆាន សូមមេត្តាទាក់ទងនាងខ្ញុំនៅភូមិឃុំខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារ ០២៣ ២១០ ៣៥៨ ឬតាមរយៈប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# លិខិតឆ្លើយតប

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ លោក ជ្រី ប៊ុនហៀង នៅខេត្តរតនគិរី បានទូរស័ព្ទមកការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រាប់ថា លោកដឹងថាឈ្មោះ ទូន ឆាន ហៅ ឃឿន កំពុងតែរស់នៅខេត្តរតនគិរី ប៉ុន្តែប្រព័ន្ធទូរស័ព្ទបានដាច់មុនពេលដែលខាងមជ្ឈមណ្ឌលយើងបានទទួលពត៌មានលម្អិតពីលោក ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានព្យាយាមទូរស័ព្ទទៅលេខ ០១១ ៩២៩ ៦០០ ដែលលោក ប៊ុនហៀង បានប្រាប់ ប៉ុន្តែលេខនេះគ្មានការប្រើប្រាស់ទេ ។ យើងសង្ឃឹមថាលោក ជ្រី ប៊ុនហៀង ឬ ទូន ឆាន ហៅ ឃឿន នឹងទូរស័ព្ទមកម្ដងទៀត ទាក់ទងឈ្មោះ សាន់ កល្យាណ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា តាមលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៩៨ ៣៩៣ ។ សូមអរគុណ ។

# សេចក្ដីប្រកាសរកប្អូនប្រុសឈ្មោះ លឹម ឡុង

នាងខ្ញុំឈ្មោះ លឹម សុក អាយុ៥៣ឆ្នាំ រស់នៅភូមិកណ្ដាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង សូមសួររកប្អូនប្រុសឈ្មោះ លឹម ឡុង (កើតឆ្នាំមមី) បានចូលបម្រើបដិវត្តន៍តាំងពីឆ្នាំ១៩៧២ ពេលដែលគាត់មានអាយុ១៨ឬ១៩ឆ្នាំ ។ មុនពេលចូលបដិវត្តន៍ ឡុង ជាកងសេនាជនឃុំ ។ រយៈពេល១ខែក្រោយពេលខ្មែរក្រហមបានទទួលជ័យជម្នះទូទាំងប្រទេស ឡុង បានមកលេងផ្ទះម្ដងក្នុងសម្លៀកបំពាក់កងទ័ព ។ ក្រោយពី ឡុង ត្រឡប់ទៅវិញក៏បាត់ដំណឹងរហូតមកដល់បច្ចុប្បន្ននេះ ។

បើបងប្អូនណាបានស្គាល់ឈ្មោះ លឹម ឡុង ឬសាមីខ្លួនបានឃើញសេចក្ដីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈឈ្មោះ នុយ ដានី ទូរស័ព្ទលេខ ០១២ ១៨០ ២៦ ៥២ ឬផ្ដល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬទូរសារលេខ ០២៣ ២១០ ៣៥៨ ។ សូមអរគុណ ។




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

DC-Cam Main Office: #66, Preah Sihanouk Blvd, Tonle Basac, Chamkar Mom, Phnom Penh, Cambodia. Tel: (855) 23 211 875, Fax: (855) 23 210 358, Email:dccam@online.com.kh, Homepage: www.dccam.org.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 66,June 2005. Funded by Norway, Sweden, and USA.**